# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)

អគារលេខ ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ: +៨៥៥(២៣) ៧២៤ ០៤៦
ទូរសារ: +៨៥៥(២៣) ៤២០ ២២០
អ៊ីម៉ែល: admin@ppwsa.com.kh
គេហទំព័រ: www.ppwsa.com.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ




# របាយការណ៍ប្រចាំឆ្នាំ ២០១១



គេហទំព័រ: www.ppwsa.com.kh

# ព័ត៌មានទូទៅអំពី រ.ទ.ស.ភ

## រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ)


ការិយាល័យកណ្តាលៈ លេខ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

លេខទូរស័ព្ទៈ +៨៥៥(២៣) ៧២៤ ០៤៦

លេខទូរសារៈ +៨៥៥(២៣) ៤២០ ២២០

អ៊ីម៉ែលៈ admin@ppwsa.com.kh

គេហទំព័រៈ www.ppwsa.com.kh


អាជ្ញាបណ្ណអាជីវកម្មៈ អនុក្រិតលេខ៥២ អនក្រ.បក កាលបរិច្ឆេទថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦

| មាតិកា | ទំព័រ |
|---|---|
| ចំណុច និងសូចនករសំខាន់ៗ សម្រាប់ឆ្នាំ២០១១ | ០១ |
| ទស្សនៈវិស័យ និងបេសកកម្ម | ០២ |
| របាយការណ៍របស់ អគ្គនាយក | ០៤ |
| អង្គការលេខ | ០៦ |
| ផ្ទៃសេវារបស់ រ.ទ.ស.ភ សម្រាប់ឆ្នាំ២០១១ | ០៧ |
| អភិបាល | ០៨ |
| បុគ្គលិកជាន់ខ្ពស់ | ១១ |
| ការងារផលិតកម្ម, ប្រព័ន្ធចែកចាយទឹក និងការងារកាត់បន្ថយទឹកបាត់បង់ | ១៦ |
| ក- ការងារផលិតកម្ម | ១៨ |
| ខ- ប្រព័ន្ធចែកចាយទឹកស្អាត | ២១ |
| គ- ការងារកាត់បន្ថយទឹកបាត់បង់ | ២២ |
| សកម្មភាព និងលទ្ធផលការងារអាជីវកម្ម ឆ្នាំ២០១១ | ២៤ |
| ក- ការងារផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋក្រីក្រ | ២៦ |
| ខ- ការងារតបណ្តាញចូលផ្ទះ និងការគ្រប់គ្រងអតិថិជន | ២៧ |
| គ- ចំណូលថ្លៃទឹក និងការងារជួសជុល ប្តូរនាឡិកាទឹក | ២៨ |
| របាយការណ៍លទ្ធផលការងារហិរញ្ញវត្ថុ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១(មិនបានធ្វើសវនកម្ម) | ៣០ |
| ក- របាយការណ៍លទ្ធផលហិរញ្ញវត្ថុ | ៣២ |
| ខ- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ | ៣៥ |
| របាយការណ៍លទ្ធផលការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស | ៦៦ |
| ក- ការងារគ្រប់គ្រង | ៦៨ |
| ខ- ការងារអភិវឌ្ឍន៍ធនធានមនុស្ស | ៦៩ |

# ចំណុច និង សូចនករសំខាន់ៗ សម្រាប់ឆ្នាំ២០១១

**ប្រាក់ចំណូលសរុប: ២០១១**

## ១១៥.០៨០ លានរៀល

២០១០: ១០៦.២៦៥ លានរៀល

**ប្រាក់ចំណេញមុនបង់ពន្ធ: ២០១១**

## ៤០.០៥៦ លានរៀល

២០១០: ៣៨.១៧៧ លានរៀល

**ចំណាយពន្ធលើប្រាក់ចំណេញ: ២០១១**

## (៨.០៦៦) លានរៀល

២០១០: (៧.៦៧១) លានរៀល

**ប្រាក់ចំណេញពិតសំរាប់ឆ្នាំ ២០១១**

## ៣១.៩៨៩ លានរៀល

២០១០: ៣០.៥០៦ លានរៀល

ប្រាក់ចំណូលសរុប (គិតជាលានរៀល)




ប្រាក់ចំណេញមុនបង់ពន្ធ (គិតជាលានរៀល)




ប្រាក់ចំណេញពិតតាមបណ្តាឆ្នាំនីមួយៗ (គិតជាលានរៀល)




# សូចនករសំខាន់ៗ

| **បរិយាយ** | **៣១/១២/២០១១** *(មិនបានធ្វើសវនកម្ម)* | **៣១/១២/២០១០** *(បានធ្វើសវនកម្ម)* | **៣១/១២/២០០៩** *(បានធ្វើសវនកម្ម)* |
|---|---|---|---|
| ១- អត្រាចំណាយដំណើរការសហគ្រាស (%) | ៣៧,១៦ | ៣៦,៤០ | ៣៦,៨៨ |
| ២- ទូទាត់បំណុលរយៈពេលវែង (ដង) | ៣,៤១ | ៣,៣៣ | ៣,១៨ |
| ៣- អត្រាបំណុលធៀបទុន (%) | ០,៥៤ | ០,៤០ | ០,៣៧ |
| ៤- ទុនសំរាប់ដំណើការ (ចំនួនថ្ងៃ) | ៨១៩,០៦ | ១.០៤២,១០ | ៨២៣,៨៣ |
| ៥-ចំណេញពិតធៀបចំណូល (%) | ២៣,៤៩ | ២៥,៤៣ | ២៥,៥១ |
| ៦- រយៈពេលប្រមូលចំណូល (ចំនួនថ្ងៃ) | ២១,៩៧ | ២០,៧៦ | ២៣,៧៤ |
| ៧- ថ្លៃលក់ទឹកមធ្យម (រៀល) | ៩៩១,៨១ | ៩៩៨,២៥ | ១.០១៣,១៦ |
| ៨- ថ្លៃដើមមធ្យម (រៀល) | ៨២៤,៣៣ | ៨០៧,៩២ | ៨២១,៦៥ |
| ៩- ថ្លៃដើមផលិតមធ្យម (រៀល) | ២៩៥,០៥ | ២៧៣,៣៣ | ២៥៨,៩៣ |
| ១០- បរិមាណប្រើប្រាស់អគ្គិសនី (វ៉ាត់/ម$^{៣}$) | ២៦៤,៧២ | ២៦៤,៨៥ | ២៤៨,៤៣ |
| ១១- អត្រាវិនិយោគខ្លួនឯង (%) | ០,២៥ | ០,២២ | ០,២១ |
| ១២- សន្ទស្សន៍និយោជិតធៀបអតិថិជន (នាក់/១០០អតិ.) | ២,៧៧ | ២,៩៧ | ៣,១៥ |

# ទស្សនៈវិស័យ & បេសកកម្ម



## ទស្សនៈវិស័យ

រ.ទ.ស.ភ បានប្តេជ្ញាចិត្តបន្តធ្វើឲ្យសេវាផ្គត់ផ្គង់ទឹកស្អាតរបស់ខ្លួនមានការរីកចម្រើនប្រកបដោយចីរភាព ព្រមទាំងធ្វើជាអ្នកផ្តល់ប្រឹក្សា ជាអ្នកសម្របសម្រួល ដើម្បីឲ្យប្រជាពលរដ្ឋ រស់នៅក្នុងទីប្រជុំជនខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងប្រជាពលរដ្ឋរស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ក្នុងពិភពលោកមានទឹកស្អាតប្រើប្រាស់ទាំងអស់គ្នា ។

## បេសកកម្ម

បេសកកម្មរបស់ រ.ទ.ស.ភ គឺធានាផ្គត់ផ្គង់ទឹកស្អាតគ្មានមេរោគ ២៤ម៉ោងក្នុងមួយថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ មានសម្ពាធគ្រប់គ្រាន់ និងក្នុងតម្លៃមួយសមស្របជូនប្រជាពលរដ្ឋទូទាំងរាជធានីភ្នំពេញ និងទីប្រជុំជនរបស់ខេត្តកណ្តាលដែលជាប់នឹងរាជធានីភ្នំពេញ ដោយមិនមើលរំលងប្រជាពលរដ្ឋក្រីក្រ ។ ក្រៅពីនេះ រ.ទ.ស.ភ បាន នឹងកំពុងចែករំលែកបទពិសោធន៍ការងាររបស់ខ្លួនដល់បណ្តារដ្ឋាករទឹក ខេត្ត-ក្រុង មួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្តាអង្គភាពទឹកស្អាតក្នុងតំបន់ និងក្នុងពិភពលោកតាមសំណូមពរ សំដៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ក៏ដូចជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ពិភពលោក ។




ទិដ្ឋភាពស្ថានីយ៍បូមទឹក ពោធិ៍ចក្រជ្រោយចង្វារ

# របាយការណ៍របស់ អគ្គនាយក



" ក្នុងឆ្នាំ២០១១នេះ រដ្ឋាករទឹកមានការរីកចម្រើនខ្លាំងក្លា និង កំណើននៃប្រាក់ចំណេញមានការកើនឡើងជាបន្តបន្ទាប់ កត្តានេះក៏ព្រោះតែការគ្រប់គ្រងបានល្អប្រសើរ ហើយដោយបានប្រើប្រាស់ធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង គ្រប់គ្រងការចំណាយបានយ៉ាងហ្មត់ចត់ជាពិសេសគឺការកាត់បន្ថយអត្រាទឹកបាត់បង់អោយមានកំរិតទាប ។"

**ឯកឧត្តម ឯក សុនចាន់**

ដោយទទួលបានការគាំទ្រពីរាជរដ្ឋាភិបាល, ក្រសួងអាណាព្យាបាល និងក្រុមប្រឹក្សាភិបាល, មានទំនាក់ទំនងល្អពីដៃគូរអភិវឌ្ឍន៍ និងម្ចាស់ជំនួយ រដ្ឋាករទឹកក្រុងភ្នំពេញ បានទទួលស្វយ័តភាពក្នុងដំណើរការអាជីវកម្ម តាំងពីឆ្នាំ១៩៩៧ រ.ទ.ស.ភ មានការប្រែប្រួលខុសស្រឡះពីទិដ្ឋភាពមុនឆ្នាំ១៩៩៣ ។

ប្រព័ន្ធផ្គត់ផ្គង់ទឹកដ៏ចាស់ទ្រុឌទ្រោមត្រូវបានស្តារឡើងវិញជាជំហានៗ ដែលរហូតមកដល់ពេលបច្ចុប្បន្ន ការផ្គត់ផ្គង់ទឹក នៅរាជធានីភ្នំពេញមានការរីកចម្រើន និងមានសេវាលំដាប់ថ្នាក់ពិភពលោក តាមរយៈការអភិវឌ្ឍន៍ក្នុងថេរវេលាដ៏ខ្លីដែលបានចាប់ ផ្តើមពីចំណុចក្រោមសូន្យ ។ ក្នុងការខិតខំប្រឹងប្រែងទាំងនេះធ្វើអោយ រ.ទ.ស.ភ ទទួលបានពានរង្វាន់ជាច្រើនជាបន្តបន្ទាប់ដូចជា រង្វាន់ទឹកឆ្នាំ២០០៤ (ទឹកស្អាតសម្រាប់ទាំងអស់គ្នា); ពានរង្វាន់ រ៉ាមុន ម៉ាកសេយសេយ ឆ្នាំ២០០៦ (សំរាប់សេវាកម្មរដ្ឋាភិបាល) ; មេដាយកិត្តយសផ្តល់ដោយប្រធានាធិបតេយ្យបារាំង ឯកឧត្តមសាកូស៊ីក្នុងឆ្នាំ២០១០ ។ លើសពីនេះទៅទៀត ក្នុងខែកញ្ញា ឆ្នាំ២០១០ រ.ទ.ស.ភ ទទួលបានពានរង្វាន់ឧស្សាហកម្មទឹកស្អាតក្រុងស្តុកហូម ឆ្នាំ២០១០ ដែលជាពានរង្វាន់ថ្នាក់ពិភពលោក ដែលនេះជាសក្ខីភាពថ្មីមួយទៀត នៃការខិតខំប្រឹងប្រែងធ្វើអោយមានការផ្លាស់ប្តូរយ៉ាងធំធេង ដែលរដ្ឋាករទឹកកំពុងឈានទៅមុខ ប្រកបដោយភាពរីកចម្រើន ។

## លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១១

ក្រោយពីទទួលពាន់រង្វាន់នេះ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នៅតែបានខិតខំបន្ថែមទៀតក្នុងដំណើរការប្រព្រឹត្តិកម្ម និង អាជីវកម្មរបស់ខ្លួនបានយ៉ាងរលូន ដែលនេះគឺជាគន្លឹះជោគជ័យក្នុងឆ្នាំ២០១១ ក៏ដូចនាពេលអនាគតរបស់យើង ហើយនិងបន្តរក្សា បានជាអង្គភាពផ្គត់ផ្គង់ទឹកស្អាតលំដាប់ថ្នាក់ពិភពលោក ។

ក្នុងឆ្នាំ២០១១នេះ រ.ទ.ស.ភ ទទួលបានចំណូលសរុបចំនួន ១១៥.០៨០.៣៣០.៧៤២រៀល កើនលើសឆ្នាំ២០១០ ចំនួន ៨,២៩% និងទទួលបានប្រាក់ចំណេញពិតក្រោយពេលបង់ពន្ធចំនួន ៣១.៩៨៩.៩០៧.៤៤៨,៦៨រៀល កើនលើសពីឆ្នាំ២០១០ ចំនួន ៤,៨៦% ។

នាចុងការិយបរិច្ឆេទនេះ ទ្រព្យសកម្មសរុបបានកើនឡើងរហូតដល់ចំនួន ៨៦១.៥៩៧.២៤១.៧៩១,៥២រៀល ដែលនា ឆ្នាំ១៩៩៧ មានចំនួនតែ ២៦២.៥៨៧.១៩៩.០០០រៀល និង ដើមទុនដែលរដ្ឋបានផ្តល់អោយពីឆ្នាំ១៩៩៧ មានចំនួន ២៤៩.០៧០.៦០៧.០០០រៀល បានកើនឡើងរហូតដល់ចំនួន ៤៦៥.០២៨.១២៨.៨០៦,៥៤រៀល ។ ការកើនឡើងនេះគឺដោយសារ រ.ទ.ស.ភ. បានយកចិត្តទុកដាក់ខ្ពស់ជាពិសេសលើការកាត់បន្ថយអត្រាទឹកបាត់បង់ (NRW) ទោះបីសកម្មភាពជួសជុល និង ពង្រីកថ្នល់ទូទាំងរាជធានីភ្នំពេញ ជាមូលហេតុមួយក្នុងចំណោមមូលហេតុជាច្រើន ដែលបណ្តាលអោយមានការលេច-ធ្លាយបំពង់ទឹក ក៏ដោយ ។ ក្នុងឆ្នាំ២០១១នេះ យើងនៅតែសំរេចបានជោគជ័យយ៉ាងធំធេងក្នុងការកាត់បន្ថយអត្រាបាត់បង់ទឹកអោយនៅក្នុងកំរិត លេខ១ខ្ទង់ ដែលអត្រាក្នុងឆ្នាំនេះមានត្រឹមតែ ៥,៨៥% ខុសឆ្ងាយខ្លាំងពីអត្រានាឆ្នាំ១៩៩៣ មានរហូតដល់ ៧២% ។ ការកាត់បន្ថយ ទឹកបាត់បង់ជាកត្តាស្លាប់រស់របស់ រ.ទ.ស.ភ ក្នុងដំណើរការប្រព្រឹត្តិកម្ម និង អាជីវកម្មរបស់ខ្លួនប្រកបដោយគុណភាព និង ចេរភាព ក៏ដូចជាអាចបង្កលក្ខណៈអោយយើងមានទឹកសម្រាប់ផ្គត់ផ្គង់ទឹកស្អាតអាចផឹកបានពីក្បាលរ៉ូប៊ីណេដល់ រាប់ម៉ឺនគ្រួសាររួមទាំង គ្រួសារក្រីក្របំផុតផងដែរក្នុងតម្លៃមួយដ៏សមស្រប រួមចំណែកក្នុងគោលនយោបាយកាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាល ។

រ.ទ.ស.ភ. មានសមត្ថភាពផ្គត់ផ្គង់ទឹក ២៤ម៉ោង/ថ្ងៃ និង៧ថ្ងៃ/សប្តាហ៍ ។ ដោយឆ្នាំនេះអាចធ្វើការផលិតបាន ១០៩.២៧៦.៥២១ម$^{៣}$ លើសមត្ថភាពផលិតគិតជាមធ្យម ១២០.៤៥០.០០០ម$^{៣}$ ។ ការប្រព្រឹត្តិកម្មទឹកស្អាត គឺគោរពតាមស្តង់ដារ គុណភាពទឹកជាតិ និងអង្គការសុខភាពពិភពលោក (WHO) ដោយមានបន្ទប់ពិសោធន៍គុណភាពទឹកអាចវិភាគបាន៥៣មុខ ជាងនេះទៀតក្នុងឆ្នាំ២០១១នេះ យើងមានការវិភាគលើ ២១៣មុខ ពីមន្ទីពិសោធន៍ក្រៅប្រទេស (មន្ទីពិសោធន៍សិង្ហបុរី និងសៀងហៃ) ។

ការយកចិត្តទុកដាក់លើគុណភាពទឹកនេះធ្វើអោយ រ.ទ.ស.ភ. អាចធានាជូនអតិថិជនបាននូវការផឹកដោយផ្ទាល់ពីក្បាលរ៉ូប៊ីណេ ដើម្បីចូលរួមចំណែកក្នុងការទទួលខុសត្រូវចំពោះសង្គម ក្នុងគោលដៅជំរុញអោយប្រជាជនគ្រប់រូបមានទឹកស្អាតប្រើប្រាស់ ដែលជាកម្មវិធីទឹកស្អាតសម្រាប់ទាំងអស់គ្នា "Water for All" ដោយមានសេវា អនាម័យត្រឹមត្រូវ ដើម្បីការរស់នៅប្រកបដោយ សុខុមាលភាព មានជីវភាពល្អប្រសើរ និងមានបរិស្ថានល្អ ។

ទិសដៅនៃការពង្រីកបណ្តាញចែកចាយទឹក គឺទៅតំបន់មានសក្តានុពលសេដ្ឋកិច្ច ដោយមិនមើលរំលងប្រជាជនក្រីក្រ ដែលធ្វើអោយប្រវែងបំពង់មេចែកចាយទឹកបច្ចុប្បន្នមានស្មើនឹង ១.៨៩២គីឡូម៉ែត្រ និងរក្សាសម្ពាធជាមធ្យម២០ម៉ែត្រ ក្នុងបណ្តាញចែកចាយទឹកទាំងមូលផ្ទុយពីឆ្នាំ១៩៩៣ ដែលមានប្រវែងតែ ២៨៨គីឡូម៉ែត្រ ប៉ុណ្ណោះ។

យើងបានខិតខំធ្វើអោយកាន់តែប្រសើរឡើងនូវគុណភាពសេវាអតិថិជនដើម្បីស្វែងរក និង បង្កើនចំនួនអតិថិជនធំៗដែលមានតម្រូវការទឹកច្រើន (ដើម្បីធានាថ្លៃលក់មធ្យមកើន) និងធានាបាននូវប្រសិទ្ធិភាពនៃការប្រមូលប្រាក់ថ្លៃទឹក ដែលអត្រាទារប្រាក់ ក្នុងឆ្នាំ២០១១ គឺ ៩៩,៩០% ហើយកំណើនបណ្តាញអតិថិជន កើនឡើងរហូតដល់ ២១៩.៤៩៨ បណ្តាញ ក្នុងនោះបណ្តាញអតិថិជនក្រីក្រចំនួន ២៧.៧០៧ បណ្តាញ ស្មើនឹង ១៤,៣៧%នៃចំនួនបណ្តាញដែលបានតសរុប។

## ការរំពឹងទុកសម្រាប់ឆ្នាំ២០១២

ក្នុងឆ្នាំ២០១២ ខាងមុខ រ.ទ.ស.ភ នៅតែប្រកាន់ខ្ជាប់នូវទស្សនៈវិស័យ និង បេសកម្ម ដែលបានលើកពីបណ្តារឆ្នាំមុនដដែល ។ ជាទិសដៅសំរាប់ឆ្នាំ២០១២ រ.ទ.ស.ភ សង្ឃឹមថានឹងទទួលបានប្រាក់ចំណេញពិតក្រោយបង់ពន្ធមិនតិចជាងចំនួន ៣២.៤៩៩.៨៣២.០០០រៀល ដែលក្រុមប្រឹក្សាភិបាល និងក្រសួងអាណាព្យាបាលបានអនុម័ត ។

រ.ទ.ស.ភ. ក៏នៅតែប្តេជ្ញាចិត្ត ផ្តល់សេវាកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាព និង ប្រសិទ្ធិភាព ដើម្បីផ្តល់ការជឿជាក់ពីអតិថិជន ។ ជាងនេះទៅទៀត រ.ទ.ស.ភ. នៅតែខិតខំផ្តល់បណ្តាញទឹកជូនប្រជាជនក្រីក្រតាមរូបភាព ឧបត្ថម្ភថ្លៃច្បាប់ជាវទឹក ស្របទៅតាមកម្រិតជីវភាពគ្រួសារនីមួយៗ ពី៣០%, ៥០%, ៧០% និង ១០០% ដើម្បីអនុវត្តគំរោងចែកចាយទឹក ពិសេសជូនសហគមន៍ក្រីក្រ ដោយប្រើជំនួយរបស់ទីក្រុងប៉ារីស ចំនួន ៥០.០០០អឺរ៉ូ អោយអស់ ដើម្បីប្រយោជន៍ប្រជាជន។

រ.ទ.ស.ភ កំពុងសាងសង់ នឹងគ្រោងដាក់អោយដំណើរការសាកល្បង ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនិរោធន៍ ជំហានទី១ ដែលមានសមត្ថភាពផលិត ១៣០.០០០ ម៉ែត្រគូប/ថ្ងៃ នៅត្រីមាសទី៤ ឆ្នាំ២០១២ ខាងមុខ ដែលធ្វើអោយសំពាធទឹកនៅភាគខាងលិច និង ភាគខាងត្បូងរាជធានីភ្នំពេញកើនឡើង និងធ្វើអោយគុណភាពសេវាកម្មរបស់យើងកាន់តែប្រសើរឡើង ។

តាមការចង្អុលវាសផែនទីគោលចរយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក្នុងដំណើរការបង្កើត និងអភិវឌ្ឍទីផ្សារមូលបត្រនៃកម្ពុជា ដើម្បីសក្តានុពលខ្លាំងក្លាលើការវិនិយោគនៅក្នុងប្រទេស ដែលធ្វើអោយប្រទេសកម្ពុជាអាចឈានដល់កំរិតទាន់ប្រទេសជឿនលឿន រ.ទ.ស.ភ. បានត្រៀមខ្លួនគ្រប់គ្រាន់ដើម្បីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងនៅដើមត្រីមាស ទី២ ឆ្នាំ២០១២ (IPO) ទៅតាមអ្វីដែលក្រសួងអាណាព្យាបាលបានផ្តល់កាតព្វកិច្ចអោយ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។

បន្តការផ្សព្វផ្សាយអំពីគុណភាពទឹកស្អាតអាចផឹកបានពីក្បាលរ៉ូប៊ីណេជូនប្រជាជនអោយកាន់តែទូលំទូលាយថែមទៀត។

ជាថ្មីម្តងទៀត រ.ទ.ស.ភ សូមថ្លែងអំណរគុណចំពោះការគាំទ្រពីរាជរដ្ឋាភិបាល ក៏ដូចជាអាណាព្យាបាលទាំងពីរ គឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និង សូមសំដែងនូវអំណរគុណដល់ក្រុមប្រឹក្សាភិបាល ចំពោះការគាំទ្រ និងការដឹកនាំល្អសំរាប់ឆ្នាំ២០១១ ដែលធ្វើអោយ រ.ទ.ស.ភ បានទទួលជោគជ័យដូចសព្វថ្ងៃនេះ ។

**ឯកឧត្តម ឯក សុនចាន់**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
អគ្គនាយក រ.ទ.ស.ភ.
ថ្ងៃទី ខែ ឆ្នាំ២០១២

# រចនាសម្ព័ន្ធ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ




*សម្គាល់:* អង្គការលេខ គិតត្រឹមខែកញ្ញា ឆ្នាំ២០១១

# ផ្ទៃសេវារបស់ រ.ទ.ស.ភ សម្រាប់ឆ្នាំ ២០១១




ផ្ទៃសេវា ចុងឆ្នាំ២០១១
ផ្ទៃសេវា សំរាប់ឆ្នាំ២០២០

ផ្ទៃសេវារបស់ រ.ទ.ស.ភ សម្រាប់ឆ្នាំ២០១១

# អភិបាល

## ឯកឧត្តម ម៉េង សក្តិធារ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧២ និងបានទទួលជាវិស្វករជំនាញនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ក្នុងឆ្នាំ១៩៩៣ (វិស្វករជំនាញ ភូគព្ភសាស្ត្រ-រ៉ែ) និងទទួលបានបរិញ្ញាបត្រ នៅវិទ្យាស្ថាន National Politechnique de Lorrain នៃប្រទេសបារាំង ក្នុងឆ្នាំ១៩៩៦ (ជំនាញគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក) ។ លោកបានបម្រើការងារឲ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨ ជាប្រធាននាយកដ្ឋានទឹកស្អាត និងជាប្រធានគម្រោងទឹកស្អាត និងអនាម័យក្រោម ឥណទានរបស់ធនាគារពិភពលោក ។ ចាប់ពីឆ្នាំ២០០៨ ដល់បច្ចុប្បន្ន លោកមានតួនាទីជាអគ្គនាយក នៃអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឯកឧត្តម ម៉េង សក្តិធារ៉ា ហើយក៏ជាប្រធានក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ និងរដ្ឋាករទឹកស្វយ័តក្រុងសៀមរាប ។



តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ឯកឧត្តម ឯក សុនចាន់

សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៥០ និងបានទទួលជាវិស្វករជំនាញនៅវិទ្យាស្ថាន បច្ចេកទេសជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត ក្នុងឆ្នាំ១៩៧៤ (វិស្វករជំនាញ អគ្គិសនី) ។ ពីឆ្នាំ២០០៦ ដល់ឆ្នាំឆ្នាំ២០០៨ លោកមានតួនាទីជាអគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។ ចាប់ពីឆ្នាំ២០០៨ រហូតដល់បច្ចុប្បន្ន លោកជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក រ.ទ.ស.ភ និងជាសមាជិកក្រុមប្រឹក្សាភិបាល ។ ក្នុងកំឡុងពេល ដឹកនាំ រ.ទ.ស.ភ ឯកឧត្តម ឯក សុនចាន់ បានទទួលបានស្នាដៃ មេដាយ និងពានរង្វាន់ជាបន្តបន្ទាប់ដូចជា រង្វាន់ទឹកឆ្នាំ២០០៤ (ទឹកស្អាតសម្រាប់ទាំងអស់គ្នា) ពី ADB; ពានរង្វាន់ រ៉ាមុន ម៉ាកសេយសេយ ឆ្នាំ២០០៦ (សំរាប់សេវាកម្ម រដ្ឋាភិបាល) ; លោកត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រសិទ្ធនាមជា វីរៈបុរសធនធានទឹកនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦; លោកបានទទួលមេដាយកិត្តិយសផ្តល់ដោយប្រធានាធិបតេយ្យបារាំង ឯកឧត្តម សាកូស៊ី ក្នុងឆ្នាំ២០១០។ លើសពីនេះទៅទៀត ក្នុងខែកញ្ញា ឆ្នាំ២០១០ លោកបានដឹកនាំ រ.ទ.ស.ភ អោយទទួលបានពានរង្វាន់ឧស្សាហកម្មទឹកស្អាតក្រុងស្តុកខូម ឆ្នាំ២០១០ ដែលជាពានរង្វាន់ថ្នាក់ពិភពលោក ។



ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក រ.ទ.ស.ភ



## ឯកឧត្តម អ៊ីវ ខេង

សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ១៩៤៩ និងបានទទួលបរិញ្ញាបត្រនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ១៩៧៥ (ជំនាញ អក្សរសាស្ត្រ) ។ លោកបានបម្រើការងារឲ្យទីស្តីការគណៈរដ្ឋមន្ត្រី និងចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ន ។

តំណាងទីស្តីការគណៈរដ្ឋមន្ត្រី



## ឯកឧត្តម ជូ វិជិត្ត

សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៣ និងបានទទួលអនុបណ្ឌិតសេដ្ឋកិច្ចកសិកម្ម នៃបណ្ឌិតសភាកសិកម្ម Timiryazev ក្រុងមូស្គូនៃសហភាពសូវៀត នៅឆ្នាំ១៩៩០ ។ លោកបានទទួល បណ្ឌិតសេដ្ឋកិច្ច នៃបណ្ឌិតសភាកសិកម្ម Timiryazev ក្រុងមូស្គូនៃសហព័ន្ធរុស្ស៊ី ក្នុងឆ្នាំ១៩៩៤ ។ លោកបានបម្រើការងារឲ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាគណៈលេខាធិការរង និង មានតួនាទីជានាយក ខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ លោកចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន ។

តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



## ឯកឧត្តម សុខ ហេង

សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧២ និងបានទទួលបរិញ្ញាបត្រគ្រប់គ្រងនៅសកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៤ ។ លោកទទួលបានអនុបណ្ឌិត នៅសកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៧ ។ លោកបានបម្រើការងារឲ្យក្រសួងមហាផ្ទៃ មានតួនាទីជាអគ្គនាយករង នៃអគ្គនាយដ្ឋានរដ្ឋបាលមូលដ្ឋាន ចាប់ពីឆ្នាំ២០០៦ ដល់បច្ចុប្បន្ន ។ លោកចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ន ។

តំណាងក្រសួងមហាផ្ទៃ



## លោក ឡុង ណារ៉ូ

សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៦ និងបានទទួលជាវិស្វករជំនាញ Mechanical នៅសាលាវិស្វកម្មសម្រាប់ Plant and Construction នៃប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ១៩៨៩ ។ លោកបានទទួលអនុបណ្ឌិតរដ្ឋបាលអាជីវកម្ម នៅវិទ្យស្ថាន សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៦ ។ លោកបានបម្រើការងារឲ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាអគ្គនាយករង ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ និងចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន ។

តំណាងនិយោជិត រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ



## លោក នួន សុមេធ

សមាជិកក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៥២ និងបានបញ្ចប់ឆ្នាំទី២ នៅមហាវិទ្យាល័យពាណិជ្ជសាស្រ្ត ក្នុងឆ្នាំ១៩៧៥ ។ លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងរដ្ឋបាលសាធារណៈ នៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា ។ លោកបានបម្រើការងារឲ្យ សាលារាជធានីភ្នំពេញ មានតួនាទីជានាយកខុទ្ទកាល័យ ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ។ លោកជាអភិបាលរង រាជធានីភ្នំពេញ ពីឆ្នាំ២០១០ រហូតដល់បច្ចុប្បន្ន និងចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ។

តំណាងសាលារាជធានីភ្នំពេញ



*សម្គាល់: បទពិសោធន៍របស់អភិបាល ០៥(ប្រាំ) ឆ្នាំចុងក្រោយ*

# បុគ្គលិកជាន់ខ្ពស់

## ឯកឧត្តម ឯក សុនចាន់

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក រ.ទ.ស.ភ



ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៥០ និងបានទទួលជាវិស្វករជំនាញនៅវិទ្យាស្ថាន បច្ចេកទេសជាន់ខ្ពស់មិត្តភាពកម្ពុជា-សូវៀត ក្នុងឆ្នាំ១៩៧៤ (វិស្វករជំនាញ អគ្គិសនី) ។ ពីឆ្នាំ២០០៦ ដល់ឆ្នាំឆ្នាំ២០០៨ លោកមានតួនាទីជាអគ្គនាយក រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។ ចាប់ពីឆ្នាំ២០០៨ រហូតដល់បច្ចុប្បន្នលោកជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក រ.ទ.ស.ភ និងជាសមាជិកក្រុមប្រឹក្សាភិបាល ។ ក្នុងកំឡុងពេល ដឹកនាំ រ.ទ.ស.ភ ឯកឧត្តម ឯក សុនចាន់ បានទទួលបានស្នាដៃ មេដាយ និងពានរង្វាន់ជាបន្តបន្ទាប់ដូចជា រង្វាន់ទឹកឆ្នាំ២០០៤ (ទឹកស្អាតសម្រាប់ទាំងអស់គ្នា) ពី ADB; ពានរង្វាន់ រ៉ាមុន ម៉ាកសេយសេយ ឆ្នាំ២០០៦ (សំរាប់សេវាកម្ម រដ្ឋាភិបាល) ; លោកត្រូវបាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រសិទ្ធនាមជា វីរៈបុរសធនធានទឹកនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦; លោកបានទទួលមេដាយកិត្តិយសផ្តល់ដោយប្រធានាធិបតេយ្យបារាំង ឯកឧត្តម សាកូស៊ី ក្នុងឆ្នាំ២០១០។ លើសពីនេះទៅទៀត ក្នុងខែកញ្ញា ឆ្នាំ២០១០ លោកបានដឹកនាំ រ.ទ.ស.ភ អោយទទួលបានពានរង្វាន់ឧស្សាហកម្មទឹកស្អាតក្រុងស្តុកខូម ឆ្នាំ២០១០ ដែលជាពានរង្វាន់ថ្នាក់ពិភពលោក ។

## លោក ឡុង ណារ៉ូ

អគ្គនាយករង



ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៦ និងបានទទួលជាវិស្វករជំនាញ Mechanical នៅសាលាវិស្វកម្មសម្រាប់ Plant and Construction នៃប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ១៩៨៩ ។ លោកបានទទួលអនុបណ្ឌិតរដ្ឋបាលអាជីវកម្ម នៅវិទ្យាស្ថាន សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៦ ។ លោកបានបម្រើការងារឲ្យរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាអគ្គនាយករង ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ និងចូលជាសមាជិកក្រុមប្រឹក្សាភិបាល នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០០៩ រហូតដល់បច្ចុប្បន្ន ។

## ឯកឧត្តម នេត មុន្នី

មន្ត្រីត្រួតពិនិត្យរដ្ឋ



ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៥ និងបានទទួលសញ្ញាបត្រ សាលាកម្រិតសិក្សា ទី៣ តាខ្មៅ ក្នុងឆ្នាំ១៩៨៤ ។ លោកបានទទួលបរិញ្ញាបត្រសេដ្ឋកិច្ចរោងចក្រ នៅសាលាវិស្វករ បច្ចេកទេស គមនាគមន៍ នៃប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ១៩៨៨ និងបានទទួលអនុបណ្ឌិត សេដ្ឋកិច្ចហិរញ្ញវត្ថុ នៅសកលវិទ្យាល័យ ឡុងដុង (កម្ពុជា និងអង់គ្លេស) ក្នុងឆ្នាំ១៩៩៧ ។ លោកបានបម្រើការងារឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីជាប្រធាននាយកដ្ឋាន ទ្រព្យសម្បត្តិរដ្ឋ (គ្រប់គ្រងគ្រងបញ្ជីអចលនៈទ្រព្យរដ្ឋ គ្រប់គ្រងរាល់ចំណូលទទួលបានពីអចលនៈទ្រព្យរដ្ឋ គ្រប់គ្រងសហគ្រាសសាធារណៈ និងរដ្ឋបាលនៃស្ថាប័នរដ្ឋ ត្រួតពិនិត្យលើសហគ្រាសសាធារណៈ) និងជាមន្ត្រីត្រួតពិនិត្យរដ្ឋ នៅរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ន ។

## លោក រស់ គឹមលាង

អគ្គនាយករង



ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៦២ និងបានទទួលបរិញ្ញាបត្រ ជំនាញវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅវិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ១៩៩១ ។ លោកបានទទួលអនុបណ្ឌិត ហិរញ្ញវត្ថុ នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងឆ្នាំ២០០៣ ។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជាប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ ពីឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១១ ។ ចាប់ពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន លោកមានតួនាទីជា អគ្គនាយករង ទទួលបន្ទុកការងារហិរញ្ញកិច្ច និង ទីផ្សារមូលបត្រ និងជាប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ។



## លោក គែវ សុវណ្ណរិទ្ធ

អគ្គនាយករង

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៦៩ ។ លោកបាន ទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច នៅវិទ្យាស្ថានស្ថាបត្យកម្ម និងសំណង់ នៃប្រទេសសូវៀត ។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាអគ្គនាយករង ទទួលបន្ទុកនាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ ពីចាប់ឆ្នាំ២០០៦ រហូតដល់ បច្ចុប្បន្ន ។



## បណ្ឌិត ជា វិសុទ្ធ

អគ្គនាយករង

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៦០ និងបានបញ្ចប់ការសិក្សា នៅមហាវិទ្យាល័យភាសា Leipzig នៃប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ១៩៨៤ ។ លោកបានទទួលអនុបណ្ឌិត វិស្វកម្ម គ្រប់គ្រងទឹក ក្នុងឆ្នាំ១៩៨៩ និងទទួលបានបណ្ឌិតវិទ្យាសាស្ត្រ វិស្វកម្ម ក្នុងឆ្នាំ១៩៩៤ នៅមហាវិទ្យាល័យបច្ចេកវិទ្យា Dresden នៃប្រទេសអាល្លឺម៉ង់ ។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាជំនួយការអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស ព្រមទាំងជាគណៈកម្មការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា (PEAC) ពីឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១១ ។ លោកគឺជាអគ្គនាយករង ទទួលបន្ទុកក្រុមប្រឹក្សាភិបាល, ការងារលេខាធិការដ្ឋាន និងការងារបណ្តុះបណ្តាល នៅ រ.ទ.ស.ភ ចាប់ពីខែធ្នូ ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ។



## លោក សំរិទ្ធ សុវិទ្យា

អគ្គនាយករង

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៦៤ និងបានទទួលជាវិស្វករជំនាញ មេកានិចឧស្សាហកម្មធុនស្រាល នៅមហាវិទ្យាល័យម៉ាស៊ីន និងបរិក្ខានៃឧស្សាហកម្មលេនីនក្រាត នៃសហភាពសូវៀត ក្នុងឆ្នាំ១៩៩១ ។ លោកបានទទួលអនុបណ្ឌិតជំនាញគ្រប់គ្រង នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ២០០៣។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាប្រធាននាយកដ្ឋានផែនការ និងគម្រោង ពីឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១១ ។ លោកជាអគ្គនាយករងទទួលបន្ទុកការងារផែនការ និងវិនិយោគ និងជាប្រធាននាយកដ្ឋាន ផែនការ និងគម្រោងចាប់ពីខែធ្នូ ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ។



## លោក យុត ឧទ្យារិទ្ធ

អគ្គនាយករង

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៦៦ ។ លោកបានបញ្ចប់ការសិក្សានៅសាលាកម្រិតទី៣ ភូមិភាគខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៨៦ និងបានទទួលបរិញ្ញាបត្រ វិស្វករជំនាញ ទឹកស្អាត និងលូទឹក នៅវិទ្យាស្ថានវិស្វកម្ម នៃប្រទេសសូវៀត ក្នុងឆ្នាំ១៩៩៣ ។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាប្រធាននាយកដ្ឋាន ផលិតកម្ម និងផ្គត់ផ្គង់ទឹក ពីឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១១ ។ លោកជាអគ្គនាយករង ទទួលបន្ទុកការងាររដ្ឋបាល និងធនធានមនុស្សចាប់ពីខែធ្នូ ឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ។



## លោក ស៊ឹម ខេងលីន

ប្រធាននាយកដ្ឋានអាជីវកម្ម

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៤៧ និងបានទទួលបរិញ្ញាបត្រផ្នែកគណិតវិទ្យា នៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ១៩៧៥ ។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាប្រធាននាយកដ្ឋានអាជីវកម្ម ចាប់ពីឆ្នាំ២០០៦ រហូតដល់បច្ចុប្បន្ន ។

## លោកស្រី រឿន ណារី

ប្រធាននាយកដ្ឋាន រដ្ឋបាល និងធនធានមនុស្ស



ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកស្រីកើតនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៦៧ និងបានទទួល បរិញ្ញាបត្រផ្នែកគ្រប់គ្រង នៅសកលវិទ្យាល័យបៀលប្រាយ ក្នុងឆ្នាំ២០០៤ ។ លោកស្រី បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកច្បាប់ នៅសកលវិទ្យាល័យឯកទេសនៃកម្ពុជា ក្នុងឆ្នាំ ២០១១ ។ លោកស្រីបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាប្រធានការិយាល័យធនធានមនុស្ស ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨ និង ជាប្រធាននាយកដ្ឋាន រដ្ឋបាល និងធនធានមនុស្ស ចាប់ពីឆ្នាំ២០០៨ រហូតដល់បច្ចុប្បន្ន ។

## លោក សែម ម៉ុនហេង

ទីប្រឹក្សា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ



ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៥១ និងបានទទួលបរិញ្ញាបត្រសេដ្ឋកិច្ច នៅវិទ្យាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឆ្នាំ១៩៩២ ។ លោកបានបម្រើការងារឲ្យ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានតួនាទីជាអគ្គនាយករង ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ ។ លោកជាទីប្រឹក្សា រ.ទ.ស.ភ ចាប់ពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន ។

*សម្គាល់: បទពិសោធន៍របស់បុគ្គលិកជាន់ខ្ពស់ ០៥(ប្រាំ) ឆ្នាំចុងក្រោយ*





# ការងារផលិតកម្ម, ប្រព័ន្ធចែកចាយទឹក និង ការងារកាត់បន្ថយទឹកបាត់បង់

## ដំណើរការនៃប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាត

បច្ចុប្បន្ន រ.ទ.ស.ភ មានលទ្ធភាពផលិតទឹកស្អាតជាមធ្យមបាន ៣៣០.០០០ម៉ែត្រគូប/ថ្ងៃ លើសមត្ថភាពដើម ៣០០.០០០ម៉ែត្រគូប/ថ្ងៃ ដោយរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំនួន ៣គឺ ៖

- រោងចក្រភូមិព្រែក មានសមត្ថភាពប្រព្រឹត្តកម្មចំនួន ១៧០.០០០ ម៉ែត្រគូប/ថ្ងៃ
- រោងចក្រជ្រោយចង្វារ មានសមត្ថភាពប្រព្រឹត្តកម្មចំនួន ១៥០.០០០ ម៉ែត្រគូប/ថ្ងៃ
- រោងចក្រចំការមន មានសមត្ថភាពប្រព្រឹត្តកម្មចំនួន ២០.០០០ ម៉ែត្រគូប/ថ្ងៃ

ប្រព្រឹត្តកម្ម និងផ្គត់ផ្គង់ទឹកស្អាតប្រចាំថ្ងៃ គឺផ្អែកតាមតម្រូវការប្រើប្រាស់ទឹករបស់ប្រជាជនក្នុងផ្ទៃសេវា ដែលតម្រូវការនេះអាចកើនឡើង ឬថយចុះមិនទៀងទាត់ ដែលទាក់ទងនឹងកត្តារដូវកាល និងអាកាសធាតុ ។ ការចាត់ចែងដំណើរការរោងចក្រនីមួយៗ ដើម្បីបំពេញតម្រូវការប្រើប្រាស់ត្រូវបានគិតគូរទៅដល់ប្រសិទ្ធិភាពសេដ្ឋកិច្ច របស់រោងចក្រនីមួយៗជាមុន ហេតុនេះទើបអត្រាដំណើរការរបស់រោងចក្រនីមួយៗ ធៀបនឹងសមត្ថភាពប្រព្រឹត្តកម្មពុំដូចគ្នាទាំងស្រុង ។

ជារួម សង្វាក់ផលិតកម្មទឹករបស់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតទាំងអស់របស់ រ.ទ.ស.ភ ចែកចេញជា ៣ដំណាក់កាល៖

១- ស្ថានីយបូមទឹកល្អក់ (ទឹកទន្លេ)
២- ស្ថានីយប្រព្រឹត្តកម្មទឹក
៣- ស្ថានីយបូមទឹកស្អាត

## ប្រព័ន្ធចែកចាយទឹកស្អាត

ប្រព័ន្ធចែកចាយទឹកស្អាតត្រូវបានបែងចែកជា ២ផ្នែកគឺ:

- <u>បំពង់មេនាំទឹក:</u> ជាបំពង់មេធំៗមានទំហំចាប់ពី ២៥០ម.ម ឡើងទៅ ដែលមានតួនាទីបញ្ជូនទឹកស្អាតពីស្ថានីយបូមទឹកស្អាតទៅបំពង់ចែកចាយ ។ បច្ចុប្បន្ន រ.ទ.ស.ភ មានបំពង់មេទំហំធំបំផុត ១.៦០០ ម.ម ។ ដោយផ្អែកលើតួនាទី និងសម្ពាធទឹកក្នុងបំពង់ដូចនេះបំពង់មេនាំទឹក ត្រូវបានកំណត់ឲ្យប្រើប្រាស់បំពង់ប្រភេទដែកស្វិត (Ductile Iron) ។
- <u>បំពង់ចែកចាយទឹក:</u> ជាបំពង់មានទំហំចាប់ពី ៥០ម.ម ដល់២០០ម.ម ដែលទទួលទឹកស្អាតពីបំពង់មេនាំទឹក រួចចែកចាយដល់អតិថិជន ។ រ.ទ.ស.ភ កំណត់ឲ្យប្រើប្រាស់បំពង់ចែកចាយជាប្រភេទ HDPE ព្រោះមានតម្លៃថោកសមរម្យ តែមានគុណភាពខ្ពស់សមស្រប លើកលែងតែបំពង់ចែកចាយក្នុងខណ្ឌ ៧មករា និងមួយផ្នែកនៃខណ្ឌទួលគោក ដែលស្ថិតក្នុងគម្រោងជំនួយរបស់ប្រទេសជប៉ុនទើបជាបំពង់ដែកស្វិត ។

## ការបាត់បង់ទឹក

ការងារដែលមានលក្ខណ:ជាគន្លឹះបំផុតនោះគឺ ការងារគ្រប់គ្រងទឹកបាត់បង់តាមតំបន់ ដោយហេតុថា រ.ទ.ស.ភ បានចាត់ទុកការកាត់បន្ថយទឹកបាត់បង់ គឺជាកត្តាស្លាប់រស់របស់អង្គភាព ដោយហេតុថាការកាត់បន្ថយទឹកបាត់បង់អោយចុះទាប ជាហេតុនាំអោយបង្កើនបាននូវអត្រាធ្វើវិក័យប័ត្រ និងឈានទៅបង្កើនបាននូវចំណូលថ្លៃទឹក ។

# ក- ការងារផលិតកម្ម

## ក.១- ការផលិតទឹកស្អាត

### ស្ថានីយប្រព្រឹត្តកម្ម

ប្រព័ន្ធប្រព្រឹត្តកម្មទឹកចែកជា៦ដំណាក់កាលគឺ (ទី១)អាងទទួលទឹក (ទី២)អាងកូរ (ទី៣) អាងផ្ដុំកករ (ទី៤) អាងរង (ទី៥) អាងច្រោះ និង(ទី៦) អាងស្តុកទឹកស្អាត ។ ក្នុងការចម្រាញ់ទឹកដើម "ទឹកទន្លេ" ឲ្យទៅជាទឹកស្អាតចាំបាច់ត្រូវប្រើសារធាតុគីមីសាច់ជូរ កំបោរ និងឧស្ម័នក្លរ ដែលសារធាតុនីមួយៗមានតួនាទីផ្សេងៗគ្នាក្នុងការសម្អាតទឹក៖

- សាច់ជូរ: មានតួនាទីធ្វើឲ្យភាគល្អិតតូចៗនៃកករចាប់ផ្ដុំគ្នាជាដុំកករធំ មានទម្ងន់ធ្ងន់ដែលអាចរងចុះបាន ។ ភាគល្អិតទាំងនេះរួមមានដីឥដ្ឋ និងដីល្បាប់ សារធាតុគីមីសរីរាង្គ កាកសំណល់ពីដំណើរការប្រព្រឹត្តកម្មផ្សេងទៀត និងសារធាតុសរីរាង្គតូចៗជាច្រើនទៀត ។
- កំបោរ: សម្រាប់បង្កើន pH នៃទឹក មានន័យថា បន្ថយជាតិអាស៊ីតក្នុងទឹក ។
- ក្លរ: មានតួនាទីសំលាប់មេរោគ និងកម្ចាត់សារធាតុជីវសាស្ត្រ (ពពួកស្លែ) ចេញពីទឹក ។

រ.ទ.ស.ភ បានផ្គត់ផ្គង់ទឹកស្អាត ទៅតាមតម្រូវការប្រើប្រាស់របស់អតិថិជន ដោយដំណើរការ ប្រព័ន្ធផលិតកម្មដែលមានស្រាប់ និងធានាគុណភាពទឹកស្អាត គ្មានមេរោគ និងអាចផឹកបានផ្ទាល់ពីបណ្ដាញចែកចាយ ។ ជាលទ្ធផលការងារផលិតកម្ម ឆ្នាំ២០១១ របស់ រ.ទ.ស.ភ មានភាពល្អប្រសើរ ធៀបទៅនឹងផែនការ ដែលបានដាក់ចុះ ។

| បរិយាយ | ផែនការឆ្នាំ (គិតជា ម៣) | អនុវត្តជាក់ស្តែង (គិតជា ម៣) | អត្រា (គិតជា %) |
|---|---|---|---|
| រោងចក្រភូមិព្រែក | ៤៨.៨៥៤.០០០ | ៥២.៧៩៧.០៦១ | ១០៨ |
| រោងចក្រជ្រោយចង្វារ | ៥៣.១៨០.៦១១ | ៥១.៥២៤.៨៥០ | ៩៧ |
| រោងចក្រចំការមន | ៥.៩៩៦.០០០ | ៤.៩៥៤.៦១០ | ៨៣ |
| **សរុប** | ១០៨.០៣០.៦១១ | ១០៩.២៧៦.៥២១ | ១០១ |



ទិដ្ឋភាពរោងចក្រផលិតទឹកស្អាតភូមិព្រែក

## កម្ពស់ទឹកទន្លេទាំង៣ តាមរដូវកាល

ជាទូទៅ កម្ពស់ទឹកទន្លេទាំង ៣ ប្រែប្រួលទៅតាមរដូវកាល ហើយកម្ពស់ទឹកក្នុងឆ្នាំនីមួយៗក៏ពុំដូចគ្នាដែរ ដោយសារតែកត្តាអាកាសធាតុ និងជាពិសេសអាស្រ័យទៅនឹងរបបទឹកទន្លេមេគង្គ ។ ខាងក្រោមនេះជាតារាងសង្ខេបនៃកម្ពស់ទឹកពីអតីតកាលទន្លេទាំង ៣ (ឯកតាគិតជាម៉ែត្រ) ៖

| **បរិយាយ** | **២០១១** | | **២០១០** | | **២០០៩** | | **២០០៨** | | **២០០៧** | |
|---|---|---|---|---|---|---|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា | រដូវប្រាំង | រដូវវស្សា |
| ទន្លេមេគង្គ | ២,៣០ | ១០,៩០ | ២,១៩ | ៨,៣៧ | ២,០៦ | ៩,៦៤ | ២,០៥ | ៩,១៣ | ២,២៧ | ៩,៩៨ |
| ទន្លេបាសាក់ | ២,១៩ | ១០,៧៩ | ២.០៩ | ៨,២៧ | ២,០១ | ៩,៥៤ | ១,៩៥ | ៩,០៣ | ២,១៧ | ៩,៨៨ |
| ទន្លេសាប | ១,៧៦ | ៩,៨២ | ១.៥៥ | ៨,៣៨ | ២,០៣ | ៩,៦២ | ១,៨៨ | ៨,៩៣ | ១,៧២ | ៩,៦៣ |

ខណៈដែលតារាងនេះឆ្លុះបញ្ចាំងពីទិន្នន័យបច្ចុប្បន្ន រ.ទ.ស.ភ មិនអាចផ្តល់ការធានាណាមួយថាកម្រិតទឹកទាំងនេះមិនមានបម្រែបម្រួលខ្លាំងនាពេលអនាគត ខាងមុខនេះ ។

## ការប្រើប្រាស់វត្ថុធាតុដើមក្នុងការផលិតទឹកស្អាត

| **បរិយាយ** | **ភូមិព្រៃក** | | **ជ្រោយចង្វារ** | | **ចំការមន** | | **សរុបរួម** | | **អត្រា** |
|---|---|---|---|---|---|---|---|---|---|
| | ផែនការ | លទ្ធផល | ផែនការ | លទ្ធផល | ផែនការ | លទ្ធផល | ផែនការ | លទ្ធផល | % |
| **សាច់ជូរ** (គីឡូក្រាម) | ១.០៥១.៩៨៣ (២១,៥៣ក្រ/ម$^{៣}$) | ១.២២៨.៨០០ (២៣,២៧ក្រ/ម$^{៣}$) | ៦១៨.៦៣៦ (១១,៦៣ក្រ/ម$^{៣}$) | ៥៣៩.២៥០ (១០,៤៧ក្រ/ម$^{៣}$) | ១៣១.៨៩៧ (២២ក្រ/ម$^{៣}$) | ១១៨.១៥០ (២៣,៨៥ក្រ/ម$^{៣}$) | ១.៨០២.៥១៦ (១៦,៦៩ក្រ/ម$^{៣}$) | ១.៨៨៦.២០០ (១៧,២៦ក្រ/ម$^{៣}$) | ១០៥% |
| **កំបោរ** (គីឡូក្រាម) | ២២៦.៣០១ (៤,៦៣ក្រ/ម$^{៣}$) | ២៤៤.៦២០ (៤,៦៣ក្រ/ម$^{៣}$) | ២០.៤៧៣ | 0 | ៨.៨៨១ (១,៤៨ក្រ/ម$^{៣}$) | ២.៩០០ (០,៥៩ក្រ/ម$^{៣}$) | ២៥៥.៦៥៥ (២,៣៧ក្រ/ម$^{៣}$) | ២៤៧.៥២០ (២,២៧ក្រ/ម$^{៣}$) | ៩៦% |
| **ក្លរ** (គីឡូក្រាម) | ១១១.១៩១ (២,២៧ក្រ/ម$^{៣}$) | ១២០.៩៧៨ (២,២៩ក្រ/ម$^{៣}$) | ១០០.២៦១ (១,៨៥ក្រ/ម$^{៣}$) | ៨៦.០០០ (១,៦៧ក្រ/ម$^{៣}$) | ១៥.៥៥៦ (២,៥៩ក្រ/ម$^{៣}$) | ៩.១៩៦ (១,៨៦ក្រ/ម$^{៣}$) | ២២៦.៩៥៨ (២,១០ក្រ/ម$^{៣}$) | ២១៦.១៧៤ (១,៩៨ក្រ/ម$^{៣}$) | ៩៥% |
| **អគ្គិសនី** (គ.វ.ម) | ១៣.១៧៧.០៧០ (២៥៧ វ៉ាត់/ម$^{៣}$) | ១៣.៧៤៧.៤៨៤ (២៦០ វ៉ាត់/ម$^{៣}$) | ១៤.៥១១.០១៨ (២៧៣ វ៉ាត់/ម$^{៣}$) | ១៣.៨៣៥.៩៤០ (២៦៨ វ៉ាត់/ម$^{៣}$) | ១.៦៩៧.៦៨០ (២៦៨ វ៉ាត់/ម$^{៣}$) | ១.៣៩៣.៨៥០ (២៨១ វ៉ាត់/ម$^{៣}$) | ២៩.៣៨៥.៧៦៨ (២៧២ វ៉ាត់/ម$^{៣}$) | ២៨.៩៧៧.១៩៤ (២៦៥ វ៉ាត់/ម$^{៣}$) | ៩៨% |

## គុណភាពទឹក (អនុវត្តក្នុងឆ្នាំ២០១១)

បានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមយន្តការដំណើរការស្តង់ដារគុណភាពទឹក និងកម្មវិធីត្រួតពិនិត្យគុណភាពទឹក ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ត្រួតពិនិត្យគុណភាពទឹកតាមរោងចក្រផលិតទឹកទាំងបីចំនួន ០៣ដងក្នុងមួយថ្ងៃ ។
- ត្រួតពិនិត្យគុណភាពទឹកនៅតាមបណ្តាញចែកចាយចំនួន ៨០កន្លែងក្នុងមួយសប្តាហ៍ យ៉ាងទៀងទាត់ ។
- គុណភាពទឹកស្ថិតក្នុងការអនុវត្តញ្ញាតិរបស់ស្តង់ដារគុណភាពទឹកផឹករបស់ WHO ។

| **មុខវិភាគ** | **ឯកតា** | WHO | **រោងចក្រ ភូមិព្រៃក** | **រោងចក្រ ជ្រោយចង្វារ** | **រោងចក្រ ចំការមន** | **បណ្តាញ ចែកចាយ** |
|---|---|---|---|---|---|---|
| ភាពល្អក់ | NTU | ៥ | <១,១០ | <០,៩០ | <១,៣០ | <១,២០ |
| តម្លៃប៉េហាស់ | PH | ៦,៥ - ៨,៥ | ៧,១០ | ៧,៣០ | ៦,៩០ | ៧,២០ |
| ក្លរសេរី | mg/l | ០,១ - ១ | ០,៨៦ | ០,៩១ | ០,៧៨ | ០,៩៧ |
| ក្លរសរុប | mg/l | ០,៥ - ២ | ១,០៣ | ១,១៥ | ១,១០ | ១,១០ |
| មេរោគកូលីហ្វម | cfu/100ml | 0 | 0 | 0 | 0 | 0 |
| មេរោគហ្វីកល់កូលីហ្វម | cfu/100ml | 0 | 0 | 0 | 0 | 0 |
| មេរោគអ៊ីកូលី | cfu/100ml | 0 | 0 | 0 | 0 | 0 |

# ក.២- ការងារជួសជុល និងថែទាំប្រព័ន្ធផលិតកម្ម

រាល់ការងារថែទាំ និង ជួសជុលគ្រឿងចក្រនៃប្រព័ន្ធផលិតកម្មឆ្លើយតបពេញលេញទៅនឹងតំរូវការ និង លក្ខខ័ណ្ឌ បច្ចេកទេសជាក់លាក់ ។ ផ្អែកលើយន្តការខាងលើ រ.ទ.ស.ភ. បានអនុវត្តនូវកម្មវិធីត្រួតពិនិត្យ-ថែទាំជួសជុល ទទួលបានលទ្ធផល១០០% មានដូចរៀបរាប់ខាងក្រោម៖

## រោងចក្រ ភូមិព្រែក

- ជួសជុលកូយឺតអាងចាស់ចំនួន ០៣គ្រឿង
- ដាក់សំណាញ់ការពារស្លែនៅស្ថានីយបូមទឹកល្អក់
- ជួសជុលប្តូរ Capacitor ម៉ូទ័របូមទឹកល្អក់ ចំនួន០១គ្រឿង
- ប្តូរ Time relay ទូរបញ្ជាម៉ាស៊ីនខ្យល់លាងអាងច្រោះ
- ជួសជុលលាបថ្នាំអគារអគ្គីសនី ស្ថានីយបូមទឹកល្អក់
- ជួសជុលលាបថ្នាំអគារការពារសំពាធគំហុក ស្ថានីយបូមទឹកល្អក់
- ជួសជុលកូរលឿនអាងចាស់ចំនួន ០២គ្រឿង
- ជួសជុលប្តូរ Capacitor ម៉ូទ័រយោងសាច់ជូ
- ជួសជុលប្តូរ Display ជញ្ជីងក្លរ
- ប្តូរអំពូលសញ្ញា និងខ្សែទូរបញ្ជាអាងច្រោះចាស់
- ជួសជុលប្តូរជណ្តើរចុះអាងស្តុកចាស់

## រោងចក្រ ជ្រោយចង្វារ

- ជួសជុលម៉ូទ័របូមទឹកល្អក់ចំនួន ០២ គ្រឿង
- ជួសជុលប្រព័ន្ធក្លរ
- ជួសជុលប្រព័ន្ធកូរយឺតចំនួន ០២គ្រឿង
- ជួសជុលទ្វារទឹកសំណល់
- ជួសជុលវ៉ានពោង និងឧបករណ៍ការពារសំពាធ
- ជួសជុលអាងលាយសាច់ជូរ
- ថែមខ្សាច់អាងច្រោះចំនួន ០៨អាង (ជំហាន១)
- ជួសជុលប្រព័ន្ធកូរលឿនចំនួន ០៣គ្រឿង
- ជួសជុលប្រព័ន្ធសុញ្ញកាស ០១គ្រឿង

## រោងចក្រ ចំការមន

- ជួសជុលស្ថានីយ៍ និងម៉ូទ័របូមទឹកល្អក់
- ជួសជុលប្តូរ Capacitor ម៉ូទ័របូមទឹកស្អាត
- ជួសជុលឧបករណ៍ការពាររន្ទះរបស់ត្រង់ស្វូរ Post C
- ជួសជុលប្តូរ Capacitor ម៉ូទ័របូមទឹកល្អក់
- ជួសជុលម៉ូទ័រលាងអាងច្រោះ
- ជួសជុលអាងស្តុកទឹក ថ្ម

## គ្រឿងចក្របម្រើការដ្ឋាន

- ជួសជុលរថយន្តស្ទូចចំនួន ២០គ្រឿង
- ជួសជុលអេស្កាវ៉ាទ័រចំនួន ១៨គ្រឿង
- ជួសជុលរថយន្តធុនមធ្យមចំនួន ១៩គ្រឿង
- ជួសជុលម៉ាស៊ីន និងគ្រឿងចក្រធុនតូចចំនួន ៧៣គ្រឿង
- ជួសជុលរថយន្តធំដឹកអេស្កាវ៉ាទ័រចំនួន ០២គ្រឿង
- ជួសជុលរថយន្តបែនចំនួន ២៨គ្រឿង
- ជួសជុលរថយន្តដឹកទឹកចំនួន ០៦គ្រឿង
- ជួសជុលសាហ្ស៊ីច្រូកដីចំនួន ១៧លើក
- ជួសជុលត្រាក់ទ័រចំនួន ០២គ្រឿង

# ខ- ប្រព័ន្ធចែកចាយទឹកស្អាត

## ខ.១- ការងារពង្រីកផ្ទៃសេវា

| **បរិយាយ** | **ផែនការឆ្នាំ** (គិតជាម៉ែត្រ) | **អនុវត្តជាក់ស្តែង** (គិតជាម៉ែត្រ) |
|---|---|---|
| ១- បំពេញច្រកទាំង ៨ខណ្ឌ | ១៥.០០០,០០ | ៣.៧៦៧,៥០ |
| ២- ខណ្ឌ ចំការមន | ០ | ០ |
| ៣- ខណ្ឌ ឫស្សីកែវ សែនសុខ | ២.៨០០,០០ | ២០.៣២០,៧០ |
| ៤- ខណ្ឌ មានជ័យ | ៩.៦៣២,០០ | ៣៣.៥៨៩,៥០ |
| ៥- ខណ្ឌ ដង្កោ | ៣៣.៣២៨,០០ | ៧២.៣២២,១៥ |
| ៦- ស្រុក អង្គស្នួល | ០ | ៥.០៧៧,០០ |
| ៧- ស្រុក តាខ្មៅ | ០ | ៣.២០១,៨០ |
| **សរុប** | **៥៩.៧៦០,០០** | **១៣៨.២៧៨,៦៥** |

គិតត្រឹមឆ្នាំ១៩៩៣ រ.ទ.ស.ភ មានប្រព័ន្ធចែកចាយទឹកស្អាតប្រវែងសរុប ២៨៨ គ.ម ដែល មានបន្ទាត់ផ្ចិតទំហំចាប់ពី ៦០ម.ម ដល់ ៧០០ម.ម ។ ដោយមានគុណភាពទ្រុឌទ្រោមបន្សល់ទុកពី របបកម្ពុជាប្រជាធិបតេយ្យ រួមផ្សំនឹងកង្វះខាតថវិកាសម្រាប់ការជួសជុល - ថែរក្សា និង ផ្លាស់ប្តូរថ្មី ធ្វើឲ្យប្រព័ន្ធចែកចាយទឹកស្អាតនៅពេលនោះកាន់តែមានស្ថានភាពទ្រុឌទ្រោមខ្លាំងទៅ ។

ក្រោយពីការផ្លាស់ប្តូរបំពង់ចាស់ និងបំពេញផ្ទៃសេវាចាស់ចប់សព្វគ្រប់ ការដាក់បំពង់ថ្មីដើម្បីពង្រីកផ្ទៃសេវាបានអនុវត្តន៍ចាប់ពីឆ្នាំ២០០២ និងបន្តរហូតមកដល់បច្ចុប្បន្ន ក្រោមឥណទានរបស់ធនាគារពិភពលោក និង ធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ ។

មកដល់ចុងឆ្នាំ២០១១ នេះ រ.ទ.ស.ភ មានបំពង់មេចែកចាយទឹកសរុបប្រវែង ១.៨៩២គីឡូម៉ែត្រ ។

ប្រវែងបំពង់ដែលបានដាក់តាមឆ្នាំនីមួយៗ
(គិតជាគីឡូម៉ែត្រ)







ការដាក់បំពង់ទំហំ ១៦០០ម.ម លើផ្លូវជាតិលេខ ១

# គ- ការងារកាត់បន្ថយ ទឹកបាត់បង់

អត្រាទឹកបាត់បង់របស់ រ.ទ.ស.ភ នៅក្នុងឆ្នាំ១៩៩៣ មានកម្រិតខ្ពស់បំផុតគឺ ៧២% ប៉ុន្តែអត្រានេះបានថយចុះជាលំដាប់រហូតមកនៅក្នុងរង្វង់ ៦% ប៉ុណ្ណោះនៅក្នុងឆ្នាំ២០០៨ ពោលគឺក្នុងរយៈពេលត្រឹមតែ ១៥ឆ្នាំប៉ុណ្ណោះ ដែល រ.ទ.ស.ភ បានបន្ថយទឹកបាត់បង់ពី ៧២% មកនៅត្រឹម ៦% ដូចបានបង្ហាញក្នុងក្រាហ្វិចខាងក្រោម ។ ការទទួលបានលទ្ធផលល្អប្រសើរក្នុងរយៈពេលខ្លីនេះ បានធ្វើអោយស្ថាប័នអន្តរជាតិធំៗវាយតម្លៃខ្ពស់ចំពោះ រ.ទ.ស.ភ តាមរយៈការផ្តល់ជ័យលាភី និងពានរង្វាន់លំដាប់ពិភពលោក ដូចមានរៀបរាប់ខាងលើ ។

លទ្ធផលកាត់បន្ថយទឹកបាត់បង់នេះបានមកដោយ រ.ទ.ស.ភ បានបង្កើតនូវវិធានការចំនួន ៦ ក្នុងកម្មវិធីកាត់បន្ថយទឹកបាត់បង់របស់ខ្លួនគឺ៖

- ការងារគ្រប់គ្រងអតិថិជន
- ការងារគ្រប់គ្រងនាឡិកាទឹក
- ការផ្លាស់ប្តូរបំពង់ចាស់ដោយដាក់បំពង់ថ្មី
- ការជួសជុលទឹកធ្លាយទាន់ពេលវេលា
- ការងារគ្រប់គ្រងទឹកបាត់បង់ជាតំបន់
- ការបង្ការ និងបង្រ្កាបបទល្មើស

ជាលទ្ធផលការងារមកដល់ចុងឆ្នាំ២០១១ នេះ រ.ទ.ស.ភ បានអនុវត្តដោយសំរេចបានដូចខាងក្រោម៖

## ការងារជួសជុល និងថែទាំឧបករណ៍ប្រព័ន្ធផ្គត់ផ្គង់ទឹក

១- ជួសជុលថែទាំវ៉ាន់ស្តុប ៧៩កន្លែង
២- ជួសជុលថែទាំវ៉ាន់ខ្យល់ ១០៦គ្រឿង
៣- ជួសជុលថែទាំនាឡិកាតំបន់ ៨៤ គ្រឿង
៤- ជួសជុលថែទាំប៊ូសអាគ្គេ ១២៦ គ្រឿង
៥- ថែទាំប្រព័ន្ធ Telemeter ២៧០លើក
៦- កែសំរួលបំពង់ចែកចាយទឹក ៦.៤៩១ម៉ែត្រ

## ការងារជួសជុលទឹកធ្លាយ

បានជួសជុលទឹកធ្លាយ ២៤ម៉ោង និងចាប់ផ្តើមជួសជុលមិនលើសពី ២ម៉ោងក្រោយពីទទួលពត៌មាន ។

| ករណីលេចធ្លាយ | ចំនួនលេចធ្លាយ ក្នុងឆ្នាំ២០១០ | ចំនួនលេចធ្លាយ បំពង់មេ ឆ្នាំ២០១១ | ចំនួនលេចធ្លាយ បណ្តាញចូលផ្ទះ ឆ្នាំ២០១១ | ចំនួនលេចធ្លាយ សរុប ឆ្នាំ២០១១ | អត្រាធៀប ឆ្នាំ ២០១០ |
|---|---|---|---|---|---|
| គេជីកប៉ះ | ១៧៧ | ៤១ | ១៣៤ | ១៧៥ | ៩៩% |
| បច្ចេកទេស | ១៩៨ | ១១៣ | ២៦៤ | ៣៧៧ | ១៩០% |
| បំពង់ចាស់ | 0 | 0 | 0 | 0 | 0 |
| សរុប | ៣៧៥ | ១៥៤ | ៣៩៨ | ៥៥២ | ១៣៨% |

ទោះជាចំនួនលេចធ្លាយមានការកើនឡើង បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១០ ក៏ រ.ទ.ស.ភ នៅតែបន្តអនុវត្តវិធានការកាត់បន្ថយការលេចធ្លាយ ទាំងលើកគ្គាអត្តនោម័ត និងសត្យានុម័ត ។ ដោយឡែកទាក់ទងនឹងការលេចធ្លាយដោយកត្តាសត្យានុម័ត យើងបានបង្ខំអោយអ្នកបង្កចេញសងការខូចខាត ដែលគិតមកទល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ មានទឹកប្រាក់ចំនួន ១៧,៧២៥,៩៨៨ រៀល ។



## ការគ្រប់គ្រងទឹកបាត់បង់តាមតំបន់

| តំបន់គ្រប់គ្រង | អត្រាកំណត់ | លទ្ធផលរកឃើញ | សរុបក្នុងឆ្នាំ | អត្រាសម្រេចបាន |
|---|---|---|---|---|
| ១- ខណ្ឌ ដូនពេញ | ៥,០០% | - ទឹកធ្លាយចូលលូ | ២១ | ៥,៥១% |
| ២- ខណ្ឌ ៧មករា | ៤,១០% | - ទឹកធ្លាយចូលលូ | ២២ | ៣.០១% |
| ៣- ខណ្ឌ ចំការមន | ៤,៨៥% | - ទឹកធ្លាយចូលលូ | ៤០ | ៦,០៤% |
| ៤- ខណ្ឌ ទួលគោក | ៥,០០% | - ទឹកធ្លាយចូលលូ | ២៨ | ៥,៧៦% |
| ៥- ខណ្ឌ ឫស្សីកែវ | ៣,៥០% | - ទឹកធ្លាយចូលលូ<br>- បទល្មើសបំបែកបណ្តាញ | ១៨<br>០១ | ២,២៩% |
| ៦- ខណ្ឌ មានជ័យ | ៥,២០% | - ទឹកធ្លាយចូលលូ | ១៧ | ៤,១៨% |
| សរុប | | **- ទឹកធ្លាយចូលលូ**<br>**- បទល្មើសបំបែកបណ្តាញ** | **១៤៦**<br>**០១** | |

## ក្រាហ្វិចបង្ហាញពីអត្រាទឹកបាត់បង់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១១ (គិតជាភាគរយ)





# សកម្មភាព និងលទ្ធផល ការងារអាជីវកម្ម ឆ្នាំ២០១១

## តបណ្តាញទឹកជូនអតិថិជន

ក្រោយពីបានរៀបចំបណ្តាញចែកចាយទឹករួច រ.ទ.ស.ភ នឹងប្រកាសជូនដំណឹងដល់ប្រជាពលរដ្ឋឲ្យមកបំពេញបែបបទ តបណ្តាញទឹកចូលផ្ទះរៀងៗខ្លួន ។

ការងារតបណ្តាញទឹកចូលផ្ទះ ត្រូវអនុវត្តតាមបែបបទដំណើរការតាមស្តង់ដារមួយ ដែលមានលក្ខណៈសាមញ្ញ និងងាយអនុវត្តទាំងមន្ត្រី-និយោជិតរបស់ រ.ទ.ស.ភ និងអតិថិជន ។ បណ្តាមន្ត្រី-និយោជិតដែលបំពេញការងារផ្ទាល់ជាមួយអតិថិជន ត្រូវបានអប់រំឲ្យមានអាកប្បកិរិយាសុភាពរាបសារ រម្យទម រាក់ទាក់ ម៉ឺងម៉ាត់ និងជួយសម្រួលការងារតបណ្តាញទឹកចូលផ្ទះឲ្យបានឆាប់បំផុត។

ក្នុងករណីពិសេស ដូចជាការតបណ្តាញទឹកស្អាតជូនប្រជាពលរដ្ឋនៅតាមសគមក្រីក្រ នៅតាមតំបន់ជាយ រាជធានីភ្នំពេញ រ.ទ.ស.ភ បានចល័តមន្ត្រី-និយោជិត ទៅបំពេញការងារនៅសហាគមនោះតែម្តង ។ គោលបំណងចម្បងរបស់ រ.ទ.ស.ភ គឺជួយសម្រួលប្រជាពលរដ្ឋក្នុងការបំពេញបែបបទតបណ្តាញទកឲ្យបានលឿន ទទូលប្រាក់ថ្លៃជាវទឹកនៅនឹងកន្លែង កាត់បន្ថយការចំណាយ លើការធ្វើដំណើររបស់ប្រជាពលរដ្ឋ ។ល។

## ការងារគ្រប់គ្រងអតិថិជន

នៅមុនឆ្នាំ ១៩៩៣ ការគ្រប់គ្រងអតិជនមានកង្វះខាតយ៉ាងខ្លាំង។ ដូចបានរៀបរាប់រួចនៅខាងដើម ចំនួនអតិថិជនក្នុងបញ្ជី ខុសពីចំនួនអតិថិជនពិតប្រាកដយ៉ាងច្រើន ជាងនេះទៅទៀតក្នុងបញ្ជីពុំបានកត់ត្រាអ្នកមានបណ្តាញទឹកទេ តែបែរជាមានឈ្មោះអ្នក ដែលគ្មានបណ្តាណទឹកប្រើប្រាស់ទៅវិញ ។ កត្តានេះទើបធ្វើអោយអត្រាប្រមូលប្រាក់ថ្លៃទឹក នៅពេលនោះមានត្រឹមតែ៤៨% ប៉ុណ្ណោះ។ ដើម្បីកែតំរូវបញ្ជីនេះអោយត្រឹមត្រូវឡើងវិញ ដោយបានស្នើរសុំកំលាំងអន្តរាគមន៍ ប្រមាណ ១០០នាក់ ពីសាលាក្រុងភ្នំពេញជាជំនួយ រ.ទ .ស.ភ បានបើកយុទ្ធនាការអង្កេតអតិថិជនមួយនៅទូទាំងផ្ទៃសេវា ដោយចាប់ផ្តើមនៅក្នុងខែមីនា ឆ្នាំ១៩៩៤ ។ ជាលទ្ធផលនៃយុទ្ធនាការនេះ គឺបានរកឃើញអ្នកមានបណ្តាញទឹកប្រើប្រាស់តែពុំបានកត់ត្រាក្នុងបញ្ជីអតិថិជនចំនួន ១៣.៧២២ អតិថិជន ដោយឡែកក៏បានរកឃើញអ្នកដែលមានឈ្មោះក្នុងបញ្ជីតែជាក់ស្តែងពុំមានបណ្តាញទឹកប្រើប្រាស់ចំនួន ១២.៩៨០អតិថិជន ។ ក្នុងនេះដែរក៏បានរកឃើញអណ្តូងរួមចំនួន ១.៩៤៥ ដោយពុំដែលមានវិក័យបត្រ័ទូទាត់ថ្លៃទឹក (ដោយសារសំពាធទាបនៅពេលនោះដែលទឹកពុំអាចឡើងផុតពីផ្ទៃដី គេបាននាំគ្នាជីកអណ្តូងរួចចោះបំពង់មេចែកចាយទឹក ដើម្បីបង្ហូរទឹកពីបំពង់ចូលទៅក្នុងអណ្តូង ហើយប្រើប្រាស់រួមគ្នាច្រើនគ្រួសារ) ។ ដំណោះស្រាយចំពោះមុខគឺ (ទី១) តំឡើងនាឡិកាមេលើបំពង់ដេលបង្ហូទឹកចូលអណ្តូង រួចចាត់អោយមានតំណាងដើម្បីទូទាត់ថ្លៃទឹក (ទី២) ក្នុងករណីពុំអាចរកតំណាងបានត្រូវរៀបចំបណ្តាញតាមផ្ទះនីមួយៗ ហើយលុបអណ្តូងនេះចេញ ។ អណ្តូងរួមទាំងនេះត្រូវបានលុបបំបាត់ជាបន្តបន្ទាប់ រហូតបញ្ចប់ជាស្ថាពរ នៅក្នុងពេលផ្លាស់ប្តូរបំពង់មេចែកចាយទឹកថ្មី ដោយរៀបចំជាបណ្តាញចូលផ្ទះទាំងអស់ ។

## ការងារគ្រប់គ្រងនាឡិកាទឹក

ការងារគ្រប់គ្រងនាឡិកាទឹកត្រូវបានចែកចេញជា ៣ផ្នែកគឺៈ (១)ការដាក់នាឡិកាទឹក ១០០% មានន័យថាគ្រប់បណ្តាញចូលផ្ទះទាំងអស់ត្រូវតែមាននាឡិកាទឹក (២)ការជ្រើសរើសប្រភេទនាឡិកាដែលមានសុក្រឹតភាពខ្ពស់ និងគុណភាពសមស្រប និង (៣)កម្មវិធីត្រួតពិនិត្យ និងផ្លាស់ប្តូរ ។ នៅឆ្នាំ ១៩៩៣ បណ្តាញទឹកដែលមានបំពក់នាឡិកាស្ទង់មានចំនួន ៣.៣៩១ ដែលស្មើនឹង ១២,៦១%នៃចំនួនបណ្តាញសរុប ហើយការចេញវិក័យបត្រ័ថ្លៃទឹកពេលនោះ ត្រូវបានគណនាបរិមាណទឹកតាមការប៉ាន់ស្មាន ។ នៅឆ្នាំ ១៩៩៤ រ.ទ .ស.ភ បានចាប់ផ្តើមធ្វើការតំឡើងនាឡិកាទឹកជាបន្តបន្ទាប់ លើគ្រប់បណ្តាញចូលផ្ទះ ដែលធ្វើអោយបញ្ឈប់បានទាំងស្រុង នូវការប៉ាន់ស្មានបរិមាណទឹកក្នុងវិក័យបត្រ័ថ្លៃទឹក ។ តារាងខាងក្រោមនេះបង្ហាញពីកំនើននាឡិកាទឹកតាមឆ្នាំនីមួយៗ ធៀបនឹងចំនួនបណ្តាញ ហើយចាប់ពីឆ្នាំ២០០១ ទៅបណ្តាញចូលផ្ទះទាំងអស់មាននាឡិកាទឹក ១០០% ។

# ក- ការងារផ្គត់ផ្គង់ទឹកជូន ប្រជាពលរដ្ឋក្រីក្រ

## លទ្ធផលនៃការតបណ្តាញជូនអតិថិជន

បើគិតចាប់ពីពេលអនុវត្តកម្មវិធី "ផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋក្រីក្រ" រហូតដល់ចុងឆ្នាំ២០១១នេះ រ.ទ.ស.ភ បាន ផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋក្រីក្រសរុប ២៧.៧០៧បណ្តាញស្មើនឹង១៤,៣៧% នៃចំនួនបណ្តាញ ដែលបានតសរុប ។ ក្នុងនោះបានឧបត្ថម្ភធនសរុបចំនួន ១៦.៩៤៨បណ្តាញ ដែលត្រូវចំណាយទឹកប្រាក់សរុប៤.៥៥៣.១៨៧.៨៤៣រ ស្មើនឹង ១.០៣៤.២៨៣,៩១ ដុល្លាអាមេរិក ។




## លទ្ធផលនៃការប្រើប្រាស់គោលការណ៍ឧបត្ថម្ភធន

ក្នុងឆ្នាំនេះ រ.ទ.ស.ភ បានបន្តសកម្មភាពការងារផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋក្រីក្រដោយបានប្រើប្រាស់គោលការណ៍ ឧបត្ថម្ភធនដែលបានមកពីជំនួយឥតសំណងរបស់ទីក្រុងប៉ារីស និងធនាគារពិភពលោក សរុបទឹកប្រាក់ត្រូវចំណាយមានប្រមាណ ២.២១៦.៨០៥.៥៦០រៀល ស្មើនឹង ៥៧១.៦៧៥,២៧ដុល្លាអាមេរិក ដែលសម្រេចបានលទ្ធផលដូចខាងក្រោម៖

## ការវាយតម្លៃ

ការផ្តល់សេវាទឹកស្អាតដល់ប្រជាពលរដ្ឋក្រីក្រ ពិសេសប្រជាពលរដ្ឋក្រីក្ររស់នៅមានលក្ខណៈ ប្រមូលផ្តុំក្នុងសហគមន៍ដែលកន្លង មកមិនធ្លាប់បានទទួលទឹកស្អាតប្រើប្រាស់ផ្ទាល់ពីរដ្ឋ ក្នុងតម្លៃមួយ សមស្របថោកជាងឯកជន ផ្គត់ផ្គង់២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុង១សប្តាហ៍ ធានានូវគុណភាពហូបបាន ផ្ទាល់ពីក្បាលម៉ាស៊ីន និងមានការឧបត្ថម្ភធនផងនោះ បានធ្វើឱ្យប្រជាពលរដ្ឋក្រីក្រទាំងនោះសប្បាយរីករាយ និងដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយ ដែលបានយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅរបស់ពួកគាត់ ។

ការផ្តល់សេវាទឹកស្អាតនេះ បានធ្វើឱ្យប្រជាពលរដ្ឋក្រីក្រ អាចសន្សំសំចៃការចំណាយទៅលើថ្លៃទឹកប្រើប្រាស់បានប្រមាណ ៣០.០០០រៀល ក្នុង១ខែ ឬ ៣៦០.០០០រៀល ក្នុង១ឆ្នាំ ចំណេញពេលវេលាក្នុងការប្រកបមុខរបរប្រចាំថ្ងៃ កុមារៗមានពេលគ្រប់គ្រាន់ក្នុងការរៀនសូត្រ និងកំសាន្តសប្បាយ ហើយសុខភាពកាន់តែធានាល្អប្រសើរឡើង ដោយបានកាត់បន្ថយជម្ងឺផ្សេងៗ ដូចជា កមរមាស់ និងគ្រុនពោះវៀនជាដើម។



| តបណ្តាញជូនប្រជាពលរដ្ឋក្រីក្រ | | សរុប (គ្រួសារ) | ក្នុងក្រុង (គ្រួសារ) | ជាយក្រុង (គ្រួសារ) |
|---|---|---|---|---|
| | បង់រំលស់ ១២ខែ | ០៥ | ០ | ០៥ |
| ឧបត្ថម្ភធន ៣០% | និង បង់រំលស់ ១២ខែ | ០៨ | ០ | ០៨ |
| ឧបត្ថម្ភធន ៥០% | និង បង់រំលស់ ១២ខែ | ២៨២ | ១៧៩ | ១០៣ |
| ឧបត្ថម្ភធន ៧០% | និង បង់រំលស់ ១២ខែ | ៥៨៨ | ៣៤ | ៥៥៤ |
| ឧបត្ថម្ភធន ១០០% | និង បង់រំលស់ ០៨ខែ | ៥.២៧២ | ៣១ | ៥.២៤១ |
| | សរុប | ៦.១៥៥ | ២៤៤ | ៥.៩១១ |

# ខ- ការងារតបណ្តាញចូលផ្ទះ និង ការគ្រប់គ្រងអតិថិជន

## ការងារតបណ្តាញចូលផ្ទះ

ក្នុងឆ្នាំនេះ យើងតបណ្តាញជូនអតិថិជនបានលើសផែនការ ១១២,១៤% ប៉ុន្តែចំណូលថ្លៃបណ្តាញ អនុវត្តលើសផែនការតែ ១០៥,៨១% ប៉ុណ្ណោះ ដោយសារកត្តាថ្លៃ ។ ជាក់ស្តែង ថ្លៃបណ្តាញជាមធ្យមស្មើ ៣៤១.៧២៦រៀល ទាបជាងផែនការ ៣៥២.២៤៤រៀល ស្មើនឹង៣,០៨% ។ ដែលជាលទ្ធផលមានដូចខាងក្រោម៖

- តបណ្តាញចូលផ្ទះបាន ១៧.៨២០បណ្តាញ ស្មើនឹង២១២,១៤% នៃផែនការ ៨.៤០០បណ្តាញ ។
- ចំណូលតបណ្តាញមាន ៦.០៨៩.៥៥០.៣៧៤រៀល ស្មើនឹង ២០៥,៨១% នៃផែនការ ២.៩៥៨.៨៤៩.៦០០រៀល ។

## ការងារគ្រប់គ្រងអតិថិជន

- ចំនួនអតិថិជនសរុបដើមគ្រា ២០២.៩២៩ អតិថិជន
- កំណើនក្នុងគ្រា ១៦.៥៦៩ អតិថិជន
- ចំនួនអតិថិជនសរុបចុងគ្រា ២១៩.៤៩៨ អតិថិជន ស្មើនឹង ១០៤,៨៧% នៃផែនការ ២០៩.៣០០ អតិថិជន ។

យើងគ្រប់គ្រងអតិថិជនបានល្អ និងមានប្រសិទ្ធិភាពដោយ ៖

- បញ្ចូលទិន្នន័យអតិថិជនតបណ្តាញថ្មី និងទិន្នន័យនាឡិកាប្តូរថ្មីទៅក្នុងប្រព័ន្ធបានត្រឹមត្រូវ និងទាន់ពេលវេលា " **មិនលើសពីបីថ្ងៃការងារក្រោយថ្ងៃតបណ្តាញ និងប្តូរនាឡិការួច** " ។
- បញ្ចូលរាល់សំណើកែតម្រូវទិន្នន័យអតិថិជនទៅក្នុងប្រព័ន្ធទាន់ពេលវេលា ។
- ធ្វើ Back Up ទុករាល់ថ្ងៃ និងសប្តាហ៍ ទិន្នន័យអតិថិជននៅក្នុងប្រព័ន្ធ ដើម្បីធានាសុវត្ថិភាពដោយធ្វើការត្រួតពិនិត្យនៅរាល់ចុងត្រីមាសទៀតផង ។
- ធ្វើការថែទាំកុំព្យូទ័រ និង Hardware ទូទាំងអង្គភាពតាមកម្មវិធីដែលបានកំណត់ ។

| ប្រភេទអតិថិជន | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|---|---|
| ជីវភាព | ១០៥.៩៨១ | ១២១.៤២៦ | ១៣២.២៨៧ | ១៤០.៧២៨ | ១៥២.៩៧២ | ១៦១.៥៤៥ | ១៦៩.៧០០ | ១៨៣.៦៩៤ |
| អាជីវកម្ម | ១៤.៩៦៤ | ១៦.២០៩ | ១៨.៧៨៥ | ២០.៧៤៤ | ២៤.៥២២ | ២៨.៨១៩ | ៣២.៤៦៧ | ៣៥.០០១ |
| អង្គភាពរដ្ឋ | ៥៥៩ | ៦១៤ | ៦៣៥ | ៦៥៩ | ៦៩៣ | ៧១៨ | ៧៤១ | ៧៨២ |
| តំណាងចែកចាយ | ១៨ | ១៧ | ១៧ | ២០ | ១៣ | ១០ | ២១ | ២១ |
| សរុប | ១២១.៥២២ | ១៣៨.២៦៦ | ១៥១.៧២៤ | ១៦២.១៥១ | ១៧៨.២០០ | ១៩១.០៩២ | ២០២.៩២៩ | ២១៩.៤៩៨ |

## ក្រាហ្វិចបង្ហាញពីបំណែងចែកអតិថិជន ឆ្នាំ២០១១ (អតិថិជនសរុបចំនួន:២១៩.៤៩៨អតិថិជន)



# គ- ចំណូលថ្លៃទឹក និង ការងារជួសជុល ប្តូរនាឡិកាទឹក

## គ.១- ចំណូលថ្លៃទឹក

ដើម្បីធានាប្រសិទ្ធិភាព និង ទិន្នផលកាន់តែល្អប្រសើរ លើការងារប្រមូលប្រាក់ថ្លៃទឹកប្រើប្រាស់ពីអតិថិជន យើងបានបន្តអនុវត្តយន្តការអានមួយថ្ងៃបោះពុម្ពវិក្កយបត្រមួយថ្ងៃ ។ ទន្ទឹមនោះយើងបានបន្តដំណើរការ សាខាទទួលប្រាក់ថ្លៃទឹកចំនួនបួនកន្លែងនៅតាមអាងតម្កល់ទឹកជាយក្រុងទាំងបី និងនៅតាខ្មៅ សំដៅបង្កភាពងាយស្រួលដល់ការទូទាត់ប្រាក់ថ្លៃទឹករបស់អតិថិជន ក៏ដូចជាកាត់បន្ថយការចំណាយ ក្នុងការធ្វើដំណើររបស់អតិថិជនផងដែរ ។ ពិសេសជាងនេះទៅទៀត យើងបានសហការជាមួយបណ្តា ធនាគារ និងក្រុមហ៊ុន ដាក់ឲ្យដំណើរការសេវាកម្មទទួលប្រាក់ថ្លៃទឹកតាមបច្ចេកវិទ្យាទំនើបថែមទៀត ។ ដែលជាក់ស្តែងក្នុងឆ្នាំនេះ៖

- ចំនួនទឹកប្រាក់ប្រកាសក្នុងវិក្កយបត្រ មានប្រមាណ ១០២.៩៧៩.៥២៦.៤៩៧រៀល ស្មើនឹងបរិមាណទឹក ១០២.៨៨៣.៨១៥ម៣ ត្រូវជា ៩៤,១៥% នៃបរិមាណផលិតផលទឹកស្អាត ១០៩.២៧៦.៥២១ម៣ និងត្រូវជា ១០០,២៤% នៃផែនការ ១០១.៦៦៣.៣៦៤.១០០រៀល ។
- ចំណូលថ្លៃទឹកទារបានស្មើនឹង ៩៩,៨៨% នៃទឹកប្រាក់ប្រកាសក្នុងវិក្កយបត្រ ។

បរិមាណទឹកលក់ក្នុងឆ្នាំ លើសផែនការ ០,៣១% ដោយសារបរិមាណទឹកប្រើប្រាស់ជាមធ្យម ក្នុងមួយបណ្តាញក្នុងមួយខែ (៣៩,៦៩ម៣/ប.ណ x ខែ) ទាបជាងផែនការ -២,២២% ប៉ុន្តែចំនួនបណ្តាញ ជាមធ្យមលើសផែនការ ២,៥៧% ។

ទឹកប្រាក់ប្រកាសលក់លើសផែនការ០,៤៥% ដោយសារបរិមាណទឹកលក់លើសផែនការ ០,៣១% ហើយថ្លៃលក់ជាមធ្យម ១.០០០,៩៣រៀល/ម៣ លើសផែនការ ៩៩៩,៥៣រៀល/ម៣ ។

### ក្រាហ្វិចបង្ហាញពីចំណូលថ្លៃទឹកទារបានស្មើនឹង ៩៩,៩២% ក្នុងឆ្នាំ២០១១




## គ.២- ការងារជួសជុល និងប្តូរនាឡិកាទឹក

តាមរយៈការដោះដូរនាឡិកានេះ យើងបានរំលឹកបរិមាណទឹកលម្អៀង បញ្ចូលទៅក្នុងវិក្កយបត្រ ៥៨.៨៣៦ម៣ ចំពោះនាឡិកាខូច ២.៦១២គ្រឿង និងនាឡិកាបាត់ ១៤២គ្រឿង និង ៣០.៦៣២ម៣ ចំពោះនាឡិកាដើរយឺត លើសកម្រិតកំណត់ ១.១០៤ គ្រឿង ។

- ដោះដូរនាឡិកាទឹក ៤.១០១ គ្រឿង ស្មើនឹង ១១៧,១៧% នៃផែនការ ៣.៥០០ គ្រឿង ។
- ជួសជុលនាឡិកា ៣.០៥០គ្រឿង ស្មើនឹង១២២% នៃផែនការ ២.៥០០ គ្រឿង ។

ការដោះដូរនាឡិកាអនុវត្តលើសផែនការដោយសារ ចំនួននាឡិកាខូច និងបាត់ មានច្រើនជាងការគ្រោងទុក ។ ដោយឡែក ការជួសជុលនាឡិកាសម្រេចលើសផែនការ ដោយសារយើងប្រើប្រាស់រូបភាពមៅការ និងបានបង្កើនម៉ោងវាស់ស្ទង់បន្ថែមទៀត ។



ទិដ្ឋភាពអាងតម្កល់ទឹកពោធិ៍ចិនតុង និងបញ្ជរបង់ប្រាក់




PPWSA - Navision Attain - [Main Menu]
File Edit View Tools Window Help
General Ledger
Fixed Assets
Sales & Receivables
Purchases & Payables
Inventory
Resources
Jobs
Human Resources
Payroll
Water Billing
House Connection
Help
NAVISION ATTAIN
ATTAIN
start
3 Microsoft Office ...
Adobe Photoshop CS...
PPWSA - Navision At...



# របាយការណ៍លទ្ធផលការងារហិរញ្ញវត្ថុ នៅការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១

(មិនបានធ្វើសវនកម្ម)

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការធានាថា របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋាករទឹក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលបាន ៖

១- អនុវត្តគោលការណ៍គណនេយ្យដែលសមស្រប ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS" ) ដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់២ នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុសមផល ហើយបន្ទាប់មកត្រូវអនុវត្តវាជាប្រចាំ ។

២- គោរពតាមតម្រូវការរបស់តាមស្តង់ដារគណនេយ្យកម្ពុជា ក្នុងការលាតត្រដាងព័ត៌មាន ហើយប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញអោយមានភាពពិត និងត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណមួយដែលសមស្រប នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

៣- ថែរក្សាបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលមានប្រសិទ្ធិភាព។

៤- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាព លើកលែងតែមានកាសន្មតថា រដ្ឋាករទឹកមិនមានលក្ខណៈសមស្រប ក្នុងការបន្តប្រតិបត្តិការនៅពេលអនាគត ដែលអាចប៉ាន់ស្មានបាន និង

៥- គ្រប់គ្រង និងដឹកនាំរដ្ឋាករទឹកអោយមានប្រសិទ្ធភាព និងចូលរួមរាល់ការសម្រេចចិត្តលើបញ្ហាសំខាន់ៗទាំងអស់ ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផល និងធានាថាការសម្រេចចិត្តទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

សមាជិកក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានសមាសភាពដូចខាងក្រោម:

- តំណាងមួយរូបពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តំណាងមួយរូបពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- តំណាងមួយរូបពីសាលារាជធានីភ្នំពេញ
- តំណាងមួយរូបពីក្រសួងមហាផ្ទៃ
- តំណាងមួយរូបពីទីស្តីការគណៈរដ្ឋមន្ត្រី
- តំណាងមួយរូបជាអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- តំណាងមួយរូបពីតំណាងនិយោជិតនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

តាងនាមអោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ យើងខ្ញុំសូមធានាអះអាងថា របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ដែលភ្ជាប់មកជាមួយនេះ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុ របស់រដ្ឋាករទឹក គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅស្របតាមស្តង់ដារគណនេយ្យកម្ពុជា ។

# ក- របាយការណ៍លទ្ធផលការងារហិរញ្ញវត្ថុ

## ក.១- តារាងតុល្យការ

(នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១)

| បរិយាយ | កំណត់សម្គាល់ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|---|
| **ទ្រព្យសកម្ម** | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ៦៣២.៣៨៥.៧៤៧ | ៥៤១.៣២១.០៤៧ |
| ទ្រព្យសកម្មអរូបី | ៦ | ១.០៣៣.៩០៤ | ៩៩៦.៨០១ |
| ឥណទានផ្តល់អោយរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៨ | ៦៩៧.៦០៩ | ៧៦៨.២៦៦ |
| **ទ្រព្យសកម្មរយៈពេលវែង(សរុប)** | | ៦៣៤.១១៧.២៥៩ | ៥៤៣.០៨៦.១១៤ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | |
| សន្និធិ | ១០ | ២៨.០៨៨.៥៧១ | ២០.១៧៦.៨១០ |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិ.ផ្សេងៗ | ១១ | ៤៣.៧១៦.០៤១ | ៤៤.៣៧៦.៥០៤ |
| កម្ចីទៅអោយរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៨ | ៦៨.០០៤ | ៥០.១៤៩ |
| ពន្ធលើប្រាក់ចំណេញត្រូវទទួល | ៩ | (៤៣៧.៦៦៤) | ១.៦៤៣.៨១៨ |
| ការវិនិយោគរយៈពេលខ្លី | ១២ | ១៥១.៧៩៩.៩២៧ | ១២៩.៦៩៧.១៣៥ |
| សាច់ប្រាក់និងសាច់ប្រាក់សមមូល | ១៣ | ៧.៤៦០.៨២១ | ៧.០៦៦.៧៥២ |
| **ទ្រព្យសកម្មរយៈពេលខ្លី(សរុប)** | | **២៣០.៦៩៥.៧០០** | **២០៣.០១១.១៦៩** |
| **ទ្រព្យសកម្ម (សរុប)** | | **៨៦៤.៨១២.៩៥៩** | **៧៤៦.០៩៧.២៨៣** |
| **មូលធន និង បំណុល** | | | |
| ដើមទុន | ១៤ | ៤៦៥.០២៨.១២៩ | ៤៥៦.០០០.២៦៤ |
| ទុនបម្រុង | ១៥ | ៥៥.៤១០.៤៤៥ | ២៩.០៦០.៩៥៧ |
| ចំណេញរក្សាទុក | | ៣១.៩៨៩.៩០៧ | ៣០.៥០៦.៣៥២ |
| **មូលធនសរុប** | | ៥៥២.៤២៨.៤៨១ | ៥១៥.៥៦៧.៥៧៣ |
| **បំណុល** | | | |
| **បំណុលរយៈពេលវែង** | | | |
| កាតព្វកិច្ចសោធននិវត្តន៍ | ១៨ | ២៤.៦០១.០២៨ | ២០.៣៤៧.៨១៧ |
| បំណុលពន្ធពន្យារលើប្រាក់ចំណេញ | ១៧ | ១៦.៩៣៥.៧០៩ | ១៥.២៧៩.៤៨០ |
| ប្រាក់កម្ចី | ១៦ | ១៨២.៨៤៧.៤៦៣ | ១២៩.២៥៥.៣៧៧ |
| ប្រាក់កក់របស់អតិថិជន | | ២៤.៦០២.០៨៧ | ២១.៨៥៤.៧៣៨ |
| ជំនួយពន្យារពីរាជរដ្ឋាភិបាល និងជំនួយផ្សេងៗ | ១៩ | ៧.៥៣៥.៦៦៧ | ១៦.៧៧៥.៥៨៤ |
| **បំណុលរយៈពេលវែង(សរុប)** | | **២៥៦.៥២១.៩៥៣** | **២០៣.៥១២.៩៩៦** |
| **បំណុលរយៈពេលខ្លី** | | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងផ្សេងៗ | ២០ | ៤៤.៣៥៨.១១១ | ១៨.២៥៧.៨៣០ |
| ប្រាក់កម្ចី | ១៦ | ១១.៥០៤.៤១៣ | ៨.៧៥៨.៨៨៤ |
| **បំណុលរយៈពេលខ្លី(សរុប)** | | ៥៥.៨៦២.៥២៤ | ២៧.០១៦.៧១៤ |
| **បំណុល(សរុប)** | | ៣១២.៣៨៤.៤៧៧ | ២៣០.៥២៩.៧១០ |
| **មូលធន និង បំណុល (សរុប)** | | **៨៦៤.៨១២.៩៥៩** | **៧៤៦.០៩៧.២៨៣** |

# ក.២- របាយការណ៍លទ្ធផល

(នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១)

| បរិយាយ | កំណត់សម្គាល់ | ៣១/១២/២០១១ *(គិតជាពាន់រៀល)* | ៣១/១២/២០១០ *(គិតជាពាន់រៀល)* |
|---|---|---|---|
| **ចំណូល** | | | |
| ការលក់ | ២១ | ១១៤.៨៦៨.២៧៩ | ១០៥.៥៤៣.៥៤០ |
| ចំណូលផ្សេងៗ | | ២១២.០៥២ | ៧២២.៣៧៣ |
| ចំណូល (សរុប) | | **១១៥.០៨០.៣៣១** | **១០៦.២៦៥.៩១៤** |
| **ចំណាយផ្សេងៗ** | | | |
| ចំណាយរំលស់ និង អរូបី | ៥&៦ | (២១.២៣៩.៩៩០) | (២០.៥៣៦.២៦១) |
| ចំណាយថ្លៃអគ្គីសនី | | (២២.៨០៩.៦៩៨) | (២១.២២៣.៣០១) |
| ចំណាយលើប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយទាក់ទិន | ២៣ | (១៨.៩៧១.៣៣៧) | (១៧.១៣១.៩០៧) |
| វត្ថុធាតុដើមសម្រាប់ផលិតទឹក | ២២ | (៩.៩៦២.២៥០) | (៩.១១១.៩៣៨) |
| ថ្លៃដើមសំភារ:សំរាប់តភ្ជាប់បណ្តាញទៅគេហដ្ឋាន | ២៤ | (៥.១២៦.៨៦៣) | (៣.៦៨៦.០៣៨) |
| ចំណាយលើការជួសជុល និងថែទាំ | | (២.៩០៧.០២៩) | (៣.២៣១.១២៥) |
| ចំណាយប្រតិបត្តិការផ្សេងៗ | | (២.៧០៩.២៩៣) | (២.៨០៩.១៧០) |
| ចំណេញ/ខាតពីការប្តូររូបិយប័ណ្ណ-សុទ្ធ | ២៥ | ២.៣៩០.៨១២ | ២.៦៩៧.៧៨៣ |
| ចំណាយផ្សេងៗ (សរុប) | | **(៧៥.៨៨៥.០៩៨)** | **(៧០.០៣៦.៩៥៣)** |
| ចំណេញពីប្រតិបត្តិការ | | ៣៩.១៩៥.២៣២ | ៣៦.២២៩.៩៦០ |
| ចំណូល/(ចំណាយ) ហិរញ្ញវត្ថុ - សុទ្ធ | | ៨៦១.៥៦២ | ១.៩៤៨.១១៨ |
| ចំណេញសុទ្ធមុនបង់ពន្ធ | | ៤០.០៥៦.៧៩៤ | ៣៨.១៧៧.៥៧៨ |
| ពន្ធលើប្រាក់ចំណេញ | ២៦ | (៨.០៦៦.៨៨៦) | (៧.៦៧១.២២៦) |
| **ចំណេញពិតសំរាប់ឆ្នាំ** | | **៣១.៩៨៩.៩០៧** | **៣០.៥០៦.៣៥២** |

# ក.៣- របាយការណ៍បម្រែបម្រួលមូលធន

(នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១)

| បរិយាយ | កំណត់សម្គាល់ | ដើមទុន *(គិតជាពាន់រៀល)* | ប្រាក់បំរុង *(គិតជាពាន់រៀល)* | ចំណេញរក្សាទុក *(គិតជាពាន់រៀល)* | សរុប *(គិតជាពាន់រៀល)* |
|---|---|---|---|---|---|
| ៣១/១២/២០១០ | | | | | |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១០ | | ៤៥៦.០០០.២៦៤ | ៥.៣៩៧.៣៣២ | ២៦.៩៣៣.៧៣៤ | ៤៨៨.៣៣១.៣៣០ |
| ផ្ទេរទៅមូលនិធិបំរុង | | - | ២៦.៩៣៣.៧៣៤ | (២៦.៩៣៣.៧៣៤) | - |
| ប្រាក់ចំណេញផ្ទេរជូនរាជរដ្ឋាភិបាល | | - | (២.៦៩៣.៣៧៤) | - | (២.៦៩៣.៣៧៤) |
| ផ្ទេរចេញពីមូលនិធិបំរុង (បំរើសង្គម) | | - | (៥៧៦.៧៣៥) | - | (៥៧៦.៧៣៥) |
| ចំណេញពិតក្នុងឆ្នាំ | | - | - | ៣០.៥០៦.៣៥២ | ៣០.៥០៦.៣៥២ |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | **៤៥៦.០០០.២៦៤** | **២៩.០៦០.៩៥៧** | **៣០.៥០៦.៣៥២** | **៥១៥.៥៦៧.៥៧៣** |
| ៣១/១២/២០១១ | | | | | |
| នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១១ | | ៤៥៦.០០០.២៦៤ | ២៩.០៦០.៩៥៧ | ៣០.៥០៦.៣៥២ | ៥១៥.៥៦៧.៥៧៣ |
| ផ្ទេរទៅមូលធន | | ៩.០២៧.៨៦៥ | - | - | ៩.០២៧.៨៦៥ |
| ផ្ទេរមូលនិធិបំរុង | | - | ៣០.៥០៦.៣៥២ | (៣០.៥០៦.៣៥២) | - |
| ប្រាក់ចំណេញផ្ទេរជូនរាជរដ្ឋាភិបាល | | - | (៣.០៥០.៦៣៥) | - | (៣០.០៥០.៦៣៥) |
| ផ្ទេរចេញពីមូលនិធិបំរុង (បំរើសង្គម) | | - | (១.១០៦.២២៩) | - | (១.១០៦.២២៩) |
| ចំណេញពិតក្នុងឆ្នាំ | | - | - | ៣១.៩៨៩.៩០៧ | ៣១.៩៨៩.៩០៧ |
| ចំណាយរៀបចំ IPO | | - | - | - | - |
| **នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | | **៤៦៥.០២៨.១២៩** | **៥៥.៤១០.៤៤៥** | **៣១.៩៨៩.៩០៧** | **៥៥២.៤២៨.៤៨១** |

# ក.៤- របាយការណ៍លំហូរសាច់ប្រាក់

(នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១)

| **បរិយាយ** | **កំណត់សម្គាល់** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---|---|---|
| **លំហូរសាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ** | | | |
| - សាច់ប្រាក់បានមកពីប្រតិបត្តិការ | ២៧ | ៨៥.១៨០.១៧៩ | ៤០.១០២.២០២ |
| - ការប្រាក់បានបង់ | | (៤.៤៨១.២៧៨) | (៤.២៨៤.៣៨៥) |
| - ពន្ធបានបង់ | | (៤.៣២៩.១៧៤) | (៥.៩១១.១៩៧) |
| - កាតព្វកិច្ចសោធននិវត្តន៍ដែលបានបង់ | | (៣៥២.៨៦៥) | (៤១១.៩៩៩) |
| **សាច់ប្រាក់សុទ្ធបានមកពីសកម្មភាពប្រតិបត្តិការ** | | ៧៦.០១៦.៨៦២ | ២៩.៤៩៤.៧១១ |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពវិនិយោគ** | | | |
| - ទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | (១១២.១៦៩.៦៧០) | (២៣.៤៧៥.៥៧៣) |
| - ទិញទ្រព្យសម្បត្តិអរូបី | | (២៧១.៨១៥) | (៤២៤.៦៨០) |
| - សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខា | | - | - |
| - កំចីដែលបានបង់សងដោយរដ្ឋាករទឹកខេត្តពោធិ៍សាត់ | | ៥២.៨០៣ | ៦២.៧៥៨ |
| - ការវិនិយោគរយៈពេលខ្លី | | (២២.១០២.៧៩២) | (២៨.៣៨១.០១៣) |
| - ការប្រាក់ទទួលបាន | | ៦.៦៨២.៩២៩ | ៦.៤២០.៩២០ |
| **សាច់ប្រាក់សុទ្ធដែលបានប្រើក្នុងសកម្មភាពវិនិយោគ** | | (១២៧.៨០៣.៥៤៥) | (៤៥.៧៩៧.៥៨៨) |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាពហិរញ្ញប្បទាន** | | | |
| - ប្រាក់ចំណេញដែលបានបង់ជូនរាជរដ្ឋាភិបាលកម្ពុជា | | (៣.០៥០.៦៣៥) | (២.៦៩៣.៣៧៣) |
| - ការបែងចែកទុនបម្រុងសម្រាប់សកម្មភាពសង្គម | | (១.១០៦.២២៩) | (៥៧៦.៧៣១) |
| - ប្រាក់ទទួលបានពីកម្ចី | | ៦៦.១៥០.០២៤ | ២៩.១៦៧.៤៣៩ |
| - ការបង់សងប្រាក់កម្ចី | | (៩.៨១២.៤០៩) | (១១.៧៨៥.០៥៤) |
| **សាច់ប្រាក់សុទ្ធដែលបានប្រើប្រាស់ក្នុងសកម្មភាពហិរញ្ញប្បទាន** | | ៥២.១៨០.៧៥១ | ១៤.១១២.២៨១ |
| **តំហាយសុទ្ធនៃសាច់ប្រាក់ និងបេឡាសមមូល** | | **៣៩៤.០៦៨** | **(២.១៩០.៥៩៦)** |
| - បេឡា និងសាច់ប្រាក់សមមូល នៅដើមឆ្នាំ | | ៧.០៦៦.៧៥២ | ៩.២៥៧.៣៤៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅចុងឆ្នាំ** | | **៧.៤៦០.៨២១** | **៧.០៦៦.៧៥២** |



# ខ- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ខ.១- ព័ត៌មានទូទៅ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ហៅកាត់ថា "រដ្ឋាករទឹក" ) ជាគ្រឹស្ថានសាធារណៈស្វយ័ត ដែលស្ថិតក្រោមការគ្រប់គ្រងបច្ចេកទេសរបស់សាលារាជធានីភ្នំពេញ និងស្ថិតនៅក្រោមការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យកណ្តាលនៅភ្នំពេញ ។ អនុលោមតាមមាត្រា២៦ នៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ថានភាពឧបសម្ព័ន្ធសេដក្ខកិច្ចរបស់រដ្ឋាករទឹក ជាប្រភេទសហគ្រាសសាធារណៈ ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ជានីតិអង្គភាពស្វយ័តផ្នែករដ្ឋាបាល និងហិរញ្ញវត្ថុ ។ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបានបង្កើតឡើងដោយអនុលោមតាម អនុក្រិត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានចុះហត្ថលេខា និង ចេញដោយនាយករដ្ឋមន្ត្រីទាំងពីរនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅពេលនោះ ។

អនុលោមតាមអនុក្រិតលេខ១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៤ បច្ចុប្បន្នេះរដ្ឋាករទឹកស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ហើយមិនស្ថិនៅក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញទៀតទេ។

យោងតាមអនុក្រឹត្យលេខ៥២ ស្តីពីការបង្កើតរដ្ឋាករទឹក បេសកកម្មរបស់រដ្ឋាករទឹកគឺការផលិត និងចែកចាយទឹកស្អាតសម្រាប់ការប្រើប្រាស់ទូទៅរបស់សាធារណជននៅរាជធានីភ្នំពេញ ។ ដើម្បីបំពេញបេសកកម្មនេះ រដ្ឋាករទឹកត្រូវបានអនុញ្ញាតអោយ អនុវត្តសកម្មភាពប្រតិបត្តការលើទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ព្រមទាំងប្រតិបត្តិការពាណិជ្ជកម្ម និង ហិរញ្ញវត្ថុចាំបាច់ផ្សេង ទៀតដូចជា៖

- ការផលិត និងការចែកចាយទឹកនៅក្រុងភ្នំពេញទាំងមូល និងនៅជាយក្រុង
- ការពង្រីក កែលម្អ និងការស្តាបនាប្រព័ន្ធផលិតកម្ម និង បណ្តាញចែកចាយ និង
- ប្រកបអាជីវកម្មលើបណ្តាញចែកចាយទឹកដែលមានស្រាប់ និងបណ្តាញចែកចាយទឹកនាពេលអនាគត ។

យោងទៅតាមលិខិតលេខ ៨០២ យរត.តស ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៤ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បាន យល់ព្រមផ្ទេរនូវប្រតិបត្តិការ និងទ្រព្យសកម្មរបស់រដ្ឋាករទឹកក្រុងតាខ្មៅ ទៅអោយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញគ្រប់គ្រង ។

ការិយាល័យរបស់រដ្ឋាករទឹកស្ថិតនៅខាងជើងស្ថានីយ៍រាជាយស្ម័យយានកម្ពុជា, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា ។

# ខ.២- សេចក្តីសង្ខេបពីគោលនយោបាយគណនេយ្យចំបងៗ

គោលការណ៍គណនេយ្យចំបងៗ ដែលបានប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះគឺមានដូចខាងក្រោម ។ គោលការណ៍ទាំងនេះត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នា គ្រប់កាលបរិច្ឆេទដែលបានបង្ហាញជូនទាំងអស់ លើកលែងតែមានការ បញ្ជាក់ផ្សេងពីនេះ ។

## ខ២.១- មូលដ្ឋាននៃការរៀបចំ

របាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹក ដែលបានបង្ហាញជាប្រាក់រៀលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") រួមមានស្តង់ដារគណនេយ្យកម្ពុជាចំនួន១៨ និង ស្តង់ដាររបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុនៃកម្ពុជា (ហៅកាត់ថា "CFRS") ចំនួនពីរ ។ ស្តង់ដារទាំងនេះត្រូវបានប្រកាសចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមប្រកាសលេខ ២២១ ស.ហ.វ/ប្រ.ក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ។

រដ្ឋាករទឹកបានជ្រើសរើស ប្រើប្រាស់ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") មួយចំនួនដូចខាងក្រោមមុនកាលកំណត់ដែលមានប្រសិទ្ធភាពសម្រាប់ការិបរិច្ឆេទគណនេយ្យ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ ២០១២ ឬ ការិយបរិច្ឆេទបន្ទាប់ពីនេះ ។

- CIAS 19 ស្តីអំពី អត្ថប្រយោជន៍និយោជិត
- CIAS 23 (កែសម្រួល) ស្តីពីបន្ទុកប្រាក់កម្ចី
- CIAS 34 ស្តីពី របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងដោយភ្ជាប់នឹងនិតិវិធីដែលបានរៀបចំឡើងសំរាប់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Initial Public Offering) នៃភាគហ៊ុនរបស់រដ្ឋាករទឹកលើផ្សារមូលបត្រកម្ពុជា ។ គោលការណ៍គណនេយ្យដែលត្រូវប្រើប្រាស់ អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យ ដែលត្រូវបានគេទទួលស្គាល់ និង ប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និង យុត្តាធិការផ្សេងៗ ។

របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលនៃប្រតិបត្តិការ និង លំហូរសាច់ប្រាក់ ដោយអនុលោមតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជាទេ ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះសម្រាប់បង្ហាញចំពោះអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និង ការអនុវត្តនៅក្នុងព្រះរាជា-ណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រសន្មតថ្លៃដើម ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របតាម CAS តម្រូវអោយប្រើប្រាស់ការប៉ាន់ស្មាន និង ការសន្មតដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និង បំណុល និង ការលាតត្រដាងទ្រព្យសកម្ម និង បំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ និង ចំនួននៃចំណូល និង ចំណាយដែលបានរាយការណ៍ នៅក្នុងអំឡុងពេលនៃការិយបរិច្ឆេទរាយការណ៍នេះ ។ បើទោះជាការប៉ាន់ស្មានទាំងនេះ ផ្អែកលើការយល់ដឹងដ៏ល្អសុក្រឹតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និង សកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកំរិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានដែលមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ។ (ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ខ៤)

## ខ២.២- ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយ

●●●●● ស្តង់ដារគណនេយ្យថ្មីៗ និង វិសោធនកម្មលើស្តង់ដាដែលមានស្រាប់ដែលបានចេញផ្សាយ និង ចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ហើយរដ្ឋាករទឹកមិនបានអនុវត្តមុនកាលកំណត់:

*CIAS 1 (កែសម្រួល) ស្តីពី "ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ"*

CIAS 1 (កែសម្រួល) មិនអនុញ្ញាតអោយបង្ហាញគណនីខ្លះនៃចំណូល និង ចំណាយ (បម្រែបម្រួលមូលធន ដែលមិនមែនជារបស់ម្ចាស់ទ្រព្យ) នៅក្នុងរបាយការណ៍បម្រែបម្រួលមូលធនម្ចាស់ទ្រព្យ ដែលតម្រូវអោយបង្ហាញបម្រែបម្រួលមូលធនមិនមែនជារបស់ម្ចាស់ទ្រព្យដាច់ដោយឡែកពីបម្រែបម្រួលមូលធនម្ចាស់ទ្រព្យ ។ រាល់ប្រតិបត្តិការបម្រែបម្រួលមូលធន ដែលមិនមែនជាម្ចាស់ទ្រព្យ ត្រូវបង្ហាញក្នុងលទ្ធផលលំអិតផ្សេងៗ ។

ប៉ុន្តែអង្គភាពអាចជ្រើសរើសក្នុងការបង្ហាញរបាយការណ៍លទ្ធផលពេញលេញមួយ រឺ របាយការណ៍ពីរ (គឺ របាយការណ៍លទ្ធផលមួយ និង របាយការណ៍ពេលលេញមួយ) ។នៅពេលអង្គភាពរាយការណ៍រឺចាត់ ថ្នាក់ព័ត៌មានប្រៀបធៀប ឡើងវិញ អង្គភាពនោះនឹងត្រូវបង្ហាញរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដែលរាយការណ៍ឡើងវិញ នៅថ្ងៃចាប់ផ្តើមនៃការិយបរិច្ឆេទប្រៀបធៀបនោះ បន្ថែមលើតម្រូវការបច្ចុប្បន្ន ក្នុងការបង្ហាញរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅថ្ងៃដំណាច់ការិយបរិច្ឆេទ បច្ចុប្បន្ន និង ការិយច្ឆេទប្រៀបធៀប ។ នៅពេលអនុវត្តស្តង់ដារនេះនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ រដ្ឋាករទឹកទំនងជាធ្វើរបាយការណ៍លទ្ធផលទាំងពីរ គឺរបាយការណ៍លទ្ធផល និង របាយការណ៍លទ្ធផលពេញលេញ នៅក្នុងរបាយការណ៍លទ្ធផលតែមួយ ។

ជាងនេះទៅទៀត CIAS 1 (កែសម្រួល) បញ្ជាក់ថាការទូទាត់បំណុល ដោយការចេញផ្សាយដើមទុន មិនពាក់ព័ន្ធទៅនឹងការធ្វើចំណាត់ថ្នាក់បំណុលនោះ ជាបំណុលរយៈពេលវែង រឺ ខ្លីនោះទេ ។ យោងតាមការកែសម្រួលនិយមន័យបំណុលរយៈពេលខ្លី ការកែសម្រួលអាចអោយចាត់ថ្នាក់បំណុល ជាបំណុលរយៈពេលវែង (ក្នុងករណីដែលអង្គភាពមានសិទ្ធិដោយឥតលក្ខខណ្ឌ ក្នុងការពន្យាពេលទូទាត់បំណុល ដោយការផ្ទេរសាច់ប្រាក់ ឬទ្រព្យសកម្ម ដ៏ទៃទៀត ក្នុងរយៈយ៉ាងហោចណាស់១២ខែ បន្ទាប់ពីការិយបរិច្ឆេទគណនេយ្យ) បើទោះជាតាមការជាក់ស្តែង បដិភាគីអាចតម្រូវអោយទូទាត់សងជាសន្លឹកហ៊ុន នៅពេលណាក៏បានក៏ដោយ ។ បច្ចុប្បន្ននេះគណៈគ្រប់គ្រងកំពុងតែវាយតម្លៃផលប៉ះពាល់នៃការអនុវត្តស្តង់ដារនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*CIAS 24 (កែសម្រួល) ស្តីពី "ការលាតត្រដាងភាគីសម្ព័ន្ធញាតិ"*

CIAS 24 ត្រូវបានកែសម្រួលដូចតទៅ: (ក) កែសម្រួលនិយមន័យនៃពាក្យ "ភាគីសម្ព័ន្ធញាតិ" អោយមានលក្ខណៈកាន់តែសាមញ្ញ ដោយបញ្ជាក់អោយកាន់តែច្បាស់នូវអត្ថន័យរបស់វា និងលុបចោលនូវភាពមិនស៊ីសង្វាក់គ្នា របស់និយមន័យ និង(ខ) ផ្តល់នូវការលើកលែងខ្លះ ចំពោះអង្គភាពដែលពាក់ព័ន្ធនឹងរដ្ឋាភិបាល ចំពោះតម្រូវការនៃការលាតត្រដាងភាគីសម្ព័ន្ធញាតិនេះ ។ បច្ចុប្បន្ននេះគណៈគ្រប់គ្រងកំពុងតែធ្វើការវាយតម្លៃផលប៉ះពាល់នៃការអនុវត្ត ស្តង់ដារនេះ។

*CIAS 20 ស្តីពី "គណនេយ្យកម្មចំពោះជំនួយរដ្ឋាភិបាល និង ការលាតត្រដាងព័ត៌មានអំពីការជួយឧបត្ថម្ភរបស់រដ្ឋាភិបាល"*

ស្តង់ដារនេះត្រូវផ្តល់ការណែនាំអំពីការកត់ត្រា និង ការលាតត្រដាងព័ត៌មានអំពីជំនួយរដ្ឋាភិបាល និង ការលាតត្រដាងអំពីព័ត៌មានក្នុងទម្រង់ដ៏ទៃទៀត អំពីការជួយឧបត្ថម្ភរបស់រដ្ឋាភិបាល ។ ជំនួយរបស់រដ្ឋាភិបាលមិនត្រូវបានទទួលស្គាល់ទេ លុះត្រាតែការអះអាងដោយសមហេតុផលថា អង្គភាពអនុលោមតាមលក្ខខណ្ឌភ្ជាប់នឹងជំនួយនោះ ហើយជំនួយនឹងត្រូវទទួល ។ អត្ថប្រយោជន៍ឥណទានរបស់រដ្ឋាភិបាល ដែលមានអត្រាការប្រាក់ក្រោមអត្រា ទីផ្សារត្រូវបានចាត់ទុកជាជំនួយរបស់រដ្ឋាភិបាល ។ ឥណទាននោះត្រូវគេទទួលស្គាល់ និង វាស់វែងដោយអនុលោមតាម CIAS 39 ស្តីពីការទទួលស្គាល់ និង ការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ ។ អត្ថប្រយោជន៍នៃឥណទានរបស់ រដ្ឋាភិបាលដែលមានអត្រាការប្រាក់ក្រោមទីផ្សារ គួរត្រូវវាស់វែងតាមអត្រាលំអៀង រវាងតម្លៃនៅសល់បឋមនៃឥណទាន ដែលត្រូវបានកំណត់ដោយអនុលោមតាម CIAS 39 និង សាច់ប្រាក់ដែលទទួលបានជាក់ស្តែង ។ អត្ថប្រយោជន៍ត្រូវបានកត់ត្រាដោយអនុលោមតាមស្តង់ដារនេះ ។ ដូចបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ខ.២.២ ស្តីពី CIAS 39, CIFRS 1 អនុញ្ញាតអោយអនុវត្តតម្រូវការសម្រាប់ការទទួលស្គាល់ប្រាក់ចំណេញនៅថ្ងៃទី០១ ត្រូវអនុវត្តនាពេលខាងមុខ ចំពោះប្រតិបត្តិការដែលកើតឡើងបន្ទាប់ពីកាលបរិច្ឆេទផ្លាស់ប្តូរមកប្រើ CIFRS ។ រដ្ឋាករទឹក មានគំរោងនឹងអនុវត្តការលើកលែងនេះ ។ បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងតែធ្វើការវាយតម្លៃផលប៉ះពាល់នៃការអនុវត្តស្តង់ដារនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ខ.២.២- ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយ (ត)

### ●●●●● ស្តង់ដារគណនេយ្យថ្មីៗ និង វិសោធនកម្មលើស្តង់ដាដែលមានស្រាប់ដែលបានចេញផ្សាយ និងចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ហើយរដ្ឋាករទឹកមិនបានអនុវត្តមុនកាលកំណត់(ត)

*CIAS 32 ស្តីពី "ការលាតត្រដាងឧបករណ៍ហិរញ្ញវត្ថុ"*

ស្តង់ដារនេះបង្កើតគោលការណ៍សម្រាប់ការលាតត្រដាងឧបករណ៍ហិរញ្ញវត្ថុ ជាបំណុល ឬមូលធន និង សម្រាប់ទូទាត់ទ្រព្យសកម្មហិរញ្ញវត្ថុ ជាមួយនឹងបំណុលហិរញ្ញវត្ថុ ។ ស្តង់ដារនេះផ្តល់នូវការណែនាំចំពោះការធ្វើចំណាត់ថ្នាក់ឧបករណ៍ហិរញ្ញវត្ថុទៅជាទ្រព្យសកម្មហិរញ្ញវត្ថុ បំណុលហិរញ្ញវត្ថុ និងឧបករណ៍មូលធន ដោយឈរលើទស្សនវិស័យរបស់អ្នកចេញផ្សាយភាគហ៊ុន ។ ស្តង់ដារនេះក៏បានណែនាំពីការធ្វើចំណាត់ថ្នាក់អត្ថប្រយោជន៍ពាក់ព័ន្ធភាគលាភ ការខាត និងចំណេញ និងកាលៈទេសៈ ផ្សេងៗដែលគួរតែទូទាត់ទ្រព្យសកម្មហិរញ្ញវត្ថុ និង បំណុលហិរញ្ញវត្ថុ ។ ជាងនេះទៀតស្តង់ដារ នេះតម្រូវអោយអង្គភាពទាំងឡាយ ធ្វើចំណាត់ថ្នាក់ជាមូលធនចំពោះឧបករណ៍ហិរញ្ញវត្ថុដែលអាចលក់បាន (Puttable Financial Instruments) និងឧបករណ៍ផ្សេងៗ ឬសមាសធាតុនៃឧបករណ៍ផ្សេៗ ដែលធ្វើអោយអង្គភាពនោះជាប់កាតព្វកិច្ច ក្នុងការផ្តល់អោយភាគីមួយផ្សេងទៀត នូវចំណែកភាគហ៊ុន តាមសមមាត្រថេរនៃទ្រព្យសកម្មសុទ្ធរបស់អង្គភាពនោះ ទៅតាមដើមទុននៅពេលបិទក្រុមហ៊ុន ប្រសិនបើឧបករណ៍ហិរញ្ញវត្ថុមានលក្ខណៈពិសេស និង បំពេញនូវលក្ខខណ្ឌពិសេស ។ CIAS 32 នឹងត្រូវអនុវត្តត្រឡប់ក្រោយ ។ បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងតែធ្វើការវាយតម្លៃផលប៉ះពាល់ នៃការអនុវត្ត ស្តង់ដារនេះនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*CIAS 33 ស្តីពី "ប្រាក់ចំណេញក្នុងមួយភាគហ៊ុន"*

ស្តង់ដារនេះពណ៌នាអំពីគោលការណ៍សម្រាប់ការកំណត់ និងការបង្ហាញប្រាក់ចំណេញក្នុងមួយភាគហ៊ុន ដើម្បីធ្វើអោយប្រសើរឡើងនូវការប្រៀបធៀបលទ្ធផលហិរញ្ញវត្ថុ រវាងអង្គភាពផ្សេងគ្នា នៅក្នុងការិយបរិច្ឆេទរាយការណ៍ដូចគ្នា និង ប្រៀបធៀបការិយបរិច្ឆេទរាយការណ៍ផ្សេងគ្នាចំពោះអង្គភាពតែមួយ ។ បើទោះជាទិន្នន័យប្រាក់ចំណេញក្នុងមួយភាគហ៊ុនមានដែនកំណត់ដោយសារការប្រើប្រាស់គោលការណ៍គណនេយ្យខុសគ្នា ដើម្បីកំណត់ "ប្រាក់ចំណេញ" ក៏ដោយ ភាគបែងដែលត្រូវកំណត់យ៉ាងស៊ីសង្វាក់គ្នាមួយធ្វើអោយរបាយការណ៍ហិរញ្ញវត្ថុមានភាពប្រសើឡើង ។ ការអនុវត្តស្តង់ដារនេះ នឹងបណ្តាលអោយមានការលាតត្រដាងព័ត៌មានបន្ថែម អំពីប្រាក់ចំណេញក្នុងមួយភាគហ៊ុននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

*CIAS 36 ស្តីពី "ការថយចុះតម្លៃទ្រព្យសកម្ម"*

ស្តង់ដារនេះពណ៌នាអំពីនិតិវិធីដែលអង្គភាពមួយត្រូវអនុវត្ត ដើម្បីធានាថាទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានកត់ត្រាមិនលើសពីតម្លៃដែលអាចទទួលបានមកវិញរបស់វា ។ យោងតាមលក្ខខណ្ឌនៃស្តង់ដារនេះទ្រព្យសកម្មនឹងត្រូវបានកត់ត្រាលើសពីតម្លៃដែលអាចទទួលបានមកវិញរបស់វា ប្រសិនបើតម្លៃនៅសល់របស់វាលើសតម្លៃដែលអាចទទួលបានមកវិញ តាមរយៈការប្រើប្រាស់ ឬ ការលក់ទ្រព្យសកម្មនោះ។ ប្រសិនបើមានករណីនេះមែន ទ្រព្យសកម្មត្រូវបានចាត់ទុកថាថយចុះតម្លៃ ហើយស្តង់ដារនេះតម្រូវអោយអង្គភាពកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ។ ស្តង់ដារក៏បានបញ្ជាក់ផងដែរ ថានៅពេលណាដែលអង្គភាពគួរត្រូវកត់ត្រាការខាតបង់បណ្តាលមកពីការថយចុះតម្លៃ និង ពណ៌នាពីការលាតត្រដាងព័ត៌មាន ។

រដ្ឋាករទឹកនឹងអនុវត្តស្តង់ដារ CIAS 36 និងផ្តល់នូវការលាតត្រដាងព័ត៌មានតាមការតម្រូវ នៅពេលដែលការសាកល្បងរកការថយចុះតម្លៃ ត្រូវអនុវត្តនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ។ បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងតែធ្វើការវាយតម្លៃផលប៉ះពាល់នៃការអនុវត្តស្តង់ដារនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*CIAS 38 (វិសោធនកម្ម) ស្តីពី "ទ្រព្យសកម្មអរូបី"*

ស្តង់ដារ CIAS 38 ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោមនេះ ៖

ការបង់មុនអាចត្រូវបានទទួលស្គាល់តែក្នុងព្រឹត្តិការណ៍ដែលការបង់នោះ ត្រូវបានធ្វើឡើងមុនពេលទទួលបានសិទ្ធិកាន់កាប់ទំនិញ ឬទទួលបានសេវាកម្មតែប៉ុណ្ណោះ ។ វិសោធនកម្មនេះ នឹងមិនមានផលប៉ះពាល់ជាសារវន្ត លើរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកទេ ។ វិសោធនកម្មនេះលុបចោលនូវពាក្យដែលថ្លែងថា "Rarely, if even" ដែលគាំទ្រសំរាប់ការប្រើប្រាស់វិធីសាស្រ្តមួយដែលមានលទ្ធផលក្នុងអត្រារំលស់ទាបជាងវិធីសាស្ត្ររំលស់ថេរ ។ គណៈគ្រប់គ្រងកំពង់តែធ្វើការវាយតម្លៃផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ ។ វិសោធនកម្មនេះបញ្ជាក់ពីការណែនាំក្នុងការវាស់វែងតម្លៃទីផ្សារនៃទ្រព្យសកម្មអរូបី ដែលបានទិញនៅក្នុងការរួមបញ្ចូលអាជីវកម្ម និងអនុញ្ញាតឲ្យដាក់ក្រុមទ្រព្យសកម្មអរូបី ជាទ្រព្រសកម្មទោល ប្រសិនបើទ្រព្យសកម្មនោះមានអាយុកាលប្រើប្រាស់ ផ្នែកសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។ វិសោធនកម្មនេះ នឹងមិនមានផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាករទឹកទេ ដោយសារវាមិនពាក់ព័ន្ធនឹងរដ្ឋាករទឹក ។

## ខ.២.២- ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយ (ត)

### ●●●●● ស្តង់ដារគណនេយ្យថ្មីៗ និង វិសោធនកម្មលើស្តង់ដាដែលមានស្រាប់ដែលបានចេញផ្សាយ និងចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ហើយរដ្ឋាករទឹកមិនបានអនុវត្តមុនកាលកំណត់(ត)

*CIAS 39 ស្តីពី "ការទទួលស្គាល់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ"*

ស្តង់ដារនេះផ្តល់នូវការណែនាំចំពោះការទទួលស្គាល់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ រួមមានការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ គណនេយ្យកម្មសម្រាប់និទស្សន៍ និងការថយចុះតម្លៃ ។

*ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ជា៤ក្រុម : ១) ទ្រព្យសកម្មហិរញ្ញវត្ថុគិតតាមតម្លៃទីផ្សារ តាមរយៈចំណេញ និងខាត ២) វិនិយោគ និងកាន់កាប់រហូតដល់កាលកំណត់ ៣) ឥណទាន និងគណនីអតិថិជន និង ៤) ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានសម្រាប់លក់ ។ ការចាត់ថ្នាក់នេះ អាស្រ័យទៅតាមគោលបំណងនៃការទិញទ្រព្យសកម្មនីមួយៗ ។ បំណុលហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់ជា : ១) បំណុលហិរញ្ញវត្ថុគិតតាមតម្លៃទីផ្សារ តាមរយៈចំណេញ និងខាត ឬ ២) បំណុលហិរញ្ញវត្ថុគិតតាមថ្លៃដើមរំលស់ ។

*ការទទួលស្គាល់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុ*

ទ្រព្យសកម្មហិរញ្ញវត្ថុក្នុងទម្រង់ជាឥណទាន ជាគណនីអតិថិជន ជាវិនិយោគតាមកាលកំណត់ និងបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងតាមថ្លៃដើមរំលស់ ត្រូវបានគេទទួលស្គាល់ជាបឋមតាមតម្លៃទីផ្សារ កាត់កងនឹងចំណាយប្រតិបត្តិការ ហើយបន្ទាប់មកទៀតត្រូវបានទទួលស្គាល់តាមថ្លៃដើមរំលស់ ដោយប្រើវិធីសាស្ត្រអាត្រាការប្រាក់ដែលមានប្រសិទ្ធភាព និងត្រូវបានទទួលនៅក្នុងរបាយការណ៍លទ្ធផល ។

*ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ*

ការវាយតម្លៃទ្រព្យសកម្មហិរញ្ញវត្ថុ គួរតែត្រូវធ្វើឡើងនៅរៀងរាល់កាលបរិច្ឆេទតារាងតុល្យការ ដើម្បីកំណត់ថាតើមានភស្តុតាងជាក់ស្តែងណាមួយ បង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុទោលមួយ ឬទ្រព្យសកម្មហិរញ្ញវត្ថុជាក្រុម មានការថយចុះតម្លៃដែរឬទេ។ ប្រសិនបើមានភស្តុតាងបង្ហាញពីការថយចុះតម្លៃ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានវាស់វែងតាមតម្លៃលម្អៀងរវាងតម្លៃនៅសល់របស់ទ្រព្យសកម្ម និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដែលបានធ្វើអប្បហារតាម អត្រាការប្រាក់ដើមដែលមានប្រសិទ្ធិភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ ។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។

ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ការចាត់ថ្នាក់ និងការវាស់វែងឧបករណ៍ហិរញ្ញវត្ថុក្រោម CIAS 39 នឹងត្រូវជំនួសដោយ CIFRS 9 ។

ការអនុវត្ត CIAS 9 នឹងមានផលប៉ះពាល់ដល់ការទទួលស្គាល់ និងការវាស់វែងប្រាក់កម្ចីរបស់រដ្ឋាករទឹកក៏ប៉ុន្តែ CIFRS 1 ផ្តល់ជម្រើសលើកលែងឲ្យអង្គភាពមួយទទួលស្គាល់ប្រាក់ចំណេញ ថ្ងៃទី១នាពេលខាងមុខ (prospective) ចំពោះប្រតិបត្តិការណាដែលកើតឡើងបន្ទាប់ពីកាលបរិច្ឆេទផ្លាស់ប្តូរមកប្រើ CIFRS ។ រដ្ឋាករទឹកមានគម្រោងនឹងអនុវត្តជម្រើសលើកលែងនេះ ។ បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងតែធ្វើការវាយតម្លៃផលប៉ះពាល់នៃការអនុវត្តស្តង់ដារនេះ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

*CIFRS 1 ស្តីពី "ការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាលើកដំបូង"*

ស្តង់ដារនេះត្រូវអនុវត្ត នៅពេលដែលអង្គភាពមួយអនុវត្ត CIFRS លើកដំបូង ដោយមានសេចក្តីបញ្ជាក់ច្បាស់លាស់ និងជាក់ ស្តែង អំពីការអនុលោមតាម CIFRS ។

ជាទូទៅ CIFRS 1 តម្រូវឲ្យអង្គភាពមួយ អនុលោមតាម CIFRS នីមួយៗដែលនៅជាធរមាន នៅដំណាច់ការិយបរិច្ឆេទរាយការណ៍តាម CIFRS លើកដំបូងរបស់ខ្លួន ។ ជាពិសេស CIFRS តម្រូវឲ្យអង្គភាពមួយអនុវត្តដូចខាងក្រោមនេះ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដំបូងថា របាយការណ៍នេះបានរៀបចំតាម CIFRS ។

ស្តង់ដារនេះបានផ្តល់នូវការលើកលែងដែលមានកម្រិត ពីតម្រូវការទាំងនេះក្នុងផ្នែកជាក់លាក់នានា ដែលចំណាយក្នុងការអនុលោមតាមតម្រូវការទាំងនេះ ទំនងជាលើសពីអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ។ CIFRS 1 មិនអនុញ្ញាតឲ្យអនុវត្ត CIFRS មុនកាលកំណត់ចំពោះផ្នែកខ្លះ ជាពិសេសការអនុវត្តត្រលប់ក្រោយវិញ អាចតម្រូវឲ្យមានការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង លើសលក្ខខណ្ឌក្នុងអតីតកាលបន្ទាប់ពីគេបានដឹងលទ្ធនៃប្រតិបត្តិការជាក់លាក់រួចហើយនោះ ។

CIFRS 1 តម្រូវឲ្យមានការលាតត្រដាង ដែលពន្យល់អំពីផលប៉ះពាល់លើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់អង្គភាព ដោយសារការផ្លាស់ប្តូរពីស្តង់ដារគណនេយ្យមុន មកប្រើ CIFRS 1 ។

## ខ.២.២- ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយ (ត)

### ●●●●● ស្តង់ដារគណនេយ្យថ្មីៗ និង វិសោធនកម្មលើស្តង់ដាដែលមានស្រាប់ដែលបានចេញផ្សាយ និង ចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ហើយរដ្ឋាករទឹកមិនបានអនុវត្តមុនកាលកំណត់(ត)

*CIFRS 1 ស្តីពី "ការអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាលើកដំបូង" (ត)*

រដ្ឋាករទឹកនឹងអនុវត្តស្តង់ដារនេះ សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ និង កាលបរិច្ឆេទផ្លាស់ប្តូរ គឺថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ ។ រដ្ឋាករទឹកបានសម្រេចជ្រើសរើសដូចខាងក្រោម :

តម្រូវការក្នុងការទទួលស្គាល់ប្រាក់ចំនេញ " ថ្ងៃទី០១ " ត្រូវអនុវត្តនាពេលខាងមុខ (prospective) សម្រាប់ប្រតិបត្តិការ ដែលបានចុះកិច្ចសន្យាបន្ទាប់ពីកាលបរិច្ឆេទប្តូរមកប្រើ CIFRS ។

*CIFRS 2 ស្តីពី "ការទូទាត់ផ្អែកតាមភាគហ៊ុន"*

ស្តង់ដារនេះបញ្ជាក់ពីរបាយការណ៍ហិរញ្ញវត្ថុ ដែលអង្គភាពមួយត្រូវធ្វើនៅពេលដែលអង្គភាពនោះមានប្រតិបត្តិការទូទាត់ ផ្អែកតាមភាគហ៊ុន ។ ជាពិសេសស្តង់ដារនេះតម្រូវឲ្យភាពមួយត្រូវឆ្លុះបញ្ចាំង ផលប៉ះពាល់នៃប្រតិបត្តិការទូទាត់ផ្អែកតាម ភាគហ៊ុន នៅក្នុងចំណេញ ឬខាតរបស់ខ្លួន ស្ថានភាពហិរញ្ញវត្ថុរួមមានចំណាយដែលពាក់ព័ន្ធនឹងប្រតិបត្តិការ ដែលត្រូវទូទាត់ជាភាគហ៊ុន អោយនិយោជិត ។ ស្តង់ដារនេះនឹងមានផលប៉ះពាល់ដល់រដ្ឋាករទឹក ប្រសិបបើរដ្ឋាករទឹកសម្រេចផ្តល់ផែនការទូទាត់ផ្អែកតាមភាគ ហ៊ុនជូន និយោជិតរបស់ខ្លួននាពេលអនាគត ។

*CIFRS 7 (វិសោធកម្ម) ស្តីពី "ការលាតត្រដាងឧបករណ៍ហិរញ្ញវត្ថុ"*

ការលាតត្រដាងអំពីតម្លៃទីផ្សារ ដែលបានវាស់វែងតាមកម្រិតនៃឋានានុក្រមក្នុងការវាស់វែងតម្លៃទីផ្សារ និងហានិភ័យ សាច់ប្រាក់ងាយស្រួល ។

អន្តរសកម្មភាពរវាងការលាតត្រដាងផ្នែកបរិមាណ និងគុណភាព អំពីស្ថានភាព និង ទំហំនិភ័យ ដែលទាក់ទងនឹង ឧបករណ៍ហិរញ្ញវត្ថុ ។ វិសោធនកម្មនេះ នឹងបណ្តាលឲ្យមានការលាតត្រដាងព័តមានបន្ថែមទៀត ។

*CIFRS 8 ស្តីពី " ផ្នែកប្រតិបត្តិការ "*

ស្តង់ដារនេះ ចែងអំពីតម្រូវការក្នុងការលាតត្រដាងព័តមានអំពីផ្នែកប្រតិបត្តិការរបស់អង្គភាព អំពីផលិតផល និង សេវាកម្មរបស់ អង្គភាព ភូមិសាស្ត្រដែលអង្គភាពធ្វើប្រតិបត្តិការអាជីវកម្ម និងអតិថិជនសំខាន់ៗផងដែរ ។ ស្តង់ដារនេះតម្រូវឲ្យ រាយការណ៍ព័តមានតាមផ្នែក ដោយផ្អែកលើផ្នែកប្រតិបត្តិការរបស់អង្គភាព ។ ផ្នែកប្រតិបត្តិការ គឺជាសមាសធាតុរបស់សហគ្រាស មួយ ដែលមានព័តមានហិរញ្ញវត្ថុ ដាច់ដោយឡែក និងត្រូវបានវាយតម្លៃជាប្រចាំដោយអ្នកសម្រេចចិត្តខាងផ្នែកប្រតិបត្តិការ ក្នុងការសម្រេច ពីវិធីបែងចែកធនធាន និងវាយតម្លៃលទ្ធផល ។ ជាទូទៅព័តមានហិរញ្ញវត្ថុ ត្រូវបានតម្រូវឲ្យរាយការណ៍តាមមូល ដ្ឋានដូចគ្នា នឹងមូលដ្ឋានដែលត្រូវបានប្រើប្រាស់ផ្ទៃក្នុង សម្រាប់វាយតម្លៃលទ្ធផលតាមផ្នែក និងសម្រេចពីវិធីដែលត្រូវបែងចែក ធនធាន តាមផ្នែកទាំងនោះ ។

គណៈគ្រប់គ្រងកំពុងតែស្ថិតក្នុងដំណាក់កាលនៃការវាយតម្លៃផលប៉ះពាល់នៃស្តង់ដារនេះ លើរបាយការណ៍ហិរញ្ញវត្ថុ ។

*CIFRIC 10 ស្តីពី "របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា និងការថយចុះតម្លៃ"*

អង្គភាពមួយមិនត្រូវកត់ត្រាបញ្ច្រាសការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ដែលបានទទួលស្គាល់រួចហើយ ក្នុង ការិយបរិច្ឆេទក្នុងគ្រាមុន ទាក់ទិនទៅនឹង កេរ្តិ៍ឈ្មោះអាជីវកម្ម ឬការវិនិយោគ ឧបករណ៍មូលធន ឬទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវ បានកត់ត្រាតាមថ្លៃដើម ។ គណៈគ្រប់គ្រងកំពុងតែស្ថិតក្នុងដំណាក់កាលនៃការវាយតម្លៃផលប៉ះពាល់នៃស្តង់ដារនេះលើរបាយ-ការណ៍ហិរញ្ញវត្ថុ ។

*CIFRIC 14 ស្តីពី "ការកំណត់លើអត្ថប្រយោជន៍ទ្រព្យសកម្មដែលបានកំណត់តម្រូវការទាំងឡាយណាដើម្បីផ្តល់មូលនិធិ អប្បបរមា និងអន្តរសកម្មរបស់វា"*

គោលបំណងនៃបំណកស្រាយនេះគឺ តម្រូវការមូលនិធិអប្បបរមា គឺជាតម្រូវការទាំងឡាយណាដើម្បីផ្តល់មូលនិធិដល់ គម្រោងអត្ថប្រយោជន៍ដែលបានកំណត់រយៈពេលវែងផ្សេងៗ ។ បំណកស្រាយនេះ សំដៅលើបញ្ហាមួយចំនួនដូចជា (i) នៅពេល ណា ដែលអាចចាត់ទុកថាមានការបង្វិលសាច់ប្រាក់មកវិញ ឬមានការកាត់បន្ថយវិភាគទានក្នុងពេលអនាគត និង (ii) របៀបដែល តម្រូវការមូលនិធិអប្បបរមា អាចប៉ះពាល់ដល់ការកាត់បន្ថយវិភាគទានក្នុងអនាគត និង (iii) នៅពេលដែលតម្រូវការមូលនិធិ អប្បបរមា អាចធ្វើឲ្យបំណុលកើនឡើង ។ គណៈគ្រប់គ្រងកំពុងតែស្ថិតក្នុងដំណាក់កាលនៃការវាយតម្លៃផលប៉ះពាល់នៃស្តង់ដារ នេះ លើរបាយការណ៍ហិរញ្ញវត្ថុ ។

## ខ.២.២- ស្តង់ដារគណនេយ្យថ្មីៗ និងបំណកស្រាយ (ត)

### ••••• ស្តង់ដារគណនេយ្យថ្មីៗ និង វិសោធនកម្មលើស្តង់ដាដែលមានស្រាប់ដែលបានចេញផ្សាយ និង ចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ហើយរដ្ឋាករទឹកមិនបានអនុវត្តមុនកាលកំណត់(ត)

*CIFRIC 14 ស្តីពី "ការកំណត់លើអត្ថប្រយោជន៍ទ្រព្យសកម្មដែលបានកំណត់តម្រូវការទាំងឡាយណាដើម្បីផ្តល់មូលនិធិអប្បបរមា និងអន្តរសកម្មរបស់វា" (ត)*

វិសោធនកម្មនេះតម្រូវឲ្យអង្គភាពមួយ ទទួលស្គាល់រាល់បម្រែបម្រួលទាំងអស់ នៃបំណុល/ទ្រព្យសកម្មអត្ថប្រយោជន៍ដែលបានកំណត់សុទ្ធ ក្នុងការិយបរិច្ឆេទដែលបម្រែបម្រួលទាំងនោះបានកើតឡើង ហើយត្រូវបំបែកនិងទទួលស្គាល់ថ្លៃដើមនៃអត្ថប្រយោជន៍ដែលបានកំណត់នោះ ។ ជាងនេះទៅទៀត បម្រែបម្រួលសំខាន់ៗចំពោះតម្រូវការក្នុងការកត់ត្រាមានដូចជា (i) ការកត់ត្រាចំណេញ ឬខាតក្នុងការគណនាហានិភ័យ នៅក្នុងចំណូលលម្អិតផ្សេងៗភ្លាមៗ (ii) ការកត់ត្រាថ្លៃដើមសេវាកម្មអតីតកាល ក្នុងរបាយការណ៍លទ្ធផលភ្លាមៗ និង (iii) ការកំណត់ឡើងវិញនៃសមាសធាតុផ្សេងៗ ក្នុងថ្លៃដើមនៃអត្ថប្រយោជន៍ដែលបានកំណត់ ។ ការអនុវត្តវិសោធនកម្មនេះ នឹងបណ្តាលឲ្យមានការចាត់ថ្នាក់ឡើងវិញនៃចំណេញ ឬខាតនៃការគណនាហានិភ័យដែលបច្ចុប្បន្ន នេះបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល ទៅកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗវិញ ។ បច្ចុប្បន្ននេះ រដ្ឋាករទឹកកំពុងវាយតម្លៃផលប៉ះពាល់ពេញលេញនៃវិសោធនកម្មនេះ លើរបាយការណ៍ហិរញ្ញវត្ថុ ។

*CIFRS 9 ស្តីពី "ឧបករណ៍ហិរញ្ញវត្ថុ"*

CIFRS 9 បង្កើតនូវគោលការណ៍សម្រាប់ការរាយការណ៍ហិរញ្ញវត្ថុ អំពីទ្រព្យសកម្មហិរញ្ញវត្ថុ ដែលនឹងត្រូវបង្ហាញព័ត៌មានពាក់ព័ន្ធ និងមានប្រយោជន៍ចំពោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ដើម្បីការវាយតម្លៃលើចំនួនទឹកប្រាក់ ពេលវេលា និងភាពមិនប្រាកដប្រជានៃលំហូរសាច់ប្រាក់នាពេលអនាគតរបស់អង្គភាព ។ CIFRS 9 នឹងជំនួស CIAS 39 ដែលមានការណែនាំលើការចាត់ថ្នាក់ និងការវាស់វែងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ នេះតទៅ ។ CIFRS 9 បញ្ជាក់ពីរបៀបដែលអង្គភាពមួយគួរចាត់ថ្នាក់ និងវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន រាប់ទាំងកិច្ចសន្យាកូនកាត់ផងដែរ ។ ស្តង់ដារនេះតម្រូវការចាត់ចែងទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ត្រូវ: (ក) ចាត់ថ្នាក់តាមមូលដ្ឋានគំរូអាជីវកម្មរបស់អង្គភាព (ខ) វាស់វែងជាបឋមតាមតម្លៃទីផ្សារបូកជាមួយថ្លៃដើមប្រតិបត្តិការ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនគិតតាមតម្លៃទីផ្សារ តាមរយៈចំណេញ ឬខាត និង (គ) នៅពេលបន្ទាប់មកត្រូវវាស់តាមថ្លៃដើមរំលស់ ឬតាមតម្លៃទីផ្សារ ។ រដ្ឋាករទឹក នឹងអនុវត្ត CIFRS 9 ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ។ បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងវាយតម្លៃ ផលប៉ះពាល់នៃស្តង់ដារនេះ លើរបាយការណ៍ហិរញ្ញវត្ថុ ។

*CIFRS 13 ស្តីពី "ការវាស់វែងតម្លៃទីផ្សារ"*

ស្តង់ដារនេះ (i) កំណត់តម្លៃទីផ្សារ (ii) ចែងអំពីគម្រោងក្នុងការវាស់វែងតម្លៃទីផ្សារនៅក្នុង CIFRS តែមួយ និង (iii) តម្រូវឲ្យមានការលាតត្រដាងអំពីការវាស់វែងតម្លៃទីផ្សារ ។ បច្ចុប្បន្ននេះ គណៈគ្រប់គ្រងកំពុងវាយតម្លៃផលប៉ះពាល់នៃស្តង់ដារនេះ លើរបាយការណ៍ហិរញ្ញវត្ថុ ។

## ខ.២.៣- ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានរាយការណ៍ ទៅតាមទស្សនៈថ្លៃដើម ឬការវាយតំលៃដំបូងបង្អស់ ដែលបានព្រមព្រៀង ដករំលស់បង្គរ ។ ទស្សនៈថ្លៃដើមរាប់បញ្ចូលចំណាយផ្ទាល់លើការទិញ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ។ ចំណាយបន្តបន្ទាប់ទៀតត្រូវបានដាក់បញ្ចូលទៅក្នុងតំលៃនៅសល់នៃទ្រព្យសកម្ម ឬត្រូវបានទទួលស្គាល់ថាមានភាពសមស្រប តែនៅពេលដែលមានភាពប្រាកដថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារនីមួយៗនឹងហូរចូលទៅក្នុងក្រុមហ៊ុន ហើយចំណាយនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារនោះ អាចវាស់វែងបានយ៉ាង គួរអោយជឿជាក់ ។ តំលៃនៅសល់នៃផ្នែកដែលត្រូវបាន ជំនួសឡើងវិញ ត្រូវបានគេឈប់កត់ត្រា ។ ចំណាយលើការជួសជុល និង ថែទាំផ្សេងៗត្រូវបានគេកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ក្នុង ការិយបរិច្ឆេទហិរញ្ញវត្ថុ ដែលប្រតិបត្តិការនោះបានកើតឡើង ។

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងកែតំរូវបើចាំបាច់នៅតាមរាល់ការិយបរិច្ឆេទ នៃតារាងតុល្យការនីមួយៗ ។ ចំណេញ/ខាតទៅលើការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀប ធៀប ប្រាក់លក់បានជាមួយនិងតំលៃនៅសល់ ហើយត្រូវបានគេបញ្ចូល ក្នុងរបាយការណ៍លទ្ធផល ។

អចលនទ្រព្យដែលរំលស់អស់ត្រូវបានគេរក្សាទុកក្នុងបញ្ជីគណនី រហូតដល់ពេលគេលែងប្រើប្រាស់តទៅទៀត ហើយគ្មានការកត់ត្រារំលស់បន្ថែមទៀតលើ អចលនៈទ្រព្យទាំងនោះទេ ។

## ខ២.៣- ទ្រព្យសម្បត្តិ រោងចក្រ និង បរិក្ខារ (ត)

រំលស់ត្រូវបានគណនាតាមវិធីសាស្ត្រថេរ ដើម្បីជំរុះចោលនូវតំលៃនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារលើកលែងតែដីធ្លី អោយនៅសល់តែតំលៃសំណល់ ដោយផ្អែកលើអាយុកាលនៃការប្រើប្រាស់ដែលបានប៉ាន់ស្មាន ដូចតទៅ :

| បរិយាយ | រយៈពេលរំលស់ |
|---|---|
| ដីធ្លី | គ្មានរំលស់ |
| សំណង់លើដីកាន់កាប់ | ៥០ ឆ្នាំ |
| គ្រឿងយន្ត | ៧ និង ២០ ឆ្នាំ |
| បំពង់បង្ហូរទឹក | ១៥-៣៥-៤០ និង៥០ ឆ្នាំ |
| សង្ហារឹម និងបរិក្ខារការិយាល័យ | ៧ ឆ្នាំ |
| បរិក្ខារមន្ទីរពិសោធន៍ | ៧ ឆ្នាំ |
| ឧបករណ៍ប្រើប្រាស់ | ៧ ឆ្នាំ |
| មធ្យោបាយដឹកជញ្ជូន | ៧ ឆ្នាំ |
| បរិក្ខារអគ្គីសនី | ១ - ១៥ ឆ្នាំ |
| អចនៈទ្រព្យនាឡិកាទឹក | ៥ ឆ្នាំ |


អាងផលិតទឹកស្អាត រោងចក្រភូមិព្រែក

.ត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃនៅពេលដែលមានព្រឹត្តការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈនាចង្អុលបង្ហាញថាតម្លៃនៅសល់នឹងមិនអាចស្រង់មកវិញបាន ។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រូវបានគេកត់ត្រាតាមតម្លៃនៅសល់របស់ទ្រព្យសកម្ម ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន ។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងគេ រវាងតម្លៃទីផ្សារនៃទ្រព្យសកម្ម ដកចំណាយលើការលក់ និងតម្លៃនោះអាចប្រើប្រាស់បានរបស់វា ។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានគេបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់ដោយឡែករបស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់) ។ ការថយចុះតម្លៃនៃទ្រព្យសកម្ម ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

## ខ.២.៦- សន្និធិ

សន្និធិត្រូវបានកត់ត្រាតាមតំលៃទាបជាង រវាងថ្លៃដើមដែលបានកើតឡើងក្នុងការនាំយកផលិតផល នីមួយៗមកកាន់ទីតាំង និងលក្ខខណ្ឌបច្ចុប្បន្នរបស់វា និងតំលៃដែលអាចលក់បាន ។

វត្ថុធាតុដើមដែលត្រូវប្រើប្រាស់ និងសំភារៈដែលទាក់ទងនឹងការផ្គត់ផ្គង់ទឹកដទៃទៀត ត្រូវបានគេវាយតំលៃតាមតំលៃដើមជាក់ស្តែងនៃការនាំយកសន្និធិមកប្រើប្រាស់ ទៅតាមគោលបំណងដែលបានគ្រោងទុក ដកសំវិធានធនសម្រាប់ការខូចខាតសន្និធិប្រើប្រាស់លែងបាន និងសន្និធិមានចលនាយឺតយ៉ាវដោយប្រើ មូលដ្ឋានសារពើភ័ណ្ឌមធ្យមភាគ ។

តំលៃដែលអាចលក់បាន គណនាដោយយកតំលៃលក់ប៉ាន់ស្មាន ដកចំណាយលើការលក់ និងចំណាយលើសំវិធានធនសំរាប់ការខូចខាត សន្និធិប្រើប្រាស់លែងបាន និងសន្និធិដែលមានចលនាយឺតយ៉ាវ ។

## ខ.២.៧- គណនីអតិថិជន

គណនីអតិថិជនពាណិជ្ជកម្ម គឺជាទឹកប្រាក់ជំពាក់ដោយអតិថិជននៅតាមផ្ទះ អតិថិជនប្រើប្រាស់ក្នុងលក្ខណៈអាជីវកម្ម និងគ្រឹះស្ថានរដ្ឋ ។ ប្រសិនបើរដ្ឋាករទឹករំពឹងថានឹងប្រមូលប្រាក់បាន ក្នុងរយៈពេល១ឆ្នាំ ឬតិចជាងគណនីអតិថិជនពាណិជ្ជកម្មនោះ ត្រូវបានកត់ត្រាជាគណនីអតិថិជនពាណិជ្ជកម្មរយៈពេលខ្លី ។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាគណនីអតិថិជនពាណិជ្ជកម្មរយៈពេលវែង ។ គណនីអតិថិជនពាណិជ្ជកម្មត្រូវបានកត់ត្រាតាមតម្លៃវិក្កយបត្រដើម ដកការប៉ាន់ស្មានសំរាប់គណនីត្រូវទទួលសង្ស័យ ដោយផ្អែកលើការពិនិត្យមើលឡើងវិញនូវតំលៃដែលគេមិនទាន់សងទាំងអស់នាដំណាច់ឆ្នាំ ។ បំណុលអាក្រក់ ត្រូវបានជម្រះចេញពីបញ្ជីនៅពេលដែលគេរកឃើញ ។

### ខ.២.៨- សាច់ប្រាក់ និង សាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់តំកល់ក្នុងធនាគារ និងការវិនិយោគរយៈពេលខ្លី ដែលអាចបង្វែរជាសាច់ប្រាក់បានភ្លាមៗ ដែលមានអាយុកាលបីខែ រឺក៏តិចជាង ។

### ខ.២.៩- ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់

ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ ត្រូវបានបង្ហាញនៅក្នុងតារាងតុល្យការ តាមចំនួនប្រាក់ដើមនៅសល់ ។

### ខ.២.១០- គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម

គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម ជាកាតព្វកិច្ចបង់ប្រាក់សម្រាប់ការទិញទំនិញ ឬសេវាកម្មផ្សេងៗ ពីអ្នកផ្គត់ផ្គង់ក្នុងដំណើរការអាជីវកម្មធម្មតា ។ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម ត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី ប្រសិនបើការសងប្រាក់ ត្រូវផុតកំណត់ក្នុងរយៈពេល១ឆ្នាំ ឬតិចជាង ។ ប្រសិនបើលើសពី១ឆ្នាំ វាត្រូវបានចាត់ទុកជាបំណុលរយៈពេលវែង ។ គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម ត្រូវបានកត់ត្រាតាមតម្លៃវិក្កបត្រដើម ។

### ខ.២.១១- ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានទទួលស្គាល់តាមចំនួនដែលបានទទួល ដែលប្រហាក់ប្រហែលទៅនឹងតំលៃទីផ្សារ ។ បន្ទាប់ពីនោះ កំចីត្រូវបានបង្ហាញជាថ្លៃដើមដែលមានលក្ខណៈជាបំណុលត្រូវសងបន្តិចម្តងៗ ហើយភាពខុសគ្នារវាងប្រាក់ដែលទទួលបាន និងចំនួននៃការបង់ចំនួនសងវិញ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលនៃរយៈពេលនៃកំចី ទៅតាមវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

កំចីត្រូវបានគេធ្វើចំណាត់ថ្នាក់ជាទ្រព្យអកម្មរយៈពេលខ្លី លុះត្រាតែរដ្ឋាករទឹកមានសិទ្ធិដោយឥតលក្ខខណ្ឌដើម្បីពន្យាការទូទាត់យ៉ាងហោចណាស់១២ខែ បន្ទាប់ពីកាលបរិច្ឆេទតារាងតុល្យការ ។

ចំណាយការប្រាក់លើប្រាក់កម្ចី ត្រូវបានកត់ត្រាជាបន្ទុករបាយការណ៍លទ្ធផល ។ បន្ទុកប្រាក់កម្ចីដែលពាក់-ព័ន្ធនឹងទ្រព្យសកម្មដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានធ្វើមូលធនកម្មជាផ្នែកមួយនៃថ្លៃដើមទ្រព្យសកម្ម។

### ខ.២.១២- ប្រាក់កក់របស់អតិថិជន

មុនពេលតភ្ជាប់បណ្តាញ រដ្ឋាករទឹកបានប្រមូលប្រាក់កក់ពីពតិថិជន អាស្រ័យទៅតាមទំហំនៃនាឡិកាទឹក ហើយត្រូវបានកត់ត្រាទៅតាមចំនួនដែលទទួលបានជាប្រាក់តម្កល់របស់អតិថិជន ក្រោមខ្ទង់បំណុលរយៈពេលវែង ។

### ខ.២.១៣- ពន្ធពន្យារលើប្រាក់ចំណេញ

ចំណាយពន្ធប្រចាំការិយបរិច្ឆេទ រួមមានពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធលើប្រាក់ចំណេញពន្យារ ។ ពន្ធត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែពន្ធនោះទាក់ទងនឹងគណនីមួយចំនួនដែលបានកត់ត្រាដោយផ្ទាល់នៅក្នុងមូលធន ។

ចំណាយពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធ ដែលបានអនុម័តរួចរាល់ ឬអនុម័តមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ នៅក្នុងប្រទេសកម្ពុជា ជាកន្លែងដែលរដ្ឋាករទឹកបង្កើតប្រាក់ចំណេញជាប់ពន្ធ ។ គណៈគ្រប់គ្រងវាយតម្លៃពីមួយគ្រាទៅមួយគ្រាអំពីស្ថានភាពដែលបានកត់ត្រាក្នុងលិខិតប្រកាសពន្ធទាក់ទិនទៅនឹងសភាពការណ៍ផ្សេងៗ ដែលបទប្បញ្ញត្តិពន្ធត្រូវធ្វើបំណកស្រាយ ។ រដ្ឋាករទឹកកត់ត្រាសំវិធានធនផ្អែកលើមូលដ្ឋាននៃចំនួនដែលរំពឹងថា នឹងត្រូវបង់ជូនអគ្គនាយកដ្ឋានពន្ធដារ ។

ពន្ធពន្យារលើប្រាក់ចំណេញ ត្រូវបានធ្វើសំវិធានធនទាំងស្រុង ដោយប្រើវិធីសាស្ត្រទ្រព្យអកម្ម ដែលផ្អែកលើភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងរវាងមូលដ្ឋានគិតពន្ធនៃទ្រព្យសកម្មនិងទ្រព្យអកម្ម និងតំលៃចុះបញ្ជីបច្ចុប្បន្នរបស់វាក្នុងរបាយកាណ៍ហិរញ្ញវត្ថុ ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានគេទទួលស្គាល់ លុះត្រាតែមានភាពប្រាកដថាមាន ប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគត អាចប្រើប្រាស់សំរាប់ទូទាត់ជាមួយនឹងវិសមភាពបណ្តោះអាសន្ននោះ ។ ពន្ធពន្យារត្រូវបានគេគណនាដោយប្រើអត្រាពន្ធជាគោល ២០% ។

## ខ.២.១៤- អត្ថប្រយោជន៍និយោជិត

### • កាតព្វកិច្ចសោធននិវត្តន៍

រដ្ឋាករទឹកប្រតិបត្តិផែនការចូលនិវត្តដោយរដ្ឋាករទឹកព្រមទាំងនិយោជិតត្រូវរួមវិភាគទានចូលទៅក្នុងគណនីសាច់ប្រាក់ផ្ទៃក្នុង ដោយស្ថិតក្រោមឈ្មោះរបស់រដ្ឋាករទឹក ។

- វិភាគទានរបស់និយោជិត គឺអត្រា ៧% នៃប្រាក់បៀវត្សប្រចាំខែ (៦% មុនខែតុលា ឆ្នាំ២០០៧)
- វិភាគទានរបស់រដ្ឋាករទឹក គឺអត្រា ៥% នៃប្រាក់បៀវត្សប្រចាំខែរបស់និយោជិត បូកបន្ថែម ២% នៃប្រាក់ចំណេញប្រចាំឆ្នាំ ។

រដ្ឋាករទឹកទទួលស្គាល់សំវិធានធនប្រាក់សោធននិវត្តន៍ក្នុងតារាងតុល្យការ និង របាយការណ៍លទ្ធផលដោយផ្អែកលើអត្រាវិភាគទាន ដែលបានកំណត់សំរាប់និយោជិតទាំងអស់ជារៀងរាល់ខែ ។ ការទូទាត់សងដល់និយោជិតពេញសិទ្ធិត្រូវបានដកចេញពីសំវិធានធនជាប់ពាក់ព័ន្ធនៅពេលដែលនិយោជិតចូលនិវត្ត ឬលាឈប់ពីការងារដោយផ្អែកលើលក្ខខណ្ឌដូចតទៅះ

- និយោជិតដែលបានធ្វើការរយៈពេលចាប់ពី ១០ទៅ ១៩ឆ្នាំ និងរហូតដល់អាយុកាលចូលនិវត្ត នឹងទទួលបានផលប្រយោជន៍ចូលនិវត្ត ២០០% នៃវិភាគទានចូលនិវត្តបង្គរតែម្តងគត់ ។
- និយោជិតដែលបានធ្វើការរយៈពេលលើសពី ២០ឆ្នាំ និងរហូតដល់អាយុកាលចូលនិវត្តនឹងទទួលបានប្រាក់សោធននិវត្តន៍ប្រចាំខែ ២៥% និងបន្ថែម ១%ទៀត ជារៀងរាល់ឆ្នាំ ពីឆ្នាំទី២១ នៃប្រាក់បៀវត្សចុងក្រោយជា រៀងរាល់ខែ រហូតដល់ពួកគេទទួលមរណៈភាព ។
- និយោជិតដែលបានលាឈប់មុនអាយុកាលចូលនិវត្តនឹងទទួលបានការទូទាត់សងម្តងគត់ដូចខាងក្រោម
  - ១២០% នៃវិភាគទានបង្គរសំរាប់និយោជិត ដែលធ្វើការរយៈពេល១០ឆ្នាំ និងបន្ថែម១% នៃវិភាគទានបង្គរសំរាប់រៀងរាល់ឆ្នាំ ពីឆ្នាំទី១១ ដល់ឆ្នាំទី២០ ។
  - ១៣៥% នៃវិភាគទានបង្គរសំរាប់និយោជិត ដែលធ្វើការរយៈពេល២១ឆ្នាំ និងបន្ថែម១% នៃវិភាគទានបង្គរសំរាប់រៀងរាល់ឆ្នាំ ពីឆ្នាំទី២២ ដល់ឆ្នាំទី៣០ ។
  - ១៥៥% នៃវិភាគទានបង្គរសំរាប់និយោជិត ដែលធ្វើការរយៈពេល៣១ឆ្នាំ និងបន្ថែម១% នៃវិភាគទានបង្គរសំរាប់រៀងរាល់ឆ្នាំ លើឆ្នាំទី៣១ ។

បំណុលដែលបានកត់ត្រានៅក្នុងតារាងតុល្យការ ទាក់ទិននឹងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ គឺជាតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍ដែលបានកំណត់ គិតត្រឹមដំណាច់ការិយបរិច្ឆេទរាយការណ៍ ដកតម្លៃទីផ្សារនៃទ្រព្យសកម្មក្នុងគម្រោង រួមនឹងនិយ័តកម្មថ្លៃដើមសេវាកម្មអតីតកាលដែលមិនទាន់បានទទួលស្គាល់ ។ កាតព្វកិច្ចសោធននិវត្តន៍ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រ projected unit credit ។ តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ត្រូវបានកំណត់ដោយធ្វើអប្បហារលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយប្រើអត្រាប្រាក់តម្កល់មធ្យមនៃមូលនិធិដែលបានផ្ញើនៅធនាគារ បម្រុងសម្រាប់បង់អត្ថប្រយោជន៍សោធននិវត្តន៍ ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា ។

ចំណេញ និងខាតពីការគណនាហានិភ័យ ដែលកើតពីនិយ័តកម្មក្នុងគ្រាមុន និងបម្រែបម្រួលក្នុងការសន្មតការគណនាហានិភ័យ ត្រូវបានកត់ត្រាជាបន្ទុក ឬកត់ត្រាខាងខ្ទង់ឥណទាន ក្នុងរបាយការណ៍ហិរញ្ញវត្ថុ ក្នុងការិយបរិច្ឆេទ ដែលវាកើតឡើង ។ ចំណាយដែលពាក់ព័ន្ធនឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រាជាបន្ទុករបាយការណ៍លទ្ធផលដើម្បីចែកចាយចំណាយនោះ លើរយៈពេលនៃការបម្រើការងារ ក្នុងអំឡុងពេលដែលអត្ថប្រយោជន៍នោះបានទទួល ។ ថ្លៃដើមសេវាកម្មក្នុងអតីតកាល ត្រូវបានកត់ត្រាភ្លាមក្នុងរបាយការណ៍លទ្ធផលលើកលែងតែបម្រែបម្រួលនៃគម្រោងសោធននិវត្តន៍ អាស្រ័យលើនិយោជិតដែលនៅបម្រើការងារសម្រាប់រយៈពេលជាក់លាក់មួយ (រយៈពេលដែលនិយោជិតមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍) ។ ក្នុងករណីនេះថ្លៃដើមសេវាកម្មក្នុងអតីតកាលត្រូវបានធ្វើរំលស់តាមមូលដ្ឋានថេរលើរយៈពេលដែលនិយោជិតមានសិទ្ធិទទួលបានប្រាក់សោធននិវត្តន៍។

## ៤.២.១៤- អត្ថប្រយោជន៍និយោជិត (ត)

●● គម្រោងប្រាក់រង្វាន់

រដ្ឋាករទឹកទទួលស្គាល់បំណុល និងចំណាយសំរាប់ប្រាក់រង្វាន់ជូនបុគ្គលិក ដោយយោងទៅតាមប្រាក់ចំណេញរបស់រដ្ឋាករទឹកក្នុងឆ្នាំនីមួយៗ តាមរូបមន្តដូចខាងក្រោម៖

- ប្រាក់បៀវត្ស១ខែ សំរាប់និយោជិតទាំងអស់ប្រសិនបើប្រាក់ចំណេញសុទ្ធទទួលបានពី៥%ទៅ១០% នៃចំណាយប្រតិបត្តិការ ។
- ប្រាក់បៀវត្ស២ខែ សំរាប់និយោជិតទាំងអស់ ប្រសិនបើប្រាក់ចំណេញសុទ្ធទទួលបានពី១១% ទៅ ២០% នៃចំណាយប្រតិបត្តិការ ។
- ប្រាក់បៀវត្ស៣ខែសំរាប់និយោជិតទាំងអស់ប្រសិនបើប្រាក់ចំណេញសុទ្ធទទួលបានច្រើនជាង២១% នៃចំណាយប្រតិបត្តិការ ។

ការទូទាត់ គឺជាធម្មតាធ្វើឡើងក្នុងខែមេសា ឬខែឧសភា នៃឆ្នាំបន្ទាប់ ។

## ៤.២.១៥- សំវិធានធន និង បំណុលយថាភាព

សំវិធានធនត្រូវបានកត់ត្រានៅពេលដែលរដ្ឋាករទឹកមានកាតព្វកិច្ច នាពេលបច្ចុប្បន្នតាមផ្លូវច្បាប់ ដែលជាលទ្ធផល នៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតំរូវអោយមានការចំណាយធនធាន ដើម្បីយកទៅទូទាត់កាតព្វកិច្ចទាំងនោះ និងចំនួនទឹកប្រាក់អាចប៉ាន់ស្មានដែលជឿជាក់បាន ។ សំវិធានធនមិនត្រូវបានគេកត់ត្រាឡើយសំរាប់ការខាតបង់លើប្រតិបត្តិការនាពេលអនាគតនោះទេ ។

សំវិធានធនត្រូវគិតតាមចំណាយដែលរំពឹងទុកដើម្បីទូទាត់កាតព្វកិច្ច ។ ប្រសិនបើតំលៃពេលវេលានៃទឹកប្រាក់មានចំនួនធំគ្រប់គ្រាន់ នោះសំវិធានធនត្រូវវាស់វែងតាមតំលៃបច្ចុប្បន្នរបស់វា ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងអំពីការវាយតំលៃទីផ្សារបច្ចុប្បន្ននូវតំលៃពេលវេលានៃទឹកប្រាក់ និង ហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចទាំងនោះ ។ កំណើនសំវិធានធនដោយសារពេលវេលា ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

ទ្រព្យអកម្មយថាភាព គឺជាកាតព្វកិច្ចមួយដែលអាចកើតមាន ហើយវាបានមកពីព្រឹត្តិការណ៍នាពេលអតីតកាល ដែលការកើតឡើងនោះនឹងត្រូវបញ្ជាក់ដោយភាពកើតមានឬមិនកើតមាននៃហេតុការណ៍មិនពិតប្រាកដនាពេលអនាគតមួយ ឬច្រើនដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងដោយរដ្ឋាករទឹកនោះទេ ។ ទ្រព្យអកម្មយថាភាពក៏អាចជា កាតព្វកិច្ចនាពេលបច្ចុប្បន្នផងដែរ ដែលកើតឡើងមកពីព្រឹត្តិការណ៍នាពេលអតីតកាល ហើយមិនទាន់ត្រូវបានកត់ត្រា ដោយសារលំហូរចេញនៃធនធានសេដ្ឋកិច្ចមិនទំនងជាកើតមាន រឺក៏ការគណនាចំនួននៃកាតព្វកិច្ចនោះមិនអាចជឿជាក់បាន ។ ទ្រព្យអកម្មយថាភាពមិនត្រូវបានកត់ត្រាទេ ប៉ុន្តែវាត្រូវបានបង្ហាញនៅក្នុងកំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ ។ នៅពេលដែលមានការប្រែប្រួលលើភាពជាក់លាក់នៅក្នុងលំហូរចេញថាវាអាចនឹងកើតឡើងនោះបំណុល យថាភាព នឹងត្រូវបានកត់ត្រាជាសំវិធានធន ។

## ៤.២.១៦- ការទទួលស្គាល់ចំណូល

ចំណូលត្រូវបានទទួលស្គាល់នៅពេលដែលវាទំនងថា ផលប្រយោជន៍សេដ្ឋកិច្ចនឹងទទួលដោយរដ្ឋាករទឹក ហើយចំណូលអាចត្រូវបានវាស់វែងយ៉ាងគួរអោយទុកចិត្តបាន ។ លក្ខខណ្ឌក្នុងការកត់ត្រាដ៏ជាក់លាក់ខាងក្រោមត្រូវតែបំពេញផងដែរមុនពេលដែលចំណូលត្រូវបានកត់ត្រា៖

● ការលក់ទឹកស្អាត

ចំណូលពីការផ្គត់ផ្គង់ទឹកត្រូវបានកត់ត្រាដោយទូទាត់អប្បហារ វិភាជន៍ និងឥណទាន ហើយត្រូវបានគេទទួលស្គាល់តាមបរិមាណទឹក ដែលបានផ្គត់ផ្គង់ទៅអោយអតិថិជនដែលទទួលស្គាល់ដោយរដ្ឋាករទឹក ។

●● ប្រាក់ចំណូលបានមកពីការតភ្ជាប់បណ្តាញទឹកជូនអតិថិជន

គឺបានមកពីការតភ្ជាប់បណ្តាញទឹកជូនអតិថិជនតាមផ្ទះទទួលស្គាល់នៅពេលបញ្ចប់ការតបណ្តាញទឹកនោះ។

### ខ២.១៦- ការទទួលស្គាល់ចំណូល (ត)

●●● ថ្លៃផ្លាស់ប្តូរនាឡិកាទឹក

ជារៀងរាល់ខែ រដ្ឋាករទឹកគិតថ្លៃ ៥០រៀលពីអតិថិជន សម្រាប់ថៃទាំនាឡិកាទំហំ ១មីលីម៉ែត្រ នៅក្នុងវគ្គ នៃការគិតប្រាក់ ហើយត្រូវបានកត់ត្រាជាប្រាក់ចំណូល ។ ការគិតប្រាក់នេះ ត្រូវបានប្រើទប់នឹងចំណាយក្នុងការផ្លាស់ប្តូរនាឡិកាទឹក នៅពេលប្រើប្រាស់លែងកើត ។ ចំណាយក្នុងការផ្លាស់ប្តូរ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល ។

●●●● ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផល ផ្អែកលើមូលដ្ឋានសមាមាត្រពេលវេលា ដោយប្រើរូបមន្តការប្រាក់ប្រសិទ្ធិភាព ។

### ខ២.១៧- ជំនួយពន្ធារ និងរំលស់

ជំនួយពន្ធារដែលទាក់ទិននិងថ្លៃដើមរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលផ្តល់ដោយម្ចាស់ជំនួយ ត្រូវបានកត់ត្រាតាមថ្លៃដើមនៅពេលទទួលបាន ។ ជំនួយពន្ធារ ដែលកត់ត្រានៅក្រោមបំណុលរយៈពេលវែង ដែលត្រូវបានកត់ត្រាខាងខ្ទង់ឥណទាននៅក្នុងរបាយការណ៍លទ្ធផល តាមមូលដ្ឋានថេរ ដើម្បីផ្គូផ្គងនឹងអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មនោះ ។

អត្ថប្រយោជន៍នៃឥណទានរបស់រដ្ឋាភិបាល តាមអត្រាប្តូររូបិយប័ណ្ណក្រោមតម្លៃទីផ្សារ ត្រូវបានចាត់ទុកជាអំណោយរបស់រដ្ឋាភិបាល អត្ថប្រយោជន៍នេះជាបម្រែបម្រួលដែលមានអំណោយផលល្អ រវាងតម្លៃរូបិយប័ណ្ណរបស់ឥណទាន (សិទ្ធិក្នុងការដកប្រាក់ជាពិសេស "SDR" ) និងរូបិយប័ណ្ណទូទាត់សងវិញរបស់រដ្ឋាទឹកជាប្រាក់រៀល ។

# ខ.៣- ការគ្រប់គ្រងហានិភ័យ

### ខ៣.១- ហានិភ័យផ្នែកហិរញ្ញវត្ថុ

រដ្ឋាករទឹក ត្រូវប្រឈមមុខនឹងហានិភ័យអត្រាការប្រាក់ ហានិភ័យឥណទាន ហានិភ័យរូបិយប័ណ្ណ និងហានិភ័យសាច់ប្រាក់ងាយស្រួល ។ រដ្ឋាករទឹកគ្រប់គ្រង និងសន្ទុតហានិភ័យទាំងនេះ ដោយការត្រួតពិនិត្យបំរែបំរួលការប្រាក់លើទីផ្សារ ប្រវត្តិឥណទាននៃភាគីទាក់ទិនរបស់ខ្លួន អត្រាប្តូររូបិយប័ណ្ណ និងលំហូរសាច់ប្រាក់ ។ បច្ចុប្បន្ននេះ រដ្ឋាករទឹកមិនទិញការ ការពារហានិភ័យទេ ។ រដ្ឋាករទឹកមិនបានកាន់កាប់ ឬបង្កើតឧបករណ៍និទស្សន៍នោះទេ ។

• ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលការប្រែប្រួលការប្រាក់លើទីផ្សារនាពេលអនាគត នឹងធ្វើអោយប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់រដ្ឋាករទឹក ។ ហានិភ័យអត្រាការប្រាក់ពាក់ព័ន្ធជាចំបងទៅ នឹងប្រាក់កម្ចី និងការវិនិយោគរយៈពេលខ្លី ។

ហានិភ័យអត្រាការប្រាក់របស់រដ្ឋាករទឹក កើតឡើងពីកម្ចីរយៈពេលវែង ។ ប្រាក់កំចីដែលរដ្ឋាករទឹកបានខ្ចីមានអត្រាការប្រាក់ប្រែប្រួលបណ្តាលអោយមានហានិភ័យអត្រាការប្រាក់ចំពោះលំហូរសាច់ប្រាក់របស់រដ្ឋាករទឹក ។ ប្រាក់កម្ចីដែលមានការប្រាក់ថេរ នឹងធ្វើអោយរដ្ឋាករទឹកមានហានិភ័យអត្រាការប្រាក់ចំពោះតំលៃទីផ្សារ នៃអត្រាការប្រាក់នោះ ។

ការប្រឈមមុខប្រាក់កំចីរបស់រដ្ឋាករទឹក លំហូរសាច់ប្រាក់មានហានិភ័យអត្រាការប្រាក់គឺកម្ចីមានពីភ្នាក់ងារអភិវឌ្ឍន៍បារាំង ហើយហានិភ័យអត្រាការប្រាក់តំលៃទីផ្សារ គឺកម្ចីមានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មិនមានវិធានការផ្លាស់ប្តូរ ឬទិញការ ការពារអត្រាការប្រាក់ (Swaps or other hedges) ត្រូវបានធ្វើឡើងនោះទេ ដោយគណៈគ្រប់គ្រងជឿជាក់ថាហានិភ័យអត្រាការប្រាក់នឹងមិនជះ លទ្ធផលជាសារវន្តនោះទេ ។

រដ្ឋាករទឹកថៃរក្សាអត្រាការប្រាក់ថេរលើវិនិយោគទុនរយៈពេលខ្លី និងកម្ចីទៅអោយរដ្ឋាករទឹកខេត្តពោធិ៍សាត់ វាដូចគ្នាទៅនឹងកម្ចីបានពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលពឹងផ្អែកទៅលើអត្រាថេរ ។

## ខ.៣.១- ហានិភ័យផ្នែកហិរញ្ញវត្ថុ

### •• ហានិភ័យការប្តូររូបិយប័ណ្ណ

រដ្ឋាករទឹក ត្រូវប្រឈមមុខនឹងហានិភ័យការផ្លាស់ប្តូររូបិយប័ណ្ណបរទេស Euro ដោយសារប្រាក់កំចីពីទីភ្នាក់ងារ អភិវឌ្ឍន៍បារាំង ជារូបិយប័ណ្ណ Euro តែការកត់ត្រាគណនីជារូបិយប័ណ្ណរៀល ។ គណៈគ្រប់គ្រងមិនបានបង្ការហានិភ័យ ឬចុះកុងត្រាជាមួយភាគីផ្សេងទៀតដើម្បីបង្ការហានិភ័យនាពេលខាងមុខ ដោយសារតែគណៈគ្រប់-គ្រងជឿជាក់ថាផល ប៉ះពាល់នៃការប្រែប្រួលរូបិយប័ណ្ណមិនមានលក្ខណៈជាសារវន្ត ។

### ••• ហានិភ័យឥណទាន

ហានិភ័យឥណទានរបស់រដ្ឋាករទឹក ភាគច្រើនទាក់ទងនឹងគណនីអតិថិជន និងសាច់ប្រាក់នៅក្នុងធនាគារ ។

ដើម្បីគ្រប់គ្រងហានិភ័យលើគណនីអតិថិជន រដ្ឋាករទឹកតម្រូវអោយមានប្រាក់កក់មុននឹងភ្ជាប់បណ្តាញទឹក ។ ប្រាក់កក់មិនតំរូវអោយមានសំរាប់ស្ថាប័នរដ្ឋនោះទេ ព្រោះថារដ្ឋាករទឹកជឿជាក់ថាអាចប្រមូលពីស្ថាប័នទាំងអស់នោះតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ គោលការណ៍កាត់បន្ថយប្រាក់កក់ គឺអនុវត្តទៅលើអតិថិជនដែលមិនបានទូទាត់សងបំណុលរបស់ពួកគេទៅតាមលក្ខខណ្ឌនៃកិច្ចសន្យាជាវទឹក និង លក្ខខណ្ឌផ្សេងៗ ។ ជាធម្មតារដ្ឋាករទឹកប្រឈមមុខនឹងហានិភ័យឥណទានលើគណនីអតិថិជននូវតម្លៃនៅសល់របស់ អតិថិជនដកសំវិធានធនលើបំណុលដែលខូច និងប្រាក់កក់របស់អតិថិជន ។

ដើម្បីកាត់បន្ថយហានិភ័យឥណទានសាច់ប្រាក់ក្នុងធនាគារ រដ្ឋាករទឹកបានបែងចែកប្រាក់កក់នៅធនាគារធំៗ និងមានកេរ្តិ៍ឈ្មោះផ្សេងៗគ្នាដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### •••• ហានិភ័យសាច់ប្រាក់ងាយស្រួល

រដ្ឋាករទឹកប្រឈមមុខនឹងហានិភ័យសាច់ប្រាក់ងាយស្រួល ដែលកើតឡើងនៅក្នុងការបង្វិលសាច់ប្រាក់ ជាទូទៅក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួន ។ វារួមបញ្ចូលនូវហានិភ័យដែលអាចនឹងធ្វើអោយរដ្ឋាករទឹកមិនមានលទ្ធភាពក្នុងការបង្វិលសាច់ប្រាក់ក្នុងសកម្មភាពអាជីវកម្មរបស់ខ្លួនអោយទាន់ពេលវេលា ។ ជានិច្ចកាលរដ្ឋាករទឹក បានរក្សាទុកសាច់ប្រាក់ និង សាច់ប្រាក់សមមូលយ៉ាងគ្រប់គ្រាន់ ។

តារាងខាងក្រោមនេះ វិភាគអំពីបំណុលហិរញ្ញវត្ថុរបស់រដ្ឋាករទឹក ដោយដាក់តាមក្រុមកាលផុតកំណត់ ដោយផ្អែកតាមការិយបរិច្ឆេទដែលនៅសល់ គិតត្រឹមកាលបរិច្ឆេទតារាងតុល្យការ ធៀបនឹងកាលផុតកំណត់លើកិច្ចសន្យា ។ ចំនួនដែលបានបង្ហាញនៅក្នុងតារាងនេះ គឺជាលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាដែលមិនធ្វើអប្បហារ ។

| **បរិយាយ** | **ក្រោម១ឆ្នាំ** *(គិតជាពាន់រៀល)* | **ពី ១-២ឆ្នាំ** *(គិតជាពាន់រៀល)* | **ពី ២-៥ឆ្នាំ** *(គិតជាពាន់រៀល)* | **លើសពី ៥ឆ្នាំ** *(គិតជាពាន់រៀល)* |
|---|---|---|---|---|
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | | | | |
| កម្ចី | ១១.៥០៤.៩១៣ | ៤៦.៩៩៩.២២៣ | ១៨១.១៨០.៩៥៨ | ១៩៩.៣៥២.១៦១ |
| ការប្រាក់លើប្រាក់កម្ចី | ១១.៨២០.០៦៨ | ៣៦.៤២៥.៣៧៣ | ៧៤.៤៣៥.៨៨៦ | ៣៧.៥៨៨.៨៦៥ |
| ប្រាក់កក់របស់អតិថិជន | ៤០.២៧២.៨៦៦ | - | - | - |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងផ្សេងៗ | - | - | - | ២៤.៦០២.០៨៧ |
| **សរុប** | **៦៣.៥៧៩.៨៤៨** | **៨២.៩២៤.៥៩៦** | **២៥៥.៦១៦.៨៤៥** | **២១១.៥៤៣.១១២** |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | |
| កម្ចី | ៨.៧៥៨.៨៨៩ | ១០.០៦៩.៨៨៩ | ៣៩.៦៥០.៦០៣ | ៨៩.៥៣៩.៨៩០ |
| ការប្រាក់លើប្រាក់កម្ចី | ៦.២៥៨.៤០៧ | ៥.៩៧១.២១៣ | ១៥.៧២១.៣២៧ | ៣៨.៣៣២.៦៥៨ |
| ប្រាក់កក់របស់អតិថិជន | - | - | - | ២១.៨៥៩.៧៣៨ |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងផ្សេងៗ | ១៧.២៩៣.៥៩៥ | - | - | - |
| **សរុប** | **៣២.៣១០.៨៩៦** | **១៦.០៣៦.០៩៧** | **៥០.៣៧១.៩៣០** | **១៤៤.៧២៧.២៨៦** |

## ខ.៣.២- ការគ្រប់គ្រងហានិភ័យដើមទុន

ទិសដៅរបស់រដ្ឋាករទឹកក្នុងការគ្រប់គ្រងដើមទុនគឺដើម្បីការពារលទ្ធភាពរបស់ខ្លួន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីផ្តល់ផលប្រយោជន៍ជូនភាគហ៊ុនិក និងភាគពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុត ដើម្បីកាត់បន្ថយចំណាយដើមទុន ។

រដ្ឋាករទឹក មិនមានរក្សាទុកគោលការណ៍ជាក់លាក់ នៃអនុបាតបំណុលធៀបនឹងដើមទុននោះទេ ។ គោលការណ៍របស់រដ្ឋាករទឹក គឺរក្សាសាច់ប្រាក់ និងសាច់ប្រាក់សមមូលឲ្យបានគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការរបស់ខ្លួន និងប្រើប្រាស់កញ្ចប់ឥណទានដើម្បីបង់ការចំណាយវិនិយោគ ។ រដ្ឋាករទឹកតាមដានដើមទុន តាមមូលដ្ឋានអនុបាតបំណុលធៀបនឹងដើមទុន ។ អនុបាតនេះត្រូវបានគណនាដោយយកបំណុលសុទ្ធ ចែកនឹងទុនសរុប ។ បំណុលសុទ្ធ ត្រូវបានគណនាដោយយកប្រាក់កម្ចីសរុប (រាប់ទាំងប្រាក់កម្ចីរយៈពេលខ្លី និងប្រាក់កម្ចីរយៈពេលវែង នៅលើតារាងតុល្យការ ) ដកនឹងសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី ។ ដើមទុនសរុប ត្រូវបានគណនាដោយយកមូលធន ដែលបានបង្ហាញនៅលើតារាងតុល្យការ បូកនឹងបំណុលសរុប ។ អនុបាតបំណុលធៀបនឹងដើមទុន មានដូចខាងក្រោម:

| **បរិយាយ** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---|---|
| ប្រាក់កម្ចីសរុប | ១៩៤.៣៥១.៨៧៦ | ១៣៨.០១៤.២៦១ |
| ដក: សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងវិនិយោគរយៈពេលខ្លី | (១៥៨.៧៦៧.៦៦៥) | (១៣៦.៧៦៣.៨៨៧) |
| បំណុលសុទ្ធ | ៣៥.៥៨៤.២១១ | ១.២៥០.៣៧៤ |
| មូលធនសរុប | ៥៥២.៤២៨.៤៨១ | ៥១៥.៥៦៧.៥៧៣ |
| ដើមទុនសរុប | **៥៨៨.០១២.៦៩៣** | **៥១៦.៨១៧.៩៤៧** |
| **អនុបាតបំណុលធៀបនឹងដើមទុន** | ៦% | 0,២៤% |

## ខ.៣.៣- ការប៉ានស្មានតំលៃទីផ្សារ

វិធីសាស្ត្រ និងការសន្មតដែលបានប្រើប្រាស់ក្នុងការប៉ានស្មានតំលៃទីផ្សារនៃឧបករណ៍ហិរញ្ញវត្ថុ:

• សាច់ប្រាក់ និងសាច់ប្រាក់សមមូល និងការវិនិយោគរយៈពេលខ្លី: តម្លៃនៅសល់នៃគណនីទាំងនេះ មានតំម្លៃប្រហាក់ប្រហែលនឹងតំលៃទីផ្សារ ដោយសារវាមានរយៈពេលខ្លី ។

•• គណនីអតិថិជន និងគណនីអ្នកផ្គត់ផ្គង់: តម្លៃនៅសល់នៃគណនី ដកសំវិធានធនខាតបង់ មានតម្លៃប្រហាក់ប្រហែលនឹងតំលៃទីផ្សារ ដោយសារគណនីទាំងនេះស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា និងដោយសារវាមានរយៈ ពេលខ្លី ។

••• សមតុល្យអន្តរក្រុមហ៊ុន: តម្លៃនៅសល់នៃឥណទាននេះ មានតម្លៃប្រហាក់ប្រហែលនឹងតំលៃទីផ្សារ ដោយសារវាមានរយៈពេលខ្លី ។

•••• កម្ចី តម្លៃទីផ្សារនៃកំចី គឺការប៉ាន់ស្មានលំហូរសាច់ប្រាក់អប្បហានាពេលអនាគត ដោយប្រើប្រាស់អត្រាការប្រាក់ដែលទទួលស្គាល់នាចុងឆ្នាំ ។

# ខ.៤- ការប៉ាន់ស្មានគណនេយ្យ ការសន្មត និងការវិនិច្ឆ័យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានគេវាយតំលៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ ។ រដ្ឋាករទឹកធ្វើការប៉ាន់ស្មានគណនេយ្យ កំរដូចគ្នានឹងលទ្ធផលពិតជាក់ស្តែងណាស់ ។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលមានហានិភ័យជាដុំកំភួន អាចបណ្តាលអោយមាននិយ័តកម្មជាសារវន្ត លើតំលៃនៅសល់នៃទ្រព្យសកម្ម និងទ្រព្យអកម្មក្នុងឆ្នាំបន្ទាប់ មានបង្ហាញដូចខាងក្រោមៈ

## ខ.៤.១- ពន្ធ

ពន្ធត្រូវបានគេគណនា តាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទបញ្ញាតិពន្ធដារ ។ ទោះជាយ៉ាងណាក៏ដោយ បទបញ្ញត្តិទាំងអស់នេះមានការផ្លាស់ប្តូរពីមួយគ្រាទៅមួយគ្រា ហើយការសំរេចជាចុងក្រោយលើចំនួនពន្ធនឹងធ្វើឡើង បន្ទាប់ពីមានការត្រួតពិនិត្យចុងក្រោយដោយអាជ្ញាធរពន្ធដារ ។

នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង ភាពលំអៀងនេះ នឹងធ្វើអោយប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធន លើពន្ធពន្យារនៅក្នុងការិយបរិច្ឆេទដែលការកំណត់ពន្ធបានធ្វើឡើង ។

## ខ.៤.២- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

គណនេយ្យកម្មនៃគណនីទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាក់ទិននឹងការប្រើប្រាស់ការប៉ាន់ស្មានក្នុងការកំណត់អាយុកាលប្រើប្រាស់រំពឹងទុក និង តម្លៃសំណល់នៃទ្រព្យសកម្មទាំងនោះ ។ ការកំណត់អាយុកាលប្រើប្រាស់ និងតម្លៃសំណល់នៃទ្រព្យសកម្ម គឺផ្អែកលើការវិនិច្ឆ័យរបស់គណៈគ្រប់គ្រង ។ ក្នុងការវិនិច្ឆ័យ រដ្ឋាករទឹក បានវាយតម្លៃលើកត្តាមួយចំនួន ក្នុងចំណោមកត្តាជាច្រើន មានដូចជាការប្រើប្រាស់រំពឹងទុកនៃទ្រព្យសកម្ម លក្ខខណ្ឌដែលអាចប្រើបាន និង លក្ខខណ្ឌដែលមិនអាចប្រើបាន ដែលអាស្រ័យទៅលើកត្តាប្រតិបត្តិការ និងកត្តាបរិស្ថាន ព្រមទាំងភាពហួសសម័យ ទាំងផ្នែកបច្ចេកទេស និង ពាណិជ្ជកម្មដែលកើតពីបម្រែបម្រួល រឺ ការកែលម្អផ្នែកបច្ចេកវិទ្យា ។

## ខ.៤.៣- កាតព្វកិច្ចសោធននិវត្តន៍

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ គឺអាស្រ័យទៅតាមកត្តាមួយចំនួន ដែលត្រូវបានកំណត់តាមមូលដ្ឋានដែលពាក់ព័ន្ធនឹងការគណនាហានិភ័យ ដោយប្រើប្រាស់ការសន្មតមួយចំនួន ។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ចំណាយសុទ្ធសម្រាប់ប្រាក់សោធននិវត្តន៍ រួមមានអត្រាអប្បហារ អត្រាកំណើន ប្រាក់បៀវត្សអត្រាមរណៈ និងអត្រាបោះបង់ការងារ ។ បម្រែបម្រួលណាមួយលើការសន្មតទាំងនេះ នឹងធ្វើអោយប៉ះពាល់ដល់តម្លៃនៅសល់របស់កាតព្វកិច្ចសោធននិវត្តន៍នេះ ។

ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណ និង សញ្ញាប័ណ្ណរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា រដ្ឋាករទឹកបានប្រើប្រាស់អត្រាការប្រាក់តម្កល់មធ្យម នៃមូលនិធិដែលបានផ្ញើនៅធនាគារ ដែលបម្រុងទុកសម្រាប់សោធនិវត្តន៍ជាអត្រាអប្បហារ ដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាននាពេលអនាគត ដែលតម្រូវអោយមានសំរាប់ការទូទាត់កាតព្វកិច្ចសោធននិវត្តន៍ ។

# ខ- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ខ.៥- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខា

(នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១)

| បរិយាយ | ដីធ្លី (គិតជាពាន់រៀល) | សំណង់លើដី កាន់កាប់ (គិតជាពាន់រៀល) | គ្រឿងយន្ត (គិតជាពាន់រៀល) | បំពង់បង្ហូរទឹក (គិតជាពាន់រៀល) | បរិក្ខារ មន្ទីរពិសោធន៍ (គិតជាពាន់រៀល) | សង្ហារឹម និង បរិក្ខារការិយាល័យ (គិតជាពាន់រៀល) | បរិក្ខារអគ្គីសនី (គិតជាពាន់រៀល) | មធ្យោបាយ ដឹកជញ្ជូន (គិតជាពាន់រៀល) | វ៉ាន និង ឧបករណ៍ការដ្ឋាន (គិតជាពាន់រៀល) | អចលនៈទ្រព្យ នាឡិកាទឹក (គិតជាពាន់រៀល) | អចលនៈទ្រព្យ កំពុងផលិត (គិតជាពាន់រៀល) | សរុប (គិតជាពាន់រៀល) |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | | | | | | | | | | | | |
| ថ្លៃដើម | ៧៣.៦៤៣.១៨៤ | ១៥៤.៤៦៥.៦៥៩ | ៥៨.៥៣៥.៤២១ | ៣២០.៩៣៩.៥៩១ | ៩២៧.៦០២ | ៨.៦៤៦.២០២ | ៥៩.១១៩.៧៧១ | ៩.៦៨៧.៣០៧ | ៧.៣៦៣.៩៧៨ | ៣.៩៥៧.១០៤ | ២៤.២១៩.៤៩០ | ៧២១.៥០៥.៣១០ |
| រំលស់បង្គរ | - | (២៦.០៦៤.៧៩៩) | (២៣.១០០.៨៦៣) | (៧០.១៦៣.៨១១) | (៧១៣.៨៥៩) | (៥.៨៩៩.៨៨១) | (៤២.៧៣៤.៨៥២) | (៦.៩៥៣.៥៩៣) | (១.២៤៣.១៧៤) | (៣.៣០៩.៤៣១) | - | (១៨០.១៨៤.២៦៣) |
| **សមតុល្យចុងគ្រាសុទ្ធ** | **៧៣.៦៤៣.១៨៤** | **១២៨.៤០០.៨៦០** | **៣៥.៤៣៤.៥៥៨** | **២៥០.៧៧៥.៧៨០** | **២១៣.៧៤៤** | **២.៧៤៦.៣២១** | **១៦.៣៨៤.៩១៩** | **២.៧៣៣.៧១៤** | **៦.១២០.៨០៥** | **៦៤៧.៦៧៣** | **២៤.២១៩.៤៩០** | **៥៤១.៣២១.០៤៨** |
| **ក្នុងគ្រា ឆ្នាំ២០១១** | | | | | | | | | | | | |
| តំលៃបញ្ជីសុទ្ធដើមគ្រា | ៧៣.៦៤៣.១៨៤ | ១២៨.៤០០.៨៦០ | ៣៥.៤៣៤.៥៥៨ | ២៥០.៧៧៥.៧៨០ | ២១៣.៧៤៤ | ២.៧៤៦.៣២១ | ១៦.៣៨៤.៩១៩ | ២.៧៣៣.៧១៤ | ៦.១២០.៨០៥ | ៦៤៧.៦៧៣ | ២៤.២១៩.៤៩០ | ៥៤១.៣២១.០៤៨ |
| បូកបន្ថែម និង កែតំរូវ | - | ៥៦៥.៩៦៤ | ៣១៨.៦៣៥ | ៥.៣៨៤.៩៦២ | ៤.៧៩៤ | ៦៩៥.៣៤២ | - | ៤.០៣៩.០៦២ | ៣៦៥.៣៧២ | ៣១២.៧៥៤ | ១០០.៤៧៧.៧៨៤ | ១១២.១៦៤.៦៧០ |
| លុបចេញពីបញ្ជី | - | - | - | - | - | (៥.៥១៣) | - | - | - | - | - | (៥.៥១៣) |
| អ. អន់គុណភាព | - | - | (៧៨.១៦១) | - | - | (១១.៥១៩) | - | - | - | - | - | (៨៩.៦៨០) |
| រំលស់ | - | (៣.៣៦១.៩២៧) | (៣.០៧៨.៤៩៧) | (៨.៣២៤.៦១៨) | (៦១.០០៤) | (៧១៨.៦៧២) | (៣.៤៨៤.១៤២) | (១.០១៨.៤៦០) | (៧៣៧.៣៥៣) | (២២០.១០៧) | - | (២១.០០៤.៧៧៩) |
| **សមតុល្យចុងគ្រាសុទ្ធ** | **៧៣.៦៤៣.១៨៤** | **១២៥.៦០៤.៨៩៧** | **៣២.៥៩៦.៥៣៦** | **២៤៧.៨៣៦.១២៤** | **១៥៧.៥៣៤** | **២.៧០៥.៩៦០** | **១២.៩០០.៧៧៧** | **៥.៧៥៤.៣១៦** | **៥.៧៤៨.៨២៥** | **៧៤០.៣២០** | **១២៤.៦៩៧.២៧៥** | **៦៣២.៣៨៥.៧៤៧** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | | | | | | | | | | | | |
| ថ្លៃដើម | ៧៣.៦៤៣.១៨៤ | ១៥៥.០៣១.៦២៣ | ៥៨.៤៨៣.៣៤៧ | ៣២៦.៣២៤.៥៥៣ | ៩១៣.១១៨ | ៦.៩៩០.០៨៩ | ៥៩.១១៩.៧៧១ | ១២.៩៨៧.១៤១ | ៧.៧២៩.៣៥១ | ៤.២៦៩.៨៥៨ | ១២៤.៦៩៧.២៧៥ | ៨៣០.០៩៩.៣០៩ |
| រំលស់បង្គរ | - | (២៩.៤២៦.៧២៧) | (២៥.៨៨៦.៨១១) | (៧៨.៤៨៨.៤២៩) | (៧៥៥.៥៨៥) | (៤.២៨៤.១២៩) | (៤៦.២១៨.៩៩៤) | (៧.១៤២.៨២៤) | (១.៩៨០.៥២៦) | (៣.៥២៩.៥៣៨) | - | (១៩៧.៧១៣.៥៦៣) |
| **សមតុល្យចុងគ្រាសុទ្ធ** | **៧៣.៦៤៣.១៨៤** | **១២៥.៦០៤.៨៩៧** | **៣២.៥៩៦.៥៣៦** | **២៤៧.៨៣៦.១២៤** | **១៥៧.៥៣៤** | **២.៧០៥.៩៦០** | **១២.៩០០.៧៧៧** | **៥.៧៥៤.៣១៦** | **៥.៧៤៨.៨២៥** | **៧៤០.៣២០** | **១២៤.៦៩៧.២៧៥** | **៦៣២.៣៨៥.៧៤៧** |

# ខ.៦- ទ្រព្យសកម្មអរូបី

| បរិយាយ | កម្មវិធីកុំព្យូទ័រ (គិតជាពាន់រៀល) |
|---|---|
| គិតត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ | |
| ថ្លៃដើម | ១.១១៦.៦៤២ |
| រំលស់បង្គរ | (៣៦៨.០២៩) |
| តម្លៃចុះបញ្ជីសុទ្ធ | ៧៤៨.៦១៣ |
| ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | |
| សមតុល្យដើមគ្រា | ៧៤៨.៦១៣ |
| ការទិញបន្ថែម | ៤២៤.៦៨០ |
| រំលស់ទៅក្នុងរបាយការណ៍លទ្ធផល | (១៧៦.៤៩២) |
| តម្លៃចុះបញ្ជីសុទ្ធ | ៩៩៦.៨០១ |
| គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | |
| ថ្លៃដើម | ១.៥៤១.៣២២ |
| រំលស់បង្គរ | (៥៤៤.៥២១) |
| តម្លៃចុះបញ្ជីសុទ្ធ | ៩៩៦.៨០១ |
| ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | |
| សមតុល្យដើមគ្រា | ៩៩៦.៨០១ |
| ការទិញបន្ថែម | ២៧១.៨១៥ |
| រំលស់ទៅក្នុងរបាយការណ៍លទ្ធផល | (២៣៤.៧១១) |
| តម្លៃចុះបញ្ជីសុទ្ធ | ១.០៣៣.៩០៤ |
| គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ | |
| ថ្លៃដើម | ១.៨១៣.១៣៥ |
| រំលស់បង្គរ | (៧៧៩.២៣២) |
| តម្លៃចុះបញ្ជីសុទ្ធ | ១.០៣៣.៩០៤ |

# ខ.៧- ការបែងចែកឧបករណ៍ហិរញ្ញវត្ថុតាមប្រភេទ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| ទ្រព្យសកម្មហិរញ្ញវត្ថុ | | |
| គណនីអតិថិជនពាណិជ្ជកម្ម និងគណនីអតិថិជនផ្សេងៗ | ២៤.៣៦៧.៨៣១ | ២០.៨៧៥.៩៩៩ |
| ឥណទានផ្តល់ឲ្យរដ្ឋាករទឹកខេត្តពោធិ៍សាត់ | ៧៦៥.៦១២ | ៨១៤.៩១៥ |
| ការវិនិយោគរយៈពេលខ្លី | ១៥១.៧៩៩.៩២៧ | ១២៩.៦៩៧.១៣៥ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៦.៩៦៧.៧៣៨ | ៧.០៦៦.៧៥២ |
| **សរុប** | **១៨៣.៩០១.១០៨** | **១៥៨.៤៥៨.៣០១** |
| បំណុលហិរញ្ញវត្ថុ | | |
| គណនីអ្នកផ្គត់ផ្គង់ពាណិជ្ជកម្ម និងគណនីអ្នកផ្គត់ផ្គង់ផ្សេងៗ | **៤០.២៧២.៨៦៦** | ១៧.២៩៣.៥៩៥ |
| ប្រាក់កម្ចី | **១៩៤.៣៥១.៨៧៦** | ១៣៨.០១៤.២៦១ |
| ប្រាក់កក់របស់អតិថិជន | **២៤.៦០២.០៨៧** | ២១.៨៥៤.៧៣៨ |
| **សរុប** | **២៥៩.២២៦.៨២៩** | **១៧៧.១៦២.៥៩៤** |

## ខ.៨- ឥណទានផ្តល់អោយរដ្ឋាករទឹកខេត្តពោធិ៍សាត់

| បរិយាយ | ៣១/១២/២០១១ *(គិតជាពាន់រៀល)* | ៣១/១២/២០១០ *(គិតជាពាន់រៀល)* |
|---|---|---|
| - កម្ចីរយៈពេលខ្លី | ៦៨.០០៤ | ៥០.១៤៩ |
| - កម្ចីរយៈពេលវែង: កាលកំណត់សង | | |
| ឥណទានរយៈពេលវែងត្រូវទទួលក្នុងរយៈពេលពី ១ឆ្នាំ ទៅ ២ឆ្នាំ | ១៦៧.២១៩ | ៦២.៦៦៨ |
| ឥណទានរយៈពេលវែងត្រូវទទួលក្នុងរយៈពេល ពី ២ឆ្នាំ ទៅ ៥ឆ្នាំ | ៥៣០.៣៩០ | ២៣៩.៦៨៨ |
| ឥណទានរយៈពេលវែងត្រូវទទួលក្នុងរយៈពេល លើសពី ៥ឆ្នាំ | - | ៤៣៥.៩១០ |
| សរុបកម្ចីរយៈពេលវែង | ៦៩៧.៦០៩ | ៧៦៨.២៦៦ |
| **ប្រាក់កម្ចីទៅអោយរដ្ឋាករទឹកខេត្តពោធិ៍សាត់** | **៧៦៥.៦១២** | **៨១៨.៤១៥** |

កម្ចី ទៅរដ្ឋាករទឹកខេត្តពោធិសាត់ (ហៅកាត់ថា PWSA) ត្រូវបានធ្វើឡើងជាប្រាក់ដុល្លាអាមេរិក ដោយយោងតាមកិច្ចសន្យាខ្ចីប្រាក់ដែលបានចុះហត្ថលេខា ដោយរដ្ឋាករទឹក និង PWSA នៅថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ២០០៨ មានតំលៃ ២៨៩.១៩២ ដុល្លាអាមេរិក (ប្រហែលជា ១.១៥៦លានរៀល) ។ គោលបំណងនៃកម្ចីនេះគឺដើម្បីសាងសង់ប្រព័ន្ធទឹក នៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ដែលត្រូវកសាង និងបញ្ចប់ដោយរដ្ឋាករទឹក ក្នុងខែមករា ឆ្នាំ២០០៩ ។ កំចីនេះ មិនមានទ្រព្យសកម្មធានានោះទេ ហើយមានអត្រាការប្រាក់ ៥%ក្នុងមួយឆ្នាំ ហើយរយៈកាល កំណត់សងគឺប្រចាំខែ គិតចាប់ពីថ្ងៃដែលប្រព័ន្ធ គ្រប់គ្រងទឹកត្រូវបានបញ្ចប់ និងអនុម័តដោយភាគីទាំងពីរ ។ កំចីនេះ នឹងត្រូវសងដោយ PWSA ក្នុងរយៈពេល ១២០ខែ គឺសងរំលស់ដោយយោងទៅតាមតារាងសងប្រាក់ដែលបាន ដាក់ចេញក្នុងមាត្រា G នៃកិច្ចសន្យាខ្ចីប្រាក់ ។

## ខ.៩- ពន្ធលើប្រាក់ចំណេញត្រូវទទួល/(ត្រូវបង់)

| បរិយាយ | ៣១/១២/២០១១ *(គិតជាពាន់រៀល)* | ៣១/១២/២០១០ *(គិតជាពាន់រៀល)* |
|---|---|---|
| នាថ្ងៃទី១ ខែមករា | ១.៦៤៣.៨១៨ | (១៣៦.២៩០) |
| ចំណាយពន្ធលើប្រាក់ចំណេញត្រូវបង់ក្នុងឆ្នាំ | (៦.៤១០.៦៥៧) | (៤.១៣១.០៣៩) |
| ពន្ធបានបង់ក្នុងឆ្នាំ | ៤.៣២៩.១៧៤ | ៥.៩១១.១៤៧ |
| **សរុបរួម** | **(៤៣៧.៦៦៣)** | **១.៦៤៣.៨១៨** |

ពន្ធលើប្រាក់ចំណេញត្រូវទទួល យោងមកពីការបង់ពន្ធលើស នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ នៃពន្ធលើប្រាក់ចំណេញកាលពីឆ្នាំមុន ។ រដ្ឋាករទឹកជឿជាក់ថា មានភស្តុតាងគ្រប់គ្រាន់ ដែលអាចយកបានមក វិញនូវចំនួនទឹកប្រាក់ដែលបង់លើស ក្នុងពេលដែលធ្វើការស៊ើបអង្កេតពន្ធ ។

# ខ.១០- សន្និធិ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| គ្រឿងបន្លាស់ បំពង់ចែកចាយ និងគ្រឿងបំពាក់បំពងផ្សេងទៀត | ២១.៩១២.៩៧០ | ១២.៧២២.២០៦ |
| នាឡិកាទឹក | ២.១៩៦.៣០៤ | ៣.២០៣.៦១៨ |
| គ្រឿងបន្លាស់ និងឧបករណ៍ | ២.៤៦០.៩៩៩ | ១.៨៧៨.៨១៨ |
| ជាតិគីមីផ្សេងៗ | ១៧៥.៧៣៦ | ១.០៣៨.៨៩២ |
| គ្រឿងយន្ត និងបរិក្ខារ | ៦៧៦.៩៤៧ | ៩២៦.៦៨៥ |
| ធុង និងគ្រឿងវេចខ្ចប់ផ្សេងៗ | ១០០.២១៦ | ២៤៩.១៦៥ |
| វត្ថុធាតុដើម និងបរិក្ខារផ្សេងៗ | ១.១៨៥.០៧០ | ៧២១.៨១០ |
| ដក: សំវិធានធនសំរាប់ការខាតបង់តំលៃសារពើភ័ណ្ឌ | (៦៩.១២១) | (៦៩.៣៨៥) |
| សរុបរួម | ២៨.០៨៨.៥៧១ | ២០.១៧៦.៨១០ |

# ខ.១១- គណនីអតិថិជន និងផ្សេងៗ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| ថ្លៃលក់ទឹក ប្រភេទអង្គភាពរដ្ឋ | ២.៧៧៨.៩៦៥ | ២.៣៣០.៧៩២ |
| ថ្លៃលក់ទឹក ប្រភេទជីវភាព | ១.៧៥២.០៦១ | ១.៣៥៣.៥០២ |
| ថ្លៃលក់ទឹក ប្រភេទអាជីវកម្ម | ១.៣០៤.៨៩២ | ១.០២៥.៧៣៣ |
| ថ្លៃលក់ទឹក ប្រភេទអ្នកលក់ទឹក | ៥.៩៩៩ | ៩.៦៩៣ |
| ផ្សេងៗ | ៣.៨៩៧.៩៦២ | ៥១៥.៥១៣ |
| ដក: វិភាជន៍សំរាប់ឥណទេយ្យលើបំណុលសង្ស័យទារមិនបាន | (១២.២៩០) | (១០.៧៩៦) |
| គណនីអតិថិជន-សុទ្ធ | ៩.១៧៧.៥៨៩ | ៥.២២៤.៩៥១ |
| ចំណូលបង្គរ | ១៩.៩០៦.១៦៩ | ១១.៩២៣.៩២៧ |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | ១៦.៩០៥.១០៥ | ២៣.២៧៩.៧៨៩ |
| ការប្រាក់ត្រូវទទួល | ៣.៥០៩.៥៣៦ | ៣.៧៣០.៩៩៥ |
| ពន្ធលើតំលៃបន្ថែមត្រូវទទួល | ២១៧.៦៩៧ | ២២២.៨៩៧ |
| គណនីផ្សេងៗត្រូវទទួល | ៣៩.៥៣៨.៤៥៧ | ៣៩.១៥២.០៥៩ |
| សរុបរួម | ៤៣.៧១៦.០៤១ | ៤៤.៣៧៦.៤៩១ |

ចំណូលបង្គរដែលត្រូវទទួល គឺជាការលក់ទឹកបង្គរសំរាប់រយៈពេល ៩៧ថ្ងៃ ចុងក្រោយ (២០១០: រយៈពេល ៩២ថ្ងៃ) នៃឆ្នាំសារពើពន្ធ ។

អតិថិជនរបស់រដ្ឋាករទឹក រួមមាន ផ្ទះប្រជាជនធម្មតា ផ្ទះធ្វើអាជីវកម្ម និង ស្ថាប័នរដ្ឋ ។ មធ្យមភាគនៃរយៈពេលបំណុលត្រូវទារ សំរាប់ផ្ទះប្រជាជនធម្មតា និងផ្ទះធ្វើអាជីវកម្ម គឺស្ថិតក្នុងរយៈពេល២១ថ្ងៃ និង នាយកដ្ឋានរដ្ឋាភិបាល គឺស្ថិតក្នុងរយៈពេលមួយឆ្នាំ ។ គណៈគ្រប់គ្រងជឿជាក់ថារាល់អតិថិជនទាំងអស់ គឺអនុវត្តតាមរយៈពេលបំណុលត្រូវទារ លើកលែងតែចំពោះអ្នកដែលយើងបានកត់ត្រាសំវិធានធនខាងលើ ។

ដោយសារគណនី ត្រូវទទួលទាំងនេះមានរយៈពេលខ្លី ដូច្នេះតំលៃទីផ្សាររបស់វាគឺ ប្រហាក់ប្រហែលនឹងតំលៃ នៅសល់ហើយដកសំវិធានធនសំរាប់ការថយចុះនេះ ។ តំលៃគណនីអតិថិជននៅសល់ទាំងអស់ បានកំណត់ជាប្រាក់រៀល និងតម្លៃត្រូវទទួលផ្សេងៗទៀត ក៏ត្រូវ បានកំណត់ជាប្រាក់រៀលផងដែរ ។

## ខ.១២- ការវិនិយោគរយៈពេលខ្លី

គឺប្រាក់បញ្ញើរមានកាលកំណត់ ដែលបានផ្ញើរនៅគ្រឹះស្ថានហិរញ្ញវត្ថុ សំរាប់រយៈពេល ពី ៤ ទៅ ១២ខែ ហើយការប្រាក់ដែលទទួលបាន គឺក្នុងលំដាប់ពី៣,៧៥% ទៅ ៥% (២០១០: ៤,២៥% ទៅ ៦%) ក្នុងមួយឆ្នាំ។

## ខ.១៣- សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| បរិយាយ | ៣១/១២/២០១១ *(គិតជាពាន់រៀល)* | ៣១/១២/២០១០ *(គិតជាពាន់រៀល)* |
|---|---|---|
| សាច់ប្រាក់ក្នុងបេឡា | ៣៥៨.២១៥ | ៣១៩.៣៩១ |
| សាច់ប្រាក់ក្នុងធនាគារ | ៧.១០២.៦០៦ | ៦.៧៤៧.៣៦១ |
| **សរុបរួមបេឡាក្នុងដៃ និងនៅធនាគារ** | **៧.៤៦០.៨២១** | **៧.០៦៦.៧៥២** |

សាច់ប្រាក់ក្នុងធនាគារ មានដូចជាគណនីចរន្ត គណនីសន្សំ និងប្រាក់បញ្ញើមានកាលកំណត់ ក្នុងពេលបីខែ ឬតិចជាងនេះតំកល់នៅធនាគារក្នុងស្រុក ។ ប្រាក់បញ្ញើមានកំណត់ទទួលបានការប្រាក់មានអត្រាពី ៣,៧៥% ទៅ ៥% (២០១០: ៤,២៥% ទៅ ៦%)។

## ខ.១៤- ដើមទុន

| បរិយាយ | ៣១/១២/២០១១ *(គិតជាពាន់រៀល)* | ៣១/១២/២០១០ *(គិតជាពាន់រៀល)* |
|---|---|---|
| សមតុល្យដើមគ្រា គិតត្រឹមថ្ងៃទី០១ ខែមករា | ៤៥៦.០០០.២៦៤ | ៤៥៦.០០០.២៦៤ |
| ការផ្ទេរមកពីជំនួយរបស់រាជរដ្ឋាភិបាល និងជំនួយផ្សេងៗទៀត | ៩.០២៧.៨៦៥ | - |
| **សរុបរួម** | **៤៦៥.០២៨.១២៩** | **៤៥៦.០០០.២៦៤** |

មាត្រា៦នៃអនុក្រិត្យស្តីពីការបង្កើតរដ្ឋាករទឹកបានចែងថា: ដើមទុនដំបូងនៃរដ្ឋាករទឹក ស្វយ័តក្រុងភ្នំពេញ នឹងត្រូវកំណត់ដោយតារាងតុល្យការដំបូង ដែលបានឯកភាពដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាលាក្រុងភ្នំពេញ និងរដ្ឋាករទឹក ។ មាត្រា៧ នៃលក្ខន្តិកៈរដ្ឋាករទឹកចែងថាការបន្ថែមដើមទុនអាចជាសាច់ប្រាក់ សំភារៈ រឺទុនបំរុង ឬការបង់វិភាគទានខាតពីរដ្ឋ ។ ការបន្ថែមដើមទុន ត្រូវសំរេចដោយក្រុមប្រឹក្សាភិបាល និងត្រូវយល់ព្រមដោយរដ្ឋមន្រ្តីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ អាជ្ញាធរទទួលការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្ទេរជំនួយ ដើមទុនបំរុង និង មូលនិធិផ្សេងៗ ទៅក្នុងដើមទុន ដោយសារវាមានភាពចាំបាច់ សំរាប់អត្ថប្រយោជន៍នៃប្រតិបត្តិការ

## ខ.១៥- ទុនបម្រុង

ចំណេញរក្សាទុក ដែលបានយោងមកពីនាដើមឆ្នាំ ត្រូវបានផ្ទេរចូលក្នុងទុនបំរុងដោយយោងតាមមាត្រា២៩ នៃលក្ខន្តិកៈរដ្ឋាករទឹក និងអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់កាតព្វកិច្ច អោយរដ្ឋាករទឹកបង់ប្រាក់ ១០% នៃប្រាក់ចំណេញប្រចាំឆ្នាំរបស់ខ្លួន ទៅអោយក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ តាមលិខិតលេខ ២២៥៤ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០០៨ មានប្រសិទ្ធិភាពសំរាប់ប្រាក់ចំណេញដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ តទៅ ។

# ខ.១៥- ទុនបម្រុង (ត)

| បរិយាយ | ទុនបំរុង (គិតជាពាន់រៀល) | ទុនបំរុងផ្នែកច្បាប់ (គិតជាពាន់រៀល) | ទុនបំរុងទូទៅ (គិតជាពាន់រៀល) | ទុនបំរុងសំរាប់ការថែរក្សា និងអភិវឌ្ឍន៍ (គិតជាពាន់រៀល) | សរុប (គិតជាពាន់រៀល) |
|---|---|---|---|---|---|
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ | ១.៦៤៨.៤៣៥ | ៥.០០៦.៥៨៨ | ៥.០០៦.៥៨៨ | ១៦.២៦៤.២៨០ | ៥.៣៩៧.៣៣១ |
| ប្តូកបន្ថែម | - | ១.៣៤៦.៦៨៧ | ១.៣៤៦.៦៨៧ | ២៤.២៤០.៣៦០ | ២៦.៩៣៣.៧៣៤ |
| ចំណាយបំរើសង្គម | - | - | - | (៥៧៦.៧៣៥) | (៥៧៦.៧៣៥) |
| ចំណេញបង់ចូលរដ្ឋ | - | - | - | (២.៦៩៣.៣៧៣) | (២.៦៩៣.៣៧៣) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | **១.៦៤៨.៤៣៥** | **៦.៣៥៣.២៧៥** | **៦.៣៥៣.២៧៥** | **១៤.៧០៥.៩៧១** | **២៩.០៦០.៩៥៧** |
| នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ | ១.៦៤៨.៤៣៥ | ៦.៣៥៣.២៧៥ | ៦.៣៥៣.២៧៥ | ១៤.៧០៥.៩៧១ | ២៩.០៦០.៩៥៧ |
| ប្តូកបន្ថែម | | ១.៥២៥.៣១៨ | ១.៥២៥.៣១៨ | ២៧.៤៥៥.៧១៧ | ៣០.៥០៦.៣៥២ |
| ចំណេញបង់ចូលរដ្ឋ | - | - | - | (៣.០៥០.៦៣៥) | (៣.០៥០.៦៣៥) |
| ចំណាយបំរើសង្គម | - | - | - | (១.១០៦.២២៩) | (១.១០៦.២២៩) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | **១.៦៤៨.៤៣៥** | **៧.៨៧៨.៥៩២** | **៧.៨៧៨.៥៩២** | **៣៨.០០៤.៨២៦** | **៥៥.៤១០.៤៤៥** |

# ខ.១៦- ប្រាក់កម្ចី

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("WB") ឥណទានលេខ 3746KH | ៣២.១៦០.០៨០ | ១៩.៣២៤.៣៨៧ |
| កម្ចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("ADB")ឥណទានលេខ 1468 CAM (SF) | ៣៩.១៦៧.៦៦៧ | ៣៩.១៦៧.៦៦៧ |
| កម្ចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ("AFD") ឥណទានលេខ CKH 6000 01G | ៤៦.៣៧៥.៤៩៨ | ៥៤.៦១១.៥៦០ |
| កម្ចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ("AFD") ឥណទានលេខ CKH 1075 03S | ២០.២៦១.៩៥០ | ៧.១៥៧.៩៨០ |
| កម្ចីពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ("JICA") ឥណទានលេខ CP-P9 | ៥៦.៣៨៦.៦៨១ | ១៧.៧៥២.៦៦៦ |
| **សរុបរួម** | **១៩៤.៣៥១.៨៧៦** | **១៣៨.០១៤.២៦១** |

បំរែបំរួលប្រាក់កំចីមានដូចខាងក្រោម:

| បរិយាយ | WB 3041KH (ពាន់រៀល) | WB 3746KH (ពាន់រៀល) | ADB (ពាន់រៀល) | AFD CKH6000 01G (ពាន់រៀល) | AFD CKH1075 03s (ពាន់រៀល) | JICA CP-P9 (ពាន់រៀល) | សរុប (ពាន់រៀល) |
|---|---|---|---|---|---|---|---|
| ០១/០១/២០១០ | ៦.៦៦៣.៦៨៤ | ១៨.៩០៤.៤៧៤ | ៣៩.១៦៧.៦៦៧ | ៥៥.៨៩៦.០៥១ | - | - | ១២០.៦៣១.៨៧៦ |
| បន្ថែម | - | ២.១៦៣.៧៥២ | - | ២.០៩៣.០៤២ | ៧.១៥៧.៩៨០ | ១៧.៧៥២.៦៦៦ | ២៩.១៦៧.៤៤០ |
| ការសងប្រាក់ | (៦.៦៦៣.៦៨៤) | (១.៧៤៣.៨៣៨) | - | (៣.៣៧៧.៥៣២) | - | - | (១១.៧៨៥.០៥៥) |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | **-** | **១៩.៣២៤.៣៨៧** | **៣៩.១៦៧.៦៦៧** | **៥៤.៦១១.៥៦០** | **៧.១៥៧.៩៨០** | **១៧.៧៥២.៦៦៦** | **១៣៨.០១៤.២៦១** |
| ០១/០១/២០១១ | - | ១៩.៣២៤.៣៨៧ | ៣៩.១៦៧.៦៦៧ | ៥៤.៦១១.៥៦០ | ៧.១៥៧.៩៨០ | ១៧.៧៥២.៦៦៦ | ១៣៨.០១៤.២៦១ |
| បន្ថែម | - | ១៥.៥៧៥.៩៥៥ | - | - | ១៤.៧៧៨.៧៣៣ | ៣៨.៩៤៥.៥៤៩ | ៦៩.៣០០.២៣៧ |
| កែតម្រូវអត្រា | - | - | - | (១.១៦៣.៩១៥) | (១.៦៧៤.៧៦៣) | (៣១១.៥៣៥) | (៣.១៥០.២១៣) |
| ការសងប្រាក់ | - | (២.៧៤០.២៦២) | - | (៧.០៧២.១៤៦) | - | - | (៩.៨១២.៤០៨) |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | **-** | **៣២.១៦០.០៧៩** | **៣៩.១៦៧.៦៦៧** | **៤៦.៣៧៥.៤៩៨** | **២០.២៦១.៩៥០** | **៥៦.៣៨៦.៦៨១** | **១៩៤.៣៥១.៨៧៦** |

# ខ- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

## ខ.១៦- ប្រាក់កម្ចី (ត)

(នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១)

| លក្ខខណ្ឌកំចី | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារពិភពលោក) ឥណទានលេខ ៣០៤១KH | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារពិភពលោក) ឥណទានលេខ ៣៧៤៦KH និង ជំនួយលេខ H០៣៤KH | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារអភិវឌ្ឍន៍អាស៊ី) ឥណទានលេខ ១៤៦៨CAM | កំចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ក្រោមកិច្ចសន្យា ឥណទានលេខ CKH ៦០០០ ០១G | កំចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ក្រោមកិច្ចសន្យា ឥណទានលេខ CKH ១០៧៥ ០៣s | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA) ឥណទានលេខ CP-P៩ |
|---|---|---|---|---|---|---|
| ថ្ងៃចុះកិច្ចសន្យា | ថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៩៨ | ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៣ | ថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៧ | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ | ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៩ | ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ |
| គំរោង | គំរោងផ្គត់ផ្គង់ទឹកនៅទីក្រុង | គម្រោងផ្គត់ផ្គង់ និងអនាម័យទឹកស្អាតនៅតាមខេត្ត និងជុំវិញទីក្រុង | គម្រោងផ្គត់ផ្គង់ និងអនាម័យទឹកស្អាតនៅតាមខេត្ត និងជុំវិញទីក្រុង | គម្រោងពង្រីកលទ្ធភាពរោងចក្រនៅជ្រោយ ចង្វា (ដំណាក់កាលទី២) និងគម្រោង ពង្រីកបណ្តាញចែកចាយរបស់ រដ្ឋាករទឹក ។ | ការសាងសង់រោងចក្រនៅនិរោធ៍ និង ពង្រីកការបញ្ជូន និងចែកចាយ បណ្តាញរបស់រដ្ឋាករទឹកអោយស្រប ទៅនឹងផលិតកម្មបន្ថែមនេះ ។ | សាងសង់រោងចក្រផលិតទឹកស្អាតនៅសង្កាត់និរោធន៍ |
| អត្រាការប្រាក់ | ៨,៥% ក្នុង១ឆ្នាំ | ៨,៥% ក្នុង១ឆ្នាំ | ៦,៥% ក្នុង១ឆ្នាំ | មិនមានករណីដែលតិចជាងអត្រា ០,២៥% ឬសំរាប់រយៈពេល៦ខែ នៃអត្រា EURIBOR ដក ១,៣៥% ក្នុង ១ឆ្នាំ ។ | នៅអត្រា EURIBOR ដក ១.៣៥%។ មិនមានករណីដែលតិចជាង អត្រា ០,២៥% ឬមិនលើសពី ៥,២១% ។ | អត្រាការប្រាក់ថេរ ៧,៥០% ក្នុង ០១ឆ្នាំ ។ |
| ការធានា | គ្មាន | គ្មាន | គ្មាន | លិខិតទទួលស្គាល់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។ | លិខិតទទួលស្គាល់ពីក្រសួងសេដ្ឋ កិច្ច និងហិរញ្ញវត្ថុ និង ក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល ។ | គ្មាន |
| ចំនួនទឹកប្រាក់បំរុង | សិទ្ធិការដកប្រាក់ជាពិសេស ("SDR") ១៨.៩៥០.០០០ | កំចី: SDR ៣.៩៤០.០០០ និង ជំនួយ: SDR ២០០.០០០ | SDR ៩.៦០៥.០០០ (ប្រហាក់ប្រហែល ៣៨.២៩៩.៩៣៧.៥០០៛) | ចំនួនអតិបរមា Euro ១១.១០០.០០០ | ចំនួនអតិបរមា Euro ១៦.០០០.០០០ | ចំនួនអតិបរមា ៣.៥១៣.០០០.០០០យ៉េន ប្រហែល ៣៧.៩៧១.១៥៣ ដុល្លាអាមេរិក |

| លក្ខខណ្ឌកំចី | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារពិភពលោក) ឥណទានលេខ ៣០៤១KH | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារពិភពលោក) ឥណទានលេខ ៣៧៤៦KH និង ជំនួយលេខ H០៣៨KH | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ធនាគារអភិវឌ្ឍន៍អាស៊ី) ឥណទានលេខ ១៩៦៨CAM | កំចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ក្រោមកិច្ចសន្យា ឥណទានលេខ CKH ៦០០០ ០១G | កំចីពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ក្រោមកិច្ចសន្យា ឥណទានលេខ CKH ១០៧៥ ០៣s | កំចីពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA) ឥណទានលេខ CP-P៩ |
| --- | --- | --- | --- | --- | --- | --- |
| តារាងការសងប្រាក់ | ទូទាត់សងបណ្តាក់ជា ៣៩ដង រៀងរាល់ថ្ងៃទី ១៥ ខែមិនា និងថ្ងៃទី១៥ ខែកញ្ញា ក្នុងឆ្នាំ សារពើពន្ធនីមួយៗ និង ចាប់ផ្តើមសងនៅ ថ្ងៃទី១៥ ខែមិនា ឆ្នាំ២០០៣ រហូតដល់ថ្ងៃ ទី១៥ ខែកញ្ញា ឆ្នាំ២០១៩ ។ ក៏ប៉ុន្តែនៅថ្ងៃទី ១៧ ខែមិនា ឆ្នាំ២០០៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានយល់ព្រំទទួលការសង មុនពេលកំណត់ ។ កម្ចីនេះត្រូវបានសងផ្តាច់ នៅក្នុង ឆ្នាំ២០១០ ។ | បង់រំលស់២៩ដង ដែលត្រូវនឹងថ្ងៃ ទី១៥ ខែមករា និងថ្ងៃទី១៥ ខែ កក្កដា នៅក្នុងឆ្នាំសារពើពន្ធនីមួយៗ ហើយចាប់ផ្តើមសងនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩ ។ | សងបណ្តាក់ជា ៦០ដងរៀងរាល់ ថ្ងៃទី១៥ ខែមករា និងថ្ងៃទី១៥ ខែកក្កដា នៅក្នុងឆ្នាំសារពើពន្ធ នីមួយៗ និងចាប់ផ្តើមសងនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១២ និង បញ្ចប់នៅថ្ងៃទី ១៥ខែកក្កដាឆ្នាំ២០៤១ | បង់រំលស់២០ដង រៀងរាល់ពាក់កណ្តាល ឆ្នាំម្តង ហើយត្រូវ ចាប់ ផ្តើមសងពីថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ២០០៩ រហូត ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ។ | បង់រំលស់១៦ដង រៀងរាល់ពាក់ កណ្តាលឆ្នាំម្តង ចាប់ផ្តើមនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ និងបញ្ចប់នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២១ | ទូទាត់សងបណ្តាក់ជា២៩ដង រៀងរាល់ថ្ងៃទី២០ ខែកញ្ញា និងថ្ងៃទី២០ ខែមិនា នៅក្នុងឆ្នាំសារពើពន្ធនីមួយៗ និង ចាប់ផ្តើមសងនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៤ និងបញ្ចប់នៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០២៦ |
| ព័ត៌មានដែលទាក់ទងផ្សេងៗ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាអ្នកទទួលនូវ ហានិភ័យ នៃការប្តូររូបិយប័ណ្ណបរទេស ដែលរងពីការប្រែប្រួល រវាងតំលៃ នៃកំចី រូបិយប័ណ្ណដុល្លារអាមេរិក និង រូបិយប័ណ្ណ នៃការសងប្រាក់ដោយរដ្ឋាករទឹកជារៀល ។ | លទ្ធផលហានិភ័យការប្តូររូបិយប័ណ្ណបរទេសបានពីការប្រែប្រួលរវាងតំលៃនៃកំចីរូបិយប័ណ្ណជា ដុល្លារ អាមេរិក និងរូបិយប័ណ្ណនៃ ការសងប្រាក់ដោយរដ្ឋាករ ទឹកជារៀល នឹងត្រូវធានា ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | គ្មាន | អត្រាការប្រាក់ប្រែប្រួល ត្រូវប្តូរជាអត្រាការប្រាក់ថេរ ១.៤៩% បន្ទាប់ពីថ្ងៃផុតកំណត់នៃការដកប្រាក់ដើម ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ | អត្រាការប្រាក់ប្រែប្រួលត្រូវបានប្តូរជាអត្រាការប្រាក់ថេរ បន្ទាប់ពីថ្ងៃផុត កំណត់នៃការដកប្រាក់ដើមថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៣ ។ | ប្រាក់កំចីនេះត្រូវផុតកំណត់នៃការដកប្រាក់ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ។ ប្រាក់ កំចីបន្តពីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានកំណត់ជារូបិយប័ណ្ណដុល្លាអាមេរិកតាមអត្រាប្តូរប្រាក់ពី JICA ។ រ.ទ.ស.ភ ត្រូវសងប្រាក់ដើម និងការប្រាក់ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជារៀល ទៅតាមប្រាក់ដើមបានដកនីមួយៗ នៅអត្រាប្តូរប្រាក់មធ្យមរបស់ NBC ។ |

# ខ.១៧- បំណុលពន្ធពន្យារលើប្រាក់ចំណេញ

| **បរិយាយ** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---:|---:|
| ពន្ធពន្យាទ្រព្យសកម្ម | (៤.៧៩៩.១៤៤) | (៣.៧៥៤.៦៩៧) |
| ពន្ធពន្យាទ្រព្យអកម្ម | ២១.៧៣៤.៨៥៣ | ១៩.០៣៤.១៧៧ |
| សរុប | **១៦.៩៣៥.៧០៩** | **១៥.២៧៩.៤៨០** |
| បំរែបំរួលពន្ធពន្យារលើប្រាក់ចំណេញ មានដូចខាងក្រោម: | | |
| ដើមឆ្នាំ | ១៥.២៧៩.៤៨០ | ១១.៧៣៩.២៩៣ |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល | ១.៦៥៦.២២៩ | ៣.៥៤០.១៨៧ |
| **ដំណាច់ឆ្នាំ** | **១៦.៩៣៥.៧០៩** | **១៥.២៧៩.៤៨០** |

បំរែបំរួលពន្ធពន្យារទ្រព្យសកម្ម និងពន្ធពន្យារទ្រព្យអកម្មក្នុងឆ្នាំ ដោយមិនទូទាត់ក្នុងយុត្តាធិការតែមួយមានដូចខាងក្រោម:

## ពន្ធពន្យារទ្រព្យសកម្ម

| **បរិយាយ** | **ផលប្រយោជន៍សោធនិវត្តន៍** *(គិតជាពាន់រៀល)* | **សំវិធានធនសំរាប់ការខាតបង់តំលៃសារពើភ័ណ្ឌ** *(គិតជាពាន់រៀល)* | **សំវិធានធនលើបំណុលសង្ស័យ** *(គិតជាពាន់រៀល)* | **ផ្សេងៗ** *(គិតជាពាន់រៀល)* | **សរុប** *(គិតជាពាន់រៀល)* |
|---|---:|---:|---:|---:|---:|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩** | ៣.២៧២.៦០៤ | ១៣.២៧៦ | ២.១៤៩ | ៩១១.៧៧៧ | ៤.១៩៩.៨០៧ |
| ចូលក្នុងរបាយការណ៍នៃបន្ទុកចំណាយ ២០០៩ | ៧៩៦.៩៥៩ | (៣៩៩) | - | (១.២៤១.៦៧០) | ៤៤៥.១១០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | ៤.០៦៩.៥៦៣ | ១២.៨៧៧ | ២.១៤៩ | (៣២៩.៨៩៣) | ៣.៧៥៤.៦៩៧ |
| ចូលក្នុងរបាយការណ៍នៃបន្ទុកចំណាយ ២០១១ | ៨៥០.៦៤២ | ៩៤៧ | ២៩៩ | ១៩២.៥៥៩ | ១.០៤៤.៤៤៧ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | **៤.៩២០.២០៦** | **១៣.៨២៤** | **២.៤៤៨** | **(១៣៧.៣៣៤)** | **៤.៧៩៩.១៤៤** |

ទ្រព្យអកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ទៅតាមទំហំនៃផលប្រយោជន៍ពន្ធដែលអាចទទួលបាននាពេលអនាគត ហើយផលប្រយោជន៍ពន្ធទាំងនេះ គឺអាចកើតមានឡើង ។

## ទ្រព្យអកម្មពន្ធពន្យារ

| **បរិយាយ** | **រំលស់ពន្ធ** *(គិតជាពាន់រៀល)* |
|---|---:|
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ | ១៥.៩៣៩.១០១ |
| ឥណពន្ធចូលទៅរបាយការណ៍លទ្ធផល | ៣.០៩៥.០៧៦ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០ | ១៩.០៣៤.១៧៧ |
| ឥណពន្ធចូលទៅរបាយការណ៍លទ្ធផល | ២.៧០០.៦៧៧ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | **២១.៧៣៤.៨៥៣** |

# ខ.១៨- កាតព្វកិច្ចសោធននិវត្តន៍

⊙ ចំនួនដែលត្រូវបានគេកត់ត្រាក្នុងរបាយការណ៍តុល្យការ ត្រូវបានកំណត់ដូចខាងក្រោម:

| **បរិយាយ** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---|---|
| តំលៃបច្ចុប្បន្ននៃកាតព្វកិច្ចមូលនិធិ | ២៤.៦០១.០២៨ | ២០.៣៤៧.៨១៦ |
| តំលៃទីផ្សារនៃទ្រព្យសកម្មគំរោង | - | - |
| ស្ថានភាពអធន | ២៤.៦០១.០២៨ | ២០.៣៤៧.៨១៦ |
| **បំណុលសុទ្ធបានកត់ត្រាក្នុងតារាង តុល្យការ** | **២៤.៦០១.០២៨** | **២០.៣៤៧.៨១៦** |

⊙ បម្រែបម្រួលនៅក្នុងទ្រព្យអកម្មដែលត្រូវបានកត់ត្រាក្នុងតារាងតុល្យការ មានដូចខាងក្រោម:

| **បរិយាយ** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---|---|
| គិតត្រឹមថ្ងៃទី០១ ខែមករា | ២០.៣៤៧.៨១៦ | ១៦.៣៦៣.០២២ |
| ថ្លៃដើមនៃសេវាកម្មបច្ចុប្បន្ន | ៩៦០.៧៦៥ | ៧០៨.៤៨៥ |
| ចំណាយការប្រាក់ | ៩៩៣.៧២៨ | ៩២៤.៤៣២ |
| អត្ថប្រយោជន៍សោធននិវត្តន៍ដែលបានបង់ | (៤៧០.៤៨៦) | (៤១១.៩៩៩) |
| ការខាតបង់ពាក់ព័ន្ធនឹងការគណនាហានិភ័យ | ២.៧៦៩.២០៤ | ២.៧៦៣.៨៧៦ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ** | **២៤.៦០១.០២៨** | **២០.៣៤៧.៨១៦** |

### ខ.១៨.១

វិភាគទានផ្សេងទៀតតំណាងវិភាគទានរបស់បុគ្គលិក ៧% នៃប្រាក់បៀវត្សប្រចាំខែ វិភាគទានរបស់រដ្ឋាករទឹក ៥% នៃប្រាក់បៀវត្សប្រចាំខែរបស់បុគ្គលិក និងការប្រាក់ទទួលបានពីមូលនិធិសោធននិវត្តន៍ ដែលផ្ញើ នៅធនាគារ ។

### ខ.១៨.២

តំលៃសេវាកម្មបច្ចុប្បន្ន មានបង្ហាញក្នុង ប្រាក់បៀវត្ស ប្រាក់ឈ្នួល និងចំណាយទាក់ទិន ។

### ខ.១៨.៣

នៅក្នុងរបាយការន៍ហិរញ្ញវត្ថុ រដ្ឋាករទឹកមិនបានធ្វើការគណនា និងកត់ត្រានូវកាតព្វកិច្ចសោធនិវត្តន៍អោយបាន ពេញលេញសំរាប់សេវាកម្មដែលត្រូវបានបំពេញដោយនិយោជិត ដោយប្រើការសន្មតដែលសមរម្យ ដូចជាអត្រា បញ្ចុះតំលៃ អត្រាតម្លើងប្រាក់បៀវត្សនាពេលអនាគត អត្រាតម្លើងប្រាក់សោធនិវត្តន៍នាពេលអនាគត និងអត្រា មរណៈភាពជាដើម ។ រដ្ឋាករទឹកកត់ត្រាប្រាក់បំរុងសោធនិវត្តន៍ ដោយផ្អែកលើអត្រាវិភាគទានថេរ ។ សំវិធានធន បែបនេះ មិនបានគណនាតាមកាតព្វកិច្ចជាក់ស្តែង ដែលបុគ្គលិកចូលនិវត្តន៍នឹងត្រូវទូទាត់នាពេលអនាគតនោះទេ ។ តាមយោបល់របស់រដ្ឋាករទឹក គឺពុំអាចរកឃើញនូវសម្មតិកម្ម ដែលមានលក្ខណៈដ៏គួរអោយជឿជាក់ ដោយ ផ្អែកទៅលើកំរិតនៃប្រព័ន្ធបច្ចុប្បន្ន និងបរិស្ថានទីផ្សារក្នុងស្រុក នាពេលបច្ចុប្បន្ននេះទេ ។ ទោះជាយ៉ាងណារដ្ឋាករទឹក ជឿជាក់ថា ការធ្វើវិភាគទានក្រោមផែនការសោធននិវត្តន៍សព្វថ្ងៃនេះ គឺគ្រប់គ្រាន់ដើម្បីបំពេញនូវកាតព្វកិច្ច ។

### ខ.១៨.៤

តំលៃទីផ្សារនៃទ្រព្យសកម្មគំរោង គឺជាប្រាក់បញ្ញើមានកាលកំណត់ នៅគ្រឹះស្ថានហិរញ្ញវត្ថុក្នុងស្រុក ។

# ខ.១៩- ជំនួយពន្យារពីរាជរដ្ឋាភិបាល

| បរិយាយ | ជំនួយទីភ្នាក់ងារ អភិវឌ្ឍន៍បារាំង *(គិតជាពាន់រៀល)* | ជំនួយរដ្ឋាភិបាល *(គិតជាពាន់រៀល)* | ជំនួយផ្សេងទៀត *(គិតជាពាន់រៀល)* | សរុប *(គិតជាពាន់រៀល)* |
|---|---|---|---|---|
| - សមតុល្យ នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ | ៨.៨០៨.៩៧៦ | ៦.៥០៨.៣៩១ | ១.៥៦៩.០៥៧ | ១៦.៨៨៦.៤២៤ |
| - កើនឡើងក្នុងឆ្នាំ | - | - | ៩៤៥.០០៧ | ៩៤៥.០០៧ |
| - រំលស់លើទ្រព្យសកម្មអរូបិយ | (២៩២.៧៦៧) | (៤៣៤.៨៤៦) | (៤៣៥.៩៤៤) | (១.១៦៣.៥៥៦) |
| - កែតំរូវលើជំនួយ ភ.អ.បា | - | ១០៧.៧៣៧ | - | ១០៧.៧៣៧ |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០** | **៨.៥១៦.២០៩** | **៦.១៨១.២៨២** | **២.០៧៨.១២១** | **១៦.៧៧៥.៦១១** |
| | | | | |
| - សមតុល្យ នាថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ | ៨.៥១៦.២០៩ | ៦.១៨១.២៨២ | ២.០៧៨.១២១ | ១៦.៧៧៥.៦១១ |
| - កើនឡើងក្នុងឆ្នាំ | - | - | - | - |
| - រំលស់លើទ្រព្យសកម្មអរូបិយ | | (៥៦៣.៩២០) | (១០០.៦៣៣) | (៦៦៤.៥៥៥) |
| - កែតំរូវលើជំនួយ ភ.អ.បា | - | ៤៧៣.៦២៣ | (២១.១៤៨) | ៤៥២.៤៧៦ |
| - ផ្ទេរទៅមូលធន | (៨.០៥៨.៩១១) | - | (៩៦៨.៩៥៣) | (៩.០២៧.៨៦៥) |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១** | **៤៥៧.២៩៨** | **៦.០៩០.៩៨៤** | **៩៨៧.៣៨៥** | **៧.៥៣៥.៦៦៧** |

### ជំនួយពីទីភ្នាក់ងារអភិវឌ្ឍន៍បារាំង

តាមរយៈអនុសញ្ញាដែលត្រូវបានចុះហត្ថលេខា ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD) ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង រដ្ឋាករទឹកបានចុះកិច្ចព្រមព្រៀងទទួលជំនួយ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នឹងផ្តល់ឧបត្ថម្ភធនដល់រដ្ឋាករទឹក នូវជំនួយរហូតដល់ទឹកប្រាក់ចំនួន ៤.០០០.០០០អឺរ៉ូ (ប្រមាណនឹង ២៣.៣១៤ លានរៀល ដើម្បីធ្វើហិរញ្ញប្បទានពង្រីកបណ្តាញផ្គត់ផ្គង់ទឹកបរិភោគ នៅតំបន់ភ្នំពេញ និងតំបន់ដែលពាក់ព័ន្ធ ។ ការផ្ទេរជំនួយទៅគណនីដើមទុន ត្រូវបានធ្វើឡើងយោងតាមលិខិតរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ៣៤៧ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ដែលជាភាគហ៊ុនិករបស់រដ្ឋាករទឹក ។

### ជំនួយពីរាជរដ្ឋាភិបាល

ជំនួយពីរាជរដ្ឋាភិបាល កើតឡើងមកពីការចំណេញលើភាពខុសគ្នា ក្នុងអត្រាដែលបានប្រើលើការទិញអចលន ទ្រព្យ និងអត្រាប្តូរប្រាក់ថេរក្រោមកិច្ចព្រមព្រៀងកម្ចីបន្តរវាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋាករទឹកនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៩៧ ដែលមានទឹកប្រាក់សរុបចំនួន ៩.៦៩៥.០០០SDR ពីធនាគារអភិវឌ្ឍន៍អាស៊ី ។ រដ្ឋាករទឹកបាន រក្សាទុកនូវចំណេញពីការប្តូរប្រាក់នេះក្នុងបញ្ជីដោយចាត់ទុកថាជាជំនួយ (ដោយសារគ្មានតំរូវការអោយបង្វិលចំណេញ នេះទេ)ហើយចំណេញនេះនឹងត្រូវរំលស់បន្តិចម្តងៗដោយផ្អែកលើគោលការណ៍ដូចគ្នាទៅនឹងជំនួយពន្យារផ្សេងៗដែរ ។

# ខ.២០- គណនីអ្នកផ្គត់ផ្គង់ និងផ្សេងៗ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| គណនីអ្នកផ្គត់ផ្គង់ | ២៥.០២២.៥៦៨ | ៧.២៦៧.៧៧៤ |
| ប្រាក់លើកទឹកចិត្តបុគ្គលិកដែលត្រូវបង់ | ២.៣៧៨.៥៥១ | ២.១០០.២៦៧ |
| អ្នកផ្គត់ផ្គង់: ទឹកប្រាក់ធានាត្រូវទូទាត់ | ៧.២៥០.០៥៩ | ២.៧៣៦.៥៣៤ |
| ការប្រាក់ដែលត្រូវបង់ | ៣.៥១៥.៥៣២ | ២.៣៩៦.៣៥២ |
| ទឹកប្រាក់ថៃទាំលូ | ១.៨៤៣.០២៦ | ១.៤៨៩.៧៨៣ |
| ចំណូលពន្យារ «ក» | ៦៤៥.០៤៥ | ៤៣៣.៦៧១ |
| សំភារ:សំរាប់ភ្ជាប់បណ្តាញតាមផ្ទះ | - | ២៧៦.៧៤៤ |
| ពន្ធផ្សេងៗដែលត្រូវបង់ | ២០៩.៤៦៥ | ៣៩៩.៥៥៩ |
| គណនីត្រូវបង់ផ្សេងទៀត | ៣.៤៩៣.៨៦៤ | ១.១៥៧.១៤៤ |
| **សរុប** | **៤៤.៣៥៨.១១១** | **១៨.២៥៧.៨៣០** |

ក» នេះជាសាច់ប្រាក់ដែលទទួលបានពីធនាគារពិភពលោក និង Maries Paris សំរាប់បណ្តាញថ្មីតាមផ្ទះ ប្រជាជនក្រីក្រ ។

# ខ.២១- ចំណូល

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| លក់ទឹកសំរាប់អ្នករស់នៅក្នុងស្រុកធម្មតា | ៥២.៤៩៣.៣០៣ | ៤៩.៥៣១.៨៦៨ |
| លក់ទឹកសំរាប់ពានិជ្ជកម្ម | ៤៣.៦៦៤.៥៦៧ | ៣៩.៨៧០.១០២ |
| លក់ទឹកសំរាប់ ស្ថាប័នសាធារណ: | ៥.៥០៩.២៣៣ | ៦.៣៣៣.៥៦៤ |
| លក់ទឹកសំរាប់ តំណាងចែកចាយ | ២១០.៥០៣ | ៣១២.១៤៣ |
| លក់ទឹកសំរាប់ អាជ្ញាធរស្វយ័ត | ៣១១.៩៩២ | ២៨៧.៥២៨ |
| ចំណូលបន្ថែមពីការលក់ទឹក (ទឹកប្រាក់បង្គ្រប់) | ២៦.៤០៥ | ២៥.៥៨៦ |
| ដក: ការលប់ចោលវិក្កយបត្រ និង ឥណទានដែលបានផ្តល់ | (១៧៥.២២៣) | (៣៣៧.០៧៩) |
| **សរុប** | **១០២.០៤០.៧៨០** | **៩៦.០២៤.១៧៧** |
| ចំណូលបានមកពីការតភ្ជាប់បណ្តាញទឹកតាមផ្ទះ | ៦.០៨៩.៥៥០ | ៤.៤៦៥.៥៥៣ |
| ចំណូលការផ្លាស់ប្តូរនាឡិកាទឹក | ១.៩៣៣.៤២៣ | ១.៨០៤.៦១២ |
| គ្រឿងបន្លាស់ និងការលក់នាឡិកាទឹក | ៥៩៦.៣០៤ | ៤១១.៨៥៥ |
| ចំណូលផ្សេងៗទៀត | ៣.៨៥២.៩៩១ | ២.៥៤២.៩៣៦ |
| ចំណូលរំពុកថ្លៃទឹក | ២០.៧៧៨ | ៦៧.៦៣២ |
| ចំណូលផាកពិន័យ | ៣៣៤.៤៥៣ | ២២៦.៧៧៤ |
| **សរុបរួម** | **១១៤.៨៦៨.២៧៩** | **១០៥.៥៤៣.៥៤០** |

## ខ.២២- វត្ថុធាតុដើមសម្រាប់ផលិតទឹកស្អាត

| **បរិយាយ** | **៣១/១២/២០១១**<br>*(គិតជាពាន់រៀល)* | **៣១/១២/២០១០**<br>*(គិតជាពាន់រៀល)* |
|---|---:|---:|
| ការប្រើប្រាស់ភ្លើងអគ្គិសនី | ២២.៨០៩.៦៩៨ | ២១.២២៣.៣០១ |
| សាច់ជូរ | ៣.០៨៧.៧៧២ | ២.៦៦៥.៣៧៧ |
| ឧស្ម័នក្លរ | ៨៩៤.៨៤៥ | ១.១០៤.៤៤៩ |
| កំបោរ | ៣៧៦.៨៦១ | ២៤៧.៦១៧ |
| វត្ថុធាតុដើមផ្សេងទៀត | ១០២.៧៧២ | ៩៤.៤៩១ |
| **សរុបរួម** | **២៧.២៧១.៩៤៨** | **២៥.៣៣៥.២៣៥** |

## ខ.២៣- ចំណាយលើប្រាក់បៀវត្សរ៍, ប្រាក់ឈ្នួល និង ចំណាយទាក់ទិន

| **បរិយាយ** | **៣១/១២/២០១១**<br>*(គិតជាពាន់រៀល)* | **៣១/១២/២០១០**<br>*(គិតជាពាន់រៀល)* |
|---|---:|---:|
| បៀវត្សរ៍និយោជិត | ៧.៥២១.៩៥០ | ៥.៩៧៣.៥៣៣ |
| ប្រាក់រង្វាន់លើកទឹកចិត្ត | ៣.៤៩៤.១០៩ | ៣.២៥៦.០៦៧ |
| ប្រាក់ឧបត្ថម និងប្រាក់លើសម៉ោងនិយោជិត | ១.៧២៧.២៥៣ | ១.៤៧៧.២៨២ |
| ប្រាក់រង្វាន់និងលើកទឹកចិត្តដំណាច់ឆ្នាំ | ១.៩៩៣.៧៧៥ | ១.៨៤០.៤០៥ |
| ប្រាក់ឈ្នួល និង មៅការ | ២៤២.៣៧៤ | ១៨៧.៣២៧ |
| វិភាគទានសោធននិវត្ត | ៣.៩៩១.៨៧៦ | ៤.៣៩៦.៧៩៣ |
| **សរុបរួម** | **១៨.៩៧១.៣៣៧** | **១៧.១៣១.៤០៧** |

## ខ.២៤- សម្ភារៈសម្រាប់តភ្ជាប់បណ្តាញទៅតាមផ្ទះ

| **បរិយាយ** | **៣១/១២/២០១១**<br>*(គិតជាពាន់រៀល)* | **៣១/១២/២០១០**<br>*(គិតជាពាន់រៀល)* |
|---|---:|---:|
| គ្រឿងបន្លាស់ សំរាប់តភ្ជាប់បណ្តាញទៅគេហដ្ឋាន | ៣.៥៩៣.៥៦២ | ២.៣០៥.៥៥៤ |
| ថ្លៃប្តូរនាឡិកាទឹកដល់អតិថិជន | ៧៨៣.៥៩៥ | ៥៧៩.៥០២ |
| ថ្លៃបំពង់តបណ្តាញចូលផ្ទះ | ១៥៦.៨២៩ | ១១៦.០៤៧ |
| ថ្លៃសំភារៈផ្សេងៗទៀត | ៥៩២.៨៧៧ | ៦៨៤.៩៣៥ |
| **សរុបថ្លៃដើមសំភារៈ** | **៥.១២៦.៨៦៣** | **៣.៦៨៦.០៣៨** |

# ខ.២៥- ចំណេញ/(ខាត) ពីការប្តូររូបិយប័ណ្ណ-សុទ្ធ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| ចំណាយការប្រាក់ | ៥.៦០០.៥៥៨ | ៤.៦០២.២៨២ |
| ចំណូលការប្រាក់ | (៦.៤៦២.០២០) | (៦.៥៥០.៤០០) |
| សរុបរួម | (៨៦១.៥៦២) | (១.៩៤៨.១១៨) |

ចំណាយនេះបង្ហាញពីការប្រាក់លើប្រាក់កម្ចីបន្តពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលផ្តល់មូលនិធិដោយ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង ។

# ខ.២៦- ចំណាយពន្ធលើប្រាក់ចំណេញ

ផ្អែកលើច្បាប់សារពើពន្ធឆ្នាំ១៩៩៧ រដ្ឋាករទឹកមានកាតព្វកិច្ចក្នុងការបង់ពន្ធណាមួយ ដែលខ្ពស់រវាងពន្ធលើប្រាក់ចំណេញ២០% រឺពន្ធអប្បបរមានៅអត្រា១% នៃចំណូលសរុប ។

## ខ.២៦.១- ពន្ធលើប្រាក់ចំណេញ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| ពន្ធលើប្រាក់ចំណេញចរន្ត | ៦.៤១០.៦៥៧ | ៤.១៣១.០៣៩ |
| ពន្ធពន្យារ | ១.៦៥៦.២៣០ | ៣.៥៤០.១៨៦ |
| សរុបរួម | ៨.០៦៦.៨៨៦ | ៧.៦៧១.២២៥ |

## ខ.២៦.២- ការផ្ទៀងផ្ទាត់រវាងពន្ធលើប្រាក់ចំណេញ និង ប្រាក់ចំណេញគណនេយ្យ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| ប្រាក់ចំណេញគណនេយ្យមុនបង់ពន្ធ | ៤០.០៥៦.៧៩៤ | ៣៨.១៧៧.៥៧៧ |
| ពន្ធលើប្រាក់ចំណេញ ២០% | ៨.០១១.៣៥៩ | ៧.៦៣៥.៥១៥ |
| ចំណាយមិនអាចកាត់កងសំរាប់ការគណនាពន្ធ | ៥៥.៥២៨ | ៣៥.៧១០ |
| ពន្ធលើប្រាក់ចំណេញ | ៨.០៦៦.៨៨៦ | ៧.៦៧១.២២៥ |

ពន្ធលើប្រាក់ចំណេញត្រូវបានគណនាតាមមូលដ្ឋានបំណកស្រាយបច្ចុប្បន្ននៃបទបញ្ញត្តិពន្ធ ។ ទោះបីជាយ៉ាងនេះក៏ដោយ បទបញ្ញត្តិទាំងនេះនៅតែមានភាពខុសប្លែកគ្នាតាមគ្រា ហើយការកំណត់ចុងក្រោយនៃពន្ធលើប្រាក់ចំណេញ នឹងត្រូវបានធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ ។

## ខ.២៧- សាច់ប្រាក់បានមកពីប្រតិបត្តិការ

| **បរិយាយ** | **កំណត់សម្គាល់** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---|---|---|
| ចំណេញសុទ្ធមុនបង់ពន្ធ | | ៤០.៥៧១.១៣០ | ៣៨.១៧៧.៥៧៨ |
| និយ័តកម្ម: | | | |
| រំលស់ | ៥ | ២១.០០៤.៧៧៩ | ២០.៣៥៩.៧៦៩ |
| Amortisation of intangible assets | | ២៣៤.៧១១ | ១៧៦.៤៩២ |
| រំលស់នៃជំនួយពន្យារពីរដ្ឋាភិបាល | ១៧ | (២១២.០៧៩) | (៧២២.៣៧៣) |
| ខាត លើការលក់ចេញអចលនទ្រព្យ | ៦ | ៩៥.១៩៣ | ២៤.៩២៤ |
| ចំណាយការប្រាក់ | | ៥.៦០០.៤៥៨ | ៤.៦០២.២៨២ |
| ចំណូលការប្រាក់ | | (៦៤៦២.០២០) | (៦.៥៥០.៤០០) |
| បំរែបំរួលទុនបង្វិល: | | | |
| សារពើភ័ណ្ឌ | | (៧.៩១១.៧៦១) | (១.៤៤៩.៥៨២) |
| គណនីអតិថិជន និងផ្សេងៗ | | ៣.៦៥៥.២៥៧ | (២៤.៧២៤.៣៦១) |
| គណនីអ្នកផ្គត់ផ្គង់ និងផ្សេងៗ | | ២១.៨៣២.៤២០ | (៣.៧១៦.៥២៣) |
| ប្រាក់កក់របស់អតិថិជន | | ២.៧៤៧.៣៤៩ | ២.០៩៤.៥៦២ |
| ប្រាក់សោធនិវត្តន៍ | | ៤.៦០៦.០៧៥ | ៤.៣៩៦.៧៩៣ |
| **សាច់ប្រាក់បានមកពីប្រតិបត្តិការ** | | **៨៥.១៨០.១៧៩** | **៤០.១០២.២០២** |

## ខ.២៨- ការសន្យាមូលធន

| **បរិយាយ** | **៣១/១២/២០១១** *(គិតជាពាន់រៀល)* | **៣១/១២/២០១០** *(គិតជាពាន់រៀល)* |
|---|---|---|
| សមាគមន៍អភិវឌ្ឍន៍អន្តរជាតិ (IDA) | | |
| បំពង់ជ័រ HDPE | - | ១៥.៨៤៨.៥៤៣ |
| សរុប | - | ១៥.៨៤៨.៥៤៣ |
| ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) "ឥណទាន" | | |
| ការសាងសង់រោងចក្រផលិតទឹកស្អាត នៅនិរោធន៍ | ៩០.៨៩១.៤១៥ | ១៣០.០៣៥.៥២០ |
| សរុប | ៩០.៨៩១.៤១៥ | ១៣០.០៣៥.៥២០ |
| ទីភ្នាក់ងារបារាំងសំរាប់អភិវឌ្ឍន៍ (AFD) "ឥណទាន" | | |
| ការសាងសង់រោងចក្រផលិតទឹកស្អាត | ៦០.៣៧១.៧៦៥ | ៣០.៤៥៨.២៣០ |
| សេវាពិគ្រោះយោបល់ | ៣.០៦២.២៨៤ | ៥.១៩៨.៩២៦ |
| សរុប | ៦៤.៤៣៤.០៤៩ | ៣៥.៦៥៧.១៥៦ |
| **សរុបរួម** | **១៥៤.៣២៥.៤៦៤** | **១៨១.៥៤១.២១៩** |

រយៈពេលនៃកិច្ចសន្យា ជាទូទៅ គឺចាប់ពី ៦ខែ ទៅ ២៤ខែ ដែលរដ្ឋាករទឹក ត្រូវបានតម្រូវអោយប្រតិបត្តិតាមកិច្ចព្រមព្រៀង និងលក្ខខ័ណ្ឌ ។

# ខ.២៩- ប្រតិបត្តិការភាគីសម្ព័ន្ធញាតិ

- រដ្ឋាករទឹក ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេស របស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋាករទឹកខេត្តពោធិ៍សាត់ ក៏ជាភាគីសម្ព័ន្ធញាតិរបស់រដ្ឋាករទឹកដែរ ដោយសាររដ្ឋាករទឹកខេត្តពោធិ៍សាត់ ក៏ស្ថិតក្រោមការគ្រប់គ្រងផ្នែកបច្ចេកទេស របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលដូចគ្នា ។

- ការទូទាត់សម្រាប់គណៈគ្រប់គ្រងសំខាន់ៗ និងក្រុមប្រឹក្សាភិបាល មានដូចខាងក្រោមៈ

| បរិយាយ | ៣១/១២/២០១១ (គិតជាពាន់រៀល) | ៣១/១២/២០១០ (គិតជាពាន់រៀល) |
|---|---|---|
| ប្រាក់បៀវត្ស ប្រាក់កម្រៃ និងចំណាយពាក់ព័ន្ធ | ៨៦៩.៣៩៣ | ៧៨៦.៧៧៦ |
| អត្ថប្រយោជន៍សោធននិវត្តន៍ | ៥.០៦១ | ១៦.២១៣ |
| **សរុបរួម** | **៨៧៤.៤៥៤** | **៨០២.៩៨៩** |

## ក្រាហ្វិចបង្ហាញពីអត្រាចំណាយដំណើរការសហគ្រាស ឆ្នាំ២០១១







# របាយការណ៍លទ្ធផល ការងារគ្រប់គ្រង និង អភិវឌ្ឍន៍ធនធានមនុស្ស

ផ្អែកលើសំណូមពរចាំបាច់នៃការអភិវឌ្ឍធនធានមនុស្ស និងដើម្បីបង្កើនគុណភាព ប្រសិទ្ធភាពការងាររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញចាំបាច់ត្រូវរៀបគម្រោងផែនការច្បាស់លាស់ ដោយមានការសហការ ឧបត្ថម្ភពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធ្វើឲ្យ រ.ទ.ស.ភ មានសមត្ថភាពកាន់តែប្រសើរឡើង ក្នុងការកែសម្រួលចំណុចសំខាន់ៗដូចខាងក្រោម៖

- រៀបចំឲ្យមានមណ្ឌលបណ្តុះបណ្តាល និងដំណើរការជាបណ្តើរៗ ចាប់ពីឆ្នាំ១៩៩៧ ដែលមានគោលការណ៍៖
  - កំណត់នូវគោលការណ៍ស្តីពីការបញ្ជូនមន្ត្រី និយោជិតទៅទទួលការបណ្តុះបណ្តាល ។
  - ស្វែងរកគ្រូបណ្តុះបណ្តាលនៅតាមវិទ្យាស្ថាននានា ទាំងក្នុង និងក្រៅប្រទេស សម្រាប់បណ្តុះបណ្តាលជំនាញដល់មន្ត្រី និយោជិត រ.ទ.ស.ភ ។
  - សហការជាមួយម្ចាស់ជំនួយក្នុងការស្នើ និងបញ្ជូនមន្ត្រីទៅទទួលការបណ្តុះបណ្តាលជំនាញចាំបាច់នៅក្រៅប្រទេស ។
- ពីឆ្នាំ២០០៥ រហូតដល់បច្ចុប្បន្នមណ្ឌលបណ្តុះបណ្តាលនេះបានដំណើរការពេញសមត្ថភាពដោយបានរៀបចំឲ្យមានគ្រូបង្គោលក្នុងអង្គភាពសម្រាប់ដំណើរការបណ្តុះបណ្តាលជំនាញ សម្រាប់និយោជិតថ្នាក់ក្រោម ដោយផ្តោតជាសំខាន់ទៅលើការបណ្តុះបណ្តាល ទាក់ទងនឹងការអនុវត្តការងារជាក់ស្តែង (បែបបទដំណើរការងារស្តង់ដាការងារ "SOP" ) ។
- បានធ្វើការកែសម្រួលនូវការវាយតម្លៃមន្ត្រី-និយោជិតតាមរយៈព្រឹត្តប័ត្រពិន្ទុប្រចាំខែ មកប្រចាំត្រីមាសក្នុងឆ្នាំ២០០៥ រហូតមកដល់បច្ចុប្បន្ន ។
- ខែមិថុនា ឆ្នាំ២០០៧ រ.ទ.ស.ភ បានរៀបចំឲ្យមានការប្រឡងសមត្ថភាពប្រចាំឆ្នាំ ។ ការប្រឡងសមត្ថភាពនេះ បានអនុវត្តសម្រាប់មន្ត្រី-និយោជិត រហូតដល់ប្រធានការិយាល័យ ដើម្បីឲ្យឃើញពីសមត្ថភាព និងការយល់ដឹងក្នុងការអនុវត្តការងារ ។
- បានរៀបចំបែបបទនៃការតំឡើងឋានៈ ការតំឡើងកាំបៀវត្សរ៍ តំឡើងបៀវត្សរ៍ លើកសរសើរប្រចាំឆ្នាំទៅតាមលទ្ធផលនៃការប្រឡងសមត្ថភាព និងលទ្ធផលនៃការវាយតម្លៃតាមរយៈព្រឹត្តិប័ត្រពិន្ទុប្រកបដោយតម្លាភាព ។

# ក- ការងារគ្រប់គ្រង

ក្នុងឆ្នាំ២០១១ នេះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមាន មន្ត្រីនិយោជិតទាំងអស់ចំនួន ៦០៧រូប (នារី: ៩២រូប) ក្នុងនោះមាន៖

- មន្ត្រីក្របខ័ណ្ឌរដ្ឋ ០២រូប គឺ ឯកឧត្តមប្រតិភូ និងប្រធាននាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ
- មន្ត្រី និយោជិតក្របខ័ណ្ឌសហគ្រាសចំនួន ៥៤៦រូប ( នារី: ៨៥រូប )
- កម្មសិក្សាការីចំនួន ១២រូប ( នារី:០១រូប )
- និយោជិតជាប់កិច្ចសន្យាចំនួន ៤៧រូប ( នារី: ០៦រូប )

## កម្រិតជំនាញរបស់មន្ត្រី និយោជិត

| កំរិតអប់រំ និងមុខវិជ្ជាជីវៈ | អាយុ ក្រោម ២៦ឆ្នាំ | អាយុ ២៧-៣៤ | អាយុ ៣៦-៤៥ | អាយុ លើស ពី៤៦ | សរុប ចំនួន( នាក់) | អត្រា (%) |
|---|---|---|---|---|---|---|
| បណ្ឌិត | ០ | ០ | ០ | ១ | ១ | ០,១៦ |
| អនុបណ្ឌិត | ០ | ៩ | ៨ | ១០ | ២៧ | ៦,៤៥ |
| បរិញ្ញាប័ត្រ / វិស្វករ | ១៧ | ៧០ | ២៧ | ១១ | ១២៥ | ២០,៥៩ |
| បរិញ្ញាប័ត្ររង/មធ្យមបច្ចេកទេស | ៤ | ៤ | ២១ | ៧ | ៣៦ | ៥,៩៣ |
| មធ្យមសិក្សាទុតិយភូមិ និងទទួលការបណ្តុះបណ្តាលរយៈពេលខ្លី | ៥៦ | ៣៩ | ៤១ | ១៤ | ១៥០ | ២៤,៧១ |
| អ្នកបច្ចេកទេស និង កម្មករជំនាញ | ០ | ១២ | ៩ | ១២ | ៣៣ | ៥,៤៤ |
| អ្នកមានបទពិសោធន៍ការងារលើ១០ឆ្នាំ | ០ | ១១ | ៤៣ | ៧៣ | ១២៧ | ២០,៩២ |
| កម្មករពលកម្ម | ២៤ | ៥៩ | ១៩ | ៦ | ១០៨ | ១៧,៧៩ |
| សរុប | ១០១ | ២០៤ | ១៦៨ | ១៣៤ | ៦០៧ | ១០០% |

## ការអនុវត្តលក្ខន្តិកៈបុគ្គលិក និងបទបញ្ជាផ្ទៃក្នុង

- ចំនួនបុគ្គលិកដែលបានប្រើប្រាស់ក្នុងឆ្នាំ២០១១ ក្នុងកំរិត២,៧៧ លើ ១,០០០ អតិថិជន ដោយផ្អែកតាមផែនការឆ្នាំ មិនឱ្យលើសពីកំរិតកំណត់ ៣,០៤ លើ ១,០០០ អតិថិជន ។
- ពង្រឹងបន្ថែមទៀតនូវការអនុវត្តតួនាទី ភារកិច្ច , វិន័យ , ការងារ , ពេលម៉ោងធ្វើការ , សំលៀក បំពាក់ និងការប្រើប្រាស់សំភារៈការពារសុវត្ថិភាពពលកម្មរបស់ មន្ត្រី-និយោជិត កម្មករ អោយបានកាន់តែប្រសើរ ។
- បូកសរុបលទ្ធផលប្រលងសមត្ថភាព និង ព្រឹត្តប័ត្រពិន្ទុប្រចាំឆ្នាំរបស់ មន្ត្រី-និយោជិត ជូនថ្នាក់ដឹកពិនិត្យ , វាយតម្លៃ , ផ្តល់ការណែនាំ ព្រមទាំងធ្វើការកែលំអរលើ បណ្តាចំនុចខ្វះខាតទាំងនោះ ។

## ការលើកទឹកចិត្ត

- បានរៀបចំកម្មវិធីជូនលិខិតសរសើរ និង ប្រាក់រង្វាន់លើកទឹកចិត្តដល់មន្ត្រីនិយោជិតចំនួន ៤៥ រូប និងពិធីបំពាក់មេដាយការងារចំនួន ៦០រូប ដែលមានស្នាដៃក្នុងការអនុវត្តការងារបានល្អប្រសើរប្រចាំឆ្នាំ ។
- ស្នើសុំមេដាយការងារទៅក្រសួងជូន មន្ត្រី និយោជិត ចំនួន ៥៦រូប សំរាប់ឆ្នាំ ២០១១ ។
- បានធ្វើការផ្លាស់ប្តូរភារកិច្ចមន្ត្រី និយោជិត ០៦រូប ឱ្យស្របតាមតំរូវការចាំបាច់របស់អង្គភាព ។
- តែងតាំងតំឡើងឋានៈជូននិយោជិតចំនួន ០២រូប ក្នុងនោះប្រធានក្រុម ០១រូប និង អនុប្រធានផ្នែក ០១រូប។

## ការលើកទឹកចិត្ត

មានមន្ត្រីនិយោជិត ចំនួន ១៧រូប ទទួលការពិន័យក្នុងនោះ៖

- ថ្នាក់អនុវត្តទទួលទណ្ឌកម្ម <u>កំរិត១</u>: ចំនួន០៧រូប
- ថ្នាក់ប្រតិបត្តិទណ្ឌកម្ម <u>កំរិត១</u>: ចំនួន ០៧រូប , <u>កំរិត២</u>: ចំនួន០២រូប និង <u>កំរិត៤</u>: ចំនួន០១រូប

# ខ- ការអភិវឌ្ឍន៍ ធនធានមនុស្ស

## ការងារបណ្តុះបណ្តាល

សហការជាមួយមណ្ឌលបណ្តុះបណ្តាលក្នុងការបញ្ជូន មន្ត្រី-និយោជិត តាមបណ្តានាយកដ្ឋាន ទៅបណ្តុះបណ្តាល ក្នុង និង ក្រៅអង្គភាពបានចំនួន **៨៣៦រូប** (**ស្រី ១២៧រូប**,**ប្រុស៧០៩រូប**) **ដោយចែកចេញជា ២៩មុខវិជ្ជា ក្នុងនោះនិយោជិត ០១រូប បានទទួលការបណ្តុះបណ្តាលច្រើនមុខវិជ្ជា។**

## ការជ្រើសរើសនិយោជិត

ធ្វើការជ្រើសរើសនិយោជិត តាមតំរូវការជាក់ស្តែង របស់បណ្តានាយកដ្ឋាន ដោយផ្អែកតាមផែនការឆ្នាំ និងអង្គភាពអោយបានសមស្របតាមសេចក្តីកំណត់ លេខ០០៦ស.ក.ណ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីលក្ខខ័ណ្ឌនៃការជ្រើសរើសនិយោជិតក្នុងនោះបាន ៖

- ទទួលនិយោជិតហ្វឹកហាត់ ចំនួន១៧រូប ( ស្រី ០៤រូប ) ។
- ជ្រើសរើសជា និ.ជាប់កិច្ចសន្យាចំនួន ៣៣រូប (ស្រី ០៦រូប) ក្នុងនោះទទួលបានការអនុញ្ញាត ឲ្យនិយោជិតចូលនិវត្តន៍ បន្តកិច្ចសន្យា ចំនួន ០៤រូប ។
- បញ្ចូល និយោជិតជាប់កិច្ចសន្យា ទៅជា និយោជិតកម្មសិក្សាការី ចំនួន ២២រូប ( ស្រី ០៥រូប)។
- បញ្ចូលពី និយោជិតកម្មសិក្សាការី ទៅជា និយោជិតក្របខ័ណ្ឌពេញសិទ្ធ ចំនួន២១រូប(ស្រី ០៦រូប) ។
- ពន្យារពេលចូលនិវត្តន៍ ចំនួន ០៦រូប ។
- ស្នើសុំដាក់មន្ត្រីនិ.អោយចូលនិវត្តន៍ តាមអាយុកំណត់ចំនួន ១១រូប ។
- លុបឈ្មោះ មន្ត្រី-និយោជិត ចេញពីបញ្ជីបៀវត្សរ៍ ចំនួន ១២រូប ( លាឈប់ពីការងារ ០៣រូប , បញ្ចប់កិច្ចសន្យា ០៤រូប និង ទទួលមរណៈភាព ០៣រូប , បណ្តេញចេញ ០២រូប ) ។